អេស៊ីលីដា
ACLEDA
ACLEDA Institute of Business

# វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

ថ្នាលអប់រំដែលលោកអ្នកជឿទុកចិត្ត



# របាយការណ៍ប្រចាំឆ្នាំ ២០១៦

# វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

## ACLEDA INSTITUTE OF BUSINESS

*The Institute You Can Trust*

# ESP

## English for Specific Purposes

- Business Communication
- Business Writing






# GEP

## General English Program

Reading, Writing,
Listening and Speaking



Training Venue :
ACLEDA INSTITUTE OF BUSINESS, Building #50,
Street 516 Corner 335, Sangkat Beung Kak 1,
Khan Tuol Kork, Phnom Penh.

For more information :
023 986 937 / 015 900 486 / 015 600 185 / 015 600 410
E-mail: info@acleda-aib.edu.kh
Website: www.acleda-aib.edu.kh

# ទស្សនៈ និងបេសកកម្ម

## ទស្សនៈ

ជាវិទ្យាស្ថានឈានមុខ ក្នុងការផ្តល់សេវាកម្មអប់រំ បណ្តុះបណ្តាល ប្រកបដោយគុណភាពខ្ពស់បំផុត ជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍ ។

## បេសកកម្ម

បេសកកម្មរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា គឺផ្តល់នូវសេវាកម្មអប់រំកម្រិតឧត្តមសិក្សា ឯកទេសគ្រប់គ្រងពាណិជ្ជកម្ម និងសេវាកម្មបណ្តុះបណ្តាលជំនាញហិរញ្ញវត្ថុ និងធនាគារ ប្រកបដោយគុណភាព និងសីលធម៌ខ្ពស់បំផុត ជូនដល់និស្សិត និងសិក្ខាកាមជាតិ និងអន្តរជាតិ ដើម្បីអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ បង្កើនឧត្តមភាពក្នុងការប្រកួតប្រជែងទីផ្សារការងារ និងក្នុងការគ្រប់គ្រង ចាត់ចែងអាជីវកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់ ដោយអនុវត្តឲ្យបាននូវនិរន្តរភាព និងបង្កើនអត្ថប្រយោជន៍ជូនដល់ភាគទុនិក កម្មករនិយោជិត ព្រមទាំងសហគមន៍ទាំងអស់ ។

យើងប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍ សីលធម៌វិជ្ជាជីវៈ សង្គម ច្បាប់ និងបរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត ។

---

របាយការណ៍នេះរៀបចំដោយ
ការិយាល័យទំនាក់ទំនងសាធារណៈ និងគណៈកម្មាធិការប្រតិបត្តិ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា
និងចេញផ្សាយដោយការិយាល័យទំនាក់ទំនងសាធារណៈ ។

សម្រាប់ព័ត៌មានបន្ថែម និងចម្ងល់ផ្សេងៗ
សូមទាក់ទងមក វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា អាសយដ្ឋានៈ
អគារលេខ៥០ ផ្លូវលេខ៥១៦ កែង៣៣៥ ភូមិ០៦
សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

ប្រអប់សំបុត្រលេខ ៖ ១១៤៩
ទូរស័ព្ទ ៖ ០២៣ ៩៩៩ ៩៤៤ / ៨៨១ ៧៩០
ទូរសារ ៖ ០២៣ ៩៩៩ ៩៧៩ / ៨៨១ ៧៨០
អ៊ីម៉ែល ៖ info@acleda-aib.edu.kh





# កម្មវិធីអប់រំបណ្ដុះបណ្ដាលរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

## កម្មវិធីអប់រំកម្រិតឧត្តមសិក្សា

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានបំពេញមុខងារដ៏សំខាន់ក្នុងការអប់រំកម្រិតឧត្តមសិក្សា ឯកទេស គ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ និងធនាគារ ប្រកបដោយគុណភាព និងសីលធម៌ ជូនដល់និស្សិត ។



១- ថ្នាក់បរិញ្ញាបត្ររង



២- ថ្នាក់បរិញ្ញាបត្រ

# កម្មវិធីបណ្តុះបណ្តាលសម្រាប់ស្ថាប័នខាងក្រៅ និងសាធារណជន

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ផ្តល់នូវការហ្វឹកហ្វឺនផ្សេងៗពីគ្នា ដែលគួបផ្សំចំណេះដឹង និងជំនាញ ក្នុងការអនុវត្តការងារដោយផ្តោតលើគុណភាពជាចម្បង ។ បច្ចុប្បន្ននេះ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានកម្មវិធីហ្វឹកហ្វឺន៨ប្រភេទ ផ្តល់ជូនអតិថិជនមកពីស្ថាប័នខាងក្រៅ ទាំងក្នុងប្រទេស និងអន្តរជាតិ ៖



១- វគ្គហ្វឹកហ្វឺនតាមប្រក្រតិទិនហ្វឹកហ្វឺនប្រចាំឆ្នាំ



២- វគ្គហ្វឹកហ្វឺនតាមតម្រូវការ ឬតាមការស្នើសុំ



៣- វគ្គទស្សនកិច្ចសិក្សា សម្រាប់ប្រតិបត្តិករមីក្រូហិរញ្ញវត្ថុ




៤- វគ្គសិក្ខាសាលា និងទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍សម្រាប់និយតករមីក្រូហិរញ្ញវត្ថុ



៥- វគ្គហ្វឹកហ្វឺនអភិវឌ្ឍន៍ជំនាញ សម្រាប់និស្សិត និងសាធារណជន



៦- វគ្គហ្វឹកហាត់ការងារជាក់ស្តែងនៅកន្លែងការងារ



៧- វគ្គសិក្សាភាសាអង់គ្លេសទូទៅ



៨- វគ្គសិក្សាភាសាអង់គ្លេសសម្រាប់គោលបំណងជាក់លាក់

# កម្មវិធីបណ្តុះបណ្តាលសម្រាប់កម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានបំពេញមុខងារដ៏សំខាន់ផងដែរក្នុងការបណ្តុះបណ្តាលសមត្ថភាពកម្មករនិយោជិត ដែលបានរួមចំណែកនៅក្នុងភាពជោគជ័យរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ បច្ចុប្បន្ននេះ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានកម្មវិធីហ្វឹកហ្វឺន៤ប្រភេទ សម្រាប់បណ្តុះបណ្តាលកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី ៖



១- វគ្គហ្វឹកហ្វឺនកម្មករនិយោជិតថ្មី



២- វគ្គហ្វឹកហ្វឺនការងារដំបូង



៣- វគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍ជំនាញ



៤- វគ្គសិក្ខាសាលាបណ្តុះបណ្តាលគ្រូហ្វឹកហ្វឺន

# វិវឌ្ឍនាការ របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

ដោយទទួលបាននូវការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និង កីឡា និងដើម្បីបំពេញតម្រូវការទីផ្សារការងារលើវិស័យហិរញ្ញវត្ថុ អេស៊ីលីដា ត្រេននីង សេនធ័រ បានកម្លាយខ្លួនទៅជា វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា តាមអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ជាគ្រឹះស្ថានឧត្តមសិក្សា ក្នុងការផ្ដល់នូវសេវាកម្មអប់រំ ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ លើដេប៉ាតឺម៉ង់ គ្រប់គ្រងពាណិជ្ជកម្ម មុខជំនាញ ហិរញ្ញវត្ថុ និងធនាគារ និងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈលើវិស័យធនាគារ និងហិរញ្ញវត្ថុ ដល់សិស្ស-និស្សិត-អង្គការជាតិ និងអន្តរជាតិ ទាំងក្នុង និងក្រៅប្រទេស ប្រកបដោយគុណភាពខ្ពស់ស្តង់ដាអន្តរជាតិ ។



អនុក្រឹត្យស្ដីពីការទទួលស្គាល់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា



ពិធីចុះហត្ថលេខា រវាង វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និង ក្រុមហ៊ុន សាជីវកម្ម ពិស្ណុការ អន្តរជាតិ ក្នុងការសាងសង់សំណង់អគារវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានប្រារព្ធពិធីបើកបវេសនកាលថ្មីឆ្នាំសិក្សា ២០១៦-២០១៧ នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រោមអធិបតីភាព **ឯកឧត្តម យក់ ឌុំយ** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ជាតំណាងដ៏ខ្ពង់ខ្ពស់ របស់ **ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា និង **បណ្ឌិត អ៊ិន ចាន់នី** ប្រធាននាយកប្រតិបត្តិ ធនាគារ អេស៊ីលីដា ភីអិលស៊ី និងជាតំណាងភាគទុនិក នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។











# ចំនួនសិក្ខាកាមដែលបានចូលរួមវគ្គហ្វឹកហ្វឺន វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា តាំងពីការចាប់ផ្តើមឆ្នាំ២០០៤

## ក- សិក្ខាកាមជាកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី

| ប្រភេទវគ្គហ្វឹកហ្វឺន | ២០០៤-២០០៨ | ២០០៤-២០០៩ | ២០០៤-២០១០ | ២០០៤-២០១១ | ២០០៤-២០១២ | ២០០៤-២០១៣ | ២០០៤-២០១៤ | ២០០៤-២០១៥ | ២០០៤-២០១៦ |
|---|---|---|---|---|---|---|---|---|---|
| វគ្គហ្វឹកហ្វឺនកម្មករនិយោជិតថ្មី | ៥.៧១៦ | ៦.៨២១ | ៧.១៦០ | ៧.៩៥៦ | ៩.៣៣២ | ១២.០៤៣ | ១៤.៤១១ | ១៦.១២៨ | ១៧.៤៣៥ |
| វគ្គហ្វឹកហ្វឺនអភិវឌ្ឍន៍ជំនាញ | ៨២.៣៣១ | ១១៧.២៥២ | ១៦០.១៨៦ | ១៩៤.៥៧១ | ២២៦.៦៦១ | ២៦៧.៤៧០ | ៣០៨.៣៧៩ | ៣៤៦.០៩០ | ៣៩០.៥៦៦ |
| វគ្គហ្វឹកហ្វឺនការងារដំបូង | ២.១៦៥ | ៣.៤៣៥ | ៤.២៣៨ | ៥.១៦២ | ៦.៥៤០ | ៨.៣៤២ | ១០.១៩៨ | ១១.៨៦៥ | ១៣.៣៤៥ |
| **សិក្ខាកាមសរុប** | ៩០.២១២ | ១២៧.៥០៨ | ១៧១.៥៨៤ | ២០៧.៦៨៩ | ២៤២.៥៣៣ | ២៨៧.៨៥៥ | ៣៣២.៩៨៨ | ៣៧៤.០៨៣ | ៤២១.៣៤៦ |



## ខ- សិក្ខាកាមមកពីស្ថាប័នខាងក្រៅ និងជានិស្សិត

| ប្រភេទសិក្ខាកាម | ២០០៤-២០០៨ | ២០០៤-២០០៩ | ២០០៤-២០១០ | ២០០៤-២០១១ | ២០០៤-២០១២ | ២០០៤-២០១៣ | ២០០៤-២០១៤ | ២០០៤-២០១៥ | ២០០៤-២០១៦ |
|---|---|---|---|---|---|---|---|---|---|
| សិក្ខាកាមក្នុងប្រទេស | ២១៩ | ៣០៥ | ៦១៧ | ៨៤៧ | ១.១១៥ | ១.៧៥០ | ២.៨៧១ | ៤.១៨៦ | ៤.៩៦៨ |
| សិក្ខាកាមអន្តរជាតិ | ១៧៤ | ២៩៨ | ៥១៧ | ៧១៧ | ៨៦៨ | ១.៣០៣ | ១.៥៥៨ | ១.៧១៦ | ១.៧៩៦ |
| **សិក្ខាកាមសរុប** | **៣៩៣** | **៦០៣** | **១.១៣៤** | **១.៥៦៤** | **១.៩៨៣** | **៣.០៥៣** | **៤.៤២៩** | **៥.៩០២** | **៦.៧៦៤** |



# ទិន្នន័យហិរញ្ញវត្ថុសង្ខេប

| ឯកតាគិតជាដុល្លារអាមេរិក | ៣១/១២/១៦ បានធ្វើសវនកម្ម | ៣១/១២/១៥ បានធ្វើសវនកម្ម | ៣១/១២/១៤ បានធ្វើសវនកម្ម | បម្រែបម្រួល (%)[១] |
|---|---|---|---|---|
| **ទិន្នន័យហិរញ្ញវត្ថុសង្ខេប** | | | | |
| ទ្រព្យសកម្ម | ២៦.៦០៥.៩៤៩ | ១៦.៧៦៧.៦៩៤ | ១៦.៥២០.៣១៦ | ៥៨,៦៧% |
| បំណុល | ៥.៧៤២.៩៥៧ | ៧០១.២៩៩ | ៧៤០.៩៣០ | ៧១៨,៩០% |
| ដើមទុន | ១៧.៨០៥.០០០ | ១២.៨០៥.០០០ | ១២.៨០៥.០០០ | ៣៩,០៥% |
| មូលនិធិម្ចាស់ហ៊ុន | ២០.៨៦២.៩៩២ | ១៦.០៦៦.៣៩៥ | ១៥.៧៧៩.៣៨៦ | ២៩,៨៥% |
| ចំណូលដុល | ២.០០៦.៧៣៥ | ២.៣៧៥.៨៦២ | ៣.៥៤១.៨៨៦ | -១៥,៥៤% |
| ប្រាក់ចំណេញមុនដកពន្ធ | (២២៦.២៤៥) | ៣៥៩.១៥៩ | ១.០៩៣.៨៤៤ | -១៦២,៩៩% |
| ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ | (២០៣.៤០៣) | ២៨៧.០០៩ | ៨៧១.៦២០ | -១៧០,៨៧% |
| ចំណេញក្នុងមួយភាគហ៊ុន | $0,00 | $0,0២ | $0,0៧ | -១00% |
| ភាគលាភ[២] | $0,00 | $0,00 | $0,00 | 0% |

១ គិតពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

២ ភាគលាភ មិនត្រូវបានបែងចែកពីប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ (ធនាគារ អេស៊ីលីដា ភីអិលស៊ី, ក្រុមហ៊ុនមេ, កាន់កាប់ភាគហ៊ុន វិទ្យាស្ថាន ពាណិជ្ជសាស្រ្ត អេស៊ីលីដា ១00%)



កិច្ចប្រជុំក្រុមប្រឹក្សាភិបាល វិទ្យាស្ថាន ពាណិជ្ជសាស្រ្ត អេស៊ីលីដា



កិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃវិទ្យាស្ថាន ពាណិជ្ជសាស្រ្ត អេស៊ីលីដា

# ចំណុចសំខាន់ៗក្នុងឆ្នាំ២០១៦

- ទ្រព្យសកម្មកើនឡើង ៥៨,៦៧% រហូតដល់ ២៦.៦០៥.៩៨៩ដុល្លារអាមេរិក
- ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធថយចុះ-១៧០,៨៧% មកនៅត្រឹម(២០៣.៤០៣)ដុល្លារអាមេរិក
- មូលនិធិម្ចាស់ហ៊ុនកើនឡើង ២៩,៨៥% រហូតដល់ ២០.៨៦២.៩៩២ដុល្លារអាមេរិក
- បានបណ្តុះបណ្តាលកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី ចំនួន ៤.៨៥៩វគ្គ មានសិក្ខាកាមចូលរួមសរុប ចំនួន ៤៧.២៦៣នាក់
- បានបណ្តុះបណ្តាលកម្មករនិយោជិតក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេសចំនួន ៣វគ្គ មានសិក្ខាកាមចូលរួមសរុប ចំនួន ៤០នាក់
- បានបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍សម្រាប់ស្ថាប័នខាងក្រៅចំនួន ៣៥វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន ៥៥១នាក់
- បានបើកវគ្គបណ្តុះបណ្តាលអភិវឌ្ឍន៍ជំនាញសម្រាប់និស្សិតចំនួន ១៧វគ្គ មានសិក្ខាកាមចូលរួមសរុប ២៧១នាក់
- បានបើកវគ្គបណ្តុះបណ្តាលថ្នាក់ភាសាអង់គ្លេសកម្រិតទូទៅ (ត្រីមាសទីមួយ) សម្រាប់កម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី និងសាធារណជនទូទៅ ចំនួន ៣០ថ្នាក់ មានសិក្ខាកាមចូលរួមសរុប ២៨០នាក់ ។
- បានបើកថ្នាក់ឧត្តមសិក្សា (បរិញ្ញាបត្រ និងបរិញ្ញាបត្ររង) ចំនួន១៩ថ្នាក់ មាននិស្សិតសរុប ៤១០នាក់ ។



លោកស្រីបណ្ឌិត សូ ផនណារី ធ្វើបដិសណ្ឋារកិច្ចស្វាគមន៍ ដំណើរទស្សនកិច្ចសិក្សារបស់សិក្ខាកាមមកពីប្រទេសមីយ៉ាន់ម៉ា



កិច្ចប្រជុំប្រចាំឆ្នាំ រវាងថ្នាក់ដឹកនាំ និងកម្មករនិយោជិត នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

# លទ្ធផលដែលបានអនុវត្ត

## ទ្រព្យសកម្មសរុប/មូលនិធិម្ចាស់ហ៊ុន និងផលលើមូលធន



## ចំនួនសិក្ខាកាម



# មាតិកា

របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល . . . . . ១៣
របាយការណ៍នាយកវិទ្យាស្ថាន . . . . . ១៦
អង្គការលេខ . . . . . ១៩
ភាគទុនិក . . . . . ២០
ក្រុមប្រឹក្សាភិបាល . . . . . ២១
គណៈកម្មាធិការប្រតិបត្តិ . . . . . ២៤
ទីប្រឹក្សា . . . . . ២៧
ក្រុមសីលធម៌ . . . . . ២៨
របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនករឯករាជ្យ . . . . . ២៩
ស្ថាប័នដែលទទួលសេវាហ្វឹកហ្វឺន . . . . . ៥៨
ការិយាល័យកណ្តាល ធនាគារ អេស៊ីលីដា ភីអិលស៊ី និងបុត្រសម្ព័ន្ធ . . . . . ៧០
សកម្មភាពអប់រំបណ្តុះបណ្តាល . . . . . ៧១



ប្រតិភូ ធនាគារពិភពលោក ( World Bank ) ធ្វើទស្សនកិច្ចសិក្សាស្វែងយល់ពីការរីកចម្រើនរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា



រូបថតអនុស្សាវរីយ ពិធីប្រគល់វិញ្ញាបនបត្រ វគ្គបណ្តុះបណ្តាលគរុកោសល្យ និងវិធីសាស្ត្របង្រៀន ជូនដល់ សាស្ត្រាចារ្យ នៃ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

# របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល



**បណ្ឌិត សូ ផនណារី**

ប្រធានក្រុមប្រឹក្សាភិបាល

ការវិនិយោគក្នុងវិស័យអប់រំត្រូវការរយៈពេលវែង ដើម្បីឆ្លើយតបទៅនឹងគោលដៅនៃធុរកិច្ចនៅក្នុងវិស័យនេះ។ ទោះបីយ៉ាងណាការវិនិយោគក្នុងវិស័យអប់រំនេះ គាំទ្រដល់ការប្តេជ្ញាចិត្ត និងការលើកទឹកចិត្តដល់យុវជនរបស់យើង ឱ្យមានលទ្ធភាពទទួលបាននូវការអប់រំកម្រិតឧត្តមសិក្សាប្រកបដោយគុណភាពខ្ពស់ គឺជាគោលបំណងដ៏សំខាន់របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ម៉្យាងទៀតធុរកិច្ចនេះពិតជាផ្តល់នូវអត្ថប្រយោជន៍ និងតម្លៃតបស្នងមិនអាចកាត់ថ្លៃបាន ក្នុងការរួមចំណែកអភិវឌ្ឍន៍ធនធានមនុស្ស ប្រកបដោយសមត្ថភាពវិជ្ជាជីវៈខ្ពស់ ស្របតាមទស្សនៈ និងបេសកកម្ម របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដែលធនធានទាំងនោះនឹងផ្តល់នូវផលិតភាពការងារ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ជូនស្ថាប័ន ឬគ្រឹះស្ថានទាំងអស់ បន្ទាប់ពីធនធានទាំងនោះបានឆ្លងកាត់ការអប់រំ-បណ្តុះបណ្តាល និងបញ្ចប់ការសិក្សាពីវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

## វិស័យអប់រំកម្ពុជាក្នុងឆ្នាំ២០១៦

ជាចំណែកមួយនៃយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់វិស័យអប់រំ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់អាទិភាព ក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃគ្រឹះស្ថានអប់រំឧត្តមសិក្សា ដើម្បីដោះស្រាយនូវភាពមិនស៊ីគ្នារវាងតម្រូវការរបស់ទីផ្សារការងារ និងការផ្គត់ផ្គង់របស់គ្រឹះស្ថានឧត្តមសិក្សា ។

ក្រសួងអប់រំ យុវជន និងកីឡា បានឈានដល់ដំណាក់កាលពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ដែលមានលក្ខណៈកាន់តែស៊ីជម្រៅ និងមុតស្រួច ក្នុងបរិបទកំណែទម្រង់វិស័យអប់រំឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាពស្របតាមដំណើរការអភិវឌ្ឍរបស់រាជរដ្ឋា-ភិបាលកម្ពុជា ។ គោលនយោបាយយុទ្ធសាស្ត្រ កម្មវិធី និងចង្កោមសកម្មភាពជាអាទិភាពរបស់ក្រសួង ត្រូវបានសម្រេច ដើម្បីឆ្លើយតបទៅនឹងប្រព័ន្ធអប់រំមួយដែលធានាគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធពីសំណាក់ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ ក្នុងការប្រើប្រាស់ឱ្យអស់សក្តានុពលធនធានសរុប ។

កំណែទម្រង់នៅក្នុងអនុវិស័យអប់រំឧត្តមសិក្សារួមមាន៖ ១)- ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា តាមរយៈការពង្រឹងយន្តការជ្រើសរើសនិស្សិត ការរៀបចំក្របខណ្ឌគោលនយោបាយឧត្តមសិក្សា ការទទួលស្គាល់គុណភាពអប់រំ នៅឧត្តមសិក្សា និងការលើកកម្ពស់សកម្មភាពស្រាវជ្រាវ ២)-ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ តាមរយៈការលើកកម្ពស់អភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា និងការអភិវឌ្ឍសមត្ថភាពមន្ត្រីឧត្តមសិក្សា ។

គិតមកដល់បច្ចុប្បន្ននេះនៅទូទាំងប្រទេសកម្ពុជា មានគ្រឹះស្ថានឧត្តមសិក្សាចំនួន១២១ គឺកើនឡើងចំនួន៣បើប្រៀបធៀបជាមួយឆ្នាំ២០១៥ នៅក្នុងនោះគ្រឹះស្ថានឧត្តមសិក្សារដ្ឋមានចំនួន៤៨ និងឯកជនមានចំនួន៧៣ ដែលមានទីតាំងនៅក្នុង២០ខេត្តនិងរាជធានីភ្នំពេញ។ គ្រឹះស្ថានឧត្តមសិក្សា៧៣ (រដ្ឋ១៣ និងឯកជន៦០) ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំយុវជន និងកីឡានិងគ្រឹះស្ថានឧត្តមសិក្សា៤៨ទៀត ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងស្ថាប័ន១៥ផ្សេងទៀត ។

និស្សិតកំពុងសិក្សានៅគ្រឹះស្ថានឧត្តមសិក្សា ចាប់ពីថ្នាក់បរិញ្ញាបត្ររង ដល់ថ្នាក់បណ្ឌិត មានចំនួនសរុប២១៧.៨៤០នាក់ (ស្រី៤៣,៩៤%) ដែលក្នុងនោះថ្នាក់បរិញ្ញាបត្ររង មាននិស្សិតកំពុងសិក្សា ចំនួន២៣.៧៤៦នាក់ (ស្រី៤៧,៩៥%) ថ្នាក់បរិញ្ញាបត្រមាននិស្សិតកំពុងសិក្សាចំនួន១៧៤.១៤២នាក់ (ស្រី៤៦,០៥%) ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ មាននិស្សិតកំពុងសិក្សាចំនួន១៨.៧២៣នាក់ (ស្រី២១,៧៨%) និងថ្នាក់បណ្ឌិតមាននិស្សិត កំពុងសិក្សាចំនួន១.២២៩នាក់ (ស្រី៥,១៣%) ។

បុគ្គលិកអប់រំឧត្តមសិក្សាទាំងជនជាតិខ្មែរនិងជនបរទេស មានចំនួន១៣.៥០២នាក់ (ស្រី១៧,១៦%) ក្នុងនោះគ្រូមានសញ្ញាបត្រកម្រិតបរិញ្ញាបត្រចំនួន៣.១៦៦នាក់ស្មើនឹង២៣,៥១% (ស្រី៩៦៧នាក់ ស្មើនឹង ៣០,៥៤%) កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ ចំនួន៩.៣២០នាក់ ស្មើនឹង ៦៩,២៣%

(ស្រី ១.១៦៥ នាក់ ស្មើនឹង១២,៥០%) និងកម្រិតបណ្ឌិត ចំនួន១.០១៦នាក់ ស្មើនឹង ៧,៥៤% (ស្រី៩៩នាក់ ស្មើនឹង ៩,៧៤%)។

## លទ្ធផលសម្រេចបាន របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវលើការកំណត់យុទ្ធសាស្ត្រ និងដឹកនាំត្រួតពិនិត្យដំណើរការអាជីវកម្មរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដើម្បីធានាបាននូវអភិបាលកិច្ចសាជីវកម្ម និងការបង្កើនអត្ថប្រយោជន៍ជូនដល់ ភាគទុនិក កម្មករនិយោជិត និងសហគមន៍ទាំងអស់ ។ ក្រុមប្រឹក្សាភិបាល បានផ្តល់នូវគំនិតថ្មីៗ គាំទ្រ និងលើកទឹកចិត្តដល់ការប្រកាន់ខ្ជាប់នូវ គោលការណ៍ អភិបាលកិច្ចល្អ សីលធម៌ វិជ្ជាជីវៈ សង្គម ច្បាប់ និងបរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត។

ដើម្បីធានាបាននូវនិរន្តរភាព នៃប្រតិបត្តិការរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា អង្គប្រជុំក្រុមប្រឹក្សាភិបាល(ជួបប្រជុំផ្ទាល់) ត្រូវបានរៀបចំឡើងជាទៀងទាត់ ចំនួនបួនដងក្នុងមួយឆ្នាំ និងអង្គប្រជុំវិសាមញ្ញក្រុមប្រឹក្សាភិបាលមួយចំនួនទៀត អាចធ្វើឡើងនៅពេលមានសំណូមពរពីសមាជិក ក្រុមប្រឹក្សាភិបាលចំនួនមួយភាគបីដែលអង្គប្រជុំអាចរៀបចំឡើងជាលក្ខណៈជួបប្រជុំផ្ទាល់ ឬតាមមធ្យោបាយ អេឡិចត្រូនិច ឬទូរស័ព្ទ ។

### សកម្មភាពសំខាន់ៗ របស់ក្រុមប្រឹក្សាភិបាល ក្នុងឆ្នាំ២០១៦ រួមមាន៖

- បានត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍វឌ្ឍនភាពនៃប្រតិបត្តិការអាជីវកម្មប្រចាំខែប្រចាំត្រីមាស ព្រមទាំងបានផ្តល់អនុសាសន៍ និងផែនការសកម្មភាពការងារដល់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដើម្បីជំរុញដំណើរការអាជីវកម្មឲ្យទទួលលទ្ធផលកាន់តែប្រសើរឡើង ។
- បានអនុម័តលើ ការកែសម្រួលអង្គការលេខថ្មី របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- បានអនុម័តយល់ព្រមលើ របាយការណ៍សវនកម្មឯករាជ្យ(KPMG) លើរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍ប្រចាំឆ្នាំ២០១៥ ។
- បានអនុម័តជ្រើសរើសយក Pricewaterhouse Coopers (PwC) ដើម្បីធ្វើសវនកម្មលើប្រតិបត្តិការអាជីវកម្មប្រចាំឆ្នាំ២០១៧
- បានពិនិត្យ និងអនុម័តយល់ព្រមលើ ផែនការអាជីវកម្មប្រាំឆ្នាំ (២០១៧-២០២១) និងផែនការថវិកាទិញឧបករណ៍-សម្ភារប្រចាំឆ្នាំ២០១៧ ។
- បានអនុម័តយល់ព្រមលើសំណើបញ្ចូលផែនការថវិកាទិញឧបករណ៍-សម្ភារចំនួន៣.២លានដុល្លារអាមេរិក(សម្រាប់បំពាក់អគារសិក្សាថ្មី) ចូលទៅក្នុងផែនការអាជីវកម្មប្រាំឆ្នាំ ២០១៧-២០២១ ។
- បានអនុម័តបង្កើតគណៈកម្មាធិការរបស់ ក្រុមប្រឹក្សាភិបាលចំនួន២ គឺ៖ ១-គណៈកម្មាធិការសវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល, និង ២-គណៈកម្មាធិការសិក្សាធិការនៃក្រុមប្រឹក្សាភិបាល ។
- បានពិនិត្យនិងអនុម័តយល់ព្រមលើលក្ខន្តិកៈនៃក្រុមប្រឹក្សាភិបាល ។
- បានពិនិត្យ និងអនុម័តយល់ព្រមលើគោលការណ៍អភិបាលកិច្ចសាជីវកម្មដែលរួមមាន៖ ធម្មនុញ្ញរបស់ក្រុមប្រឹក្សាភិបាល, ក្រមសីលធម៌របស់ក្រុមប្រឹក្សាភិបាល, លិខិតតែងតាំងអភិបាល, លក្ខន្តិកៈនៃគណៈកម្មាធិការ របស់ក្រុមប្រឹក្សាភិបាល និងលក្ខន្តិកៈរបស់នាយកវិទ្យាស្ថាន ។
- បានពិនិត្យនិងអនុម័តយល់ព្រមលើ លក្ខន្តិកៈរបស់គណៈកម្មាធិការសវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់នៃក្រុមប្រឹក្សាភិបាល, និងគណៈកម្មាធិការសិក្សាធិការនៃក្រុមប្រឹក្សាភិបាល ។
- បានសម្រេចស្នើអនុសាសន៍ទៅកាន់តំណាងភាគទុនិក ដើម្បីអនុម័តបង្កើនសមាជិកភាពអភិបាលពីចំនួន០៥រូប ទៅចំនួន ០៦រូប ដោយតែងតាំងនាយកវិទ្យាស្ថាន ជាសមាជិកអចិន្ត្រៃយ៍ និងបណ្ឌិត អ៊ុង សំអ៊ុល ជាតំណាងសាស្ត្រាចារ្យ និងបុគ្គលិក ។
- បានពិនិត្យនិងសម្រេច ដើម្បីស្នើអនុសាសន៍ទៅកាន់តំណាងភាគទុនិក អនុម័តលើសំណើបង្កើនដើមទុនចំនួន ៥ លានដុល្លារអាមេរិក ។
- បានផ្តល់អនុសាសន៍និងអនុម័តលើ ផែនការយុទ្ធសាស្ត្ររយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- បានផ្តល់អនុសាសន៍និងអនុម័តលើ លក្ខខណ្ឌផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តក្នុងភាគកម្មប្រាក់ចំណេញ សម្រាប់នាយកវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- បានពិនិត្យផ្តល់អនុសាសន៍និងអនុម័តយល់ព្រម ឱ្យថ្នាក់ដឹកនាំជាន់ខ្ពស់ ចុះកិច្ចសន្យាកម្ចីឥណទាន ចំនួន ១៣ លានដុល្លារអាមេរិក ពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដើម្បីគាំទ្រដល់ដំណើការសាងសង់អគារវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- បានពិនិត្យនិងផ្តល់អនុសាសន៍លើ សំណើសុំជួលទីប្រឹក្សាលើកិច្ចការអភិវឌ្ឍន៍ធនធានមនុស្ស និងកិច្ចការសិក្សាធិការសម្រាប់គាំទ្រដល់ដំណើរការប្រតិបត្តិការជាគ្រឹះស្ថានឧត្តមសិក្សា ដើម្បីអនុលោមទៅនឹងក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងបទដ្ឋានធានាគុណភាពជាតិ និងស្របទៅនឹងផែនការយុទ្ធសាស្ត្រ ដែលបានអនុមតិ ។
- បានពិនិត្យនិងអនុម័តយល់ព្រមលើ ការបញ្ចូលអតិផរណាឆ្នាំមុនទៅក្នុងប្រាក់បៀវត្សរ៍មូលដ្ឋាន សម្រាប់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។

សម្រាប់លទ្ធផលហិរញ្ញវត្ថុឆ្នាំ២០១៦ ដែលជាដំណាក់កាលដំបូងនៃការចាប់ផ្តើមដំណើរការប្រតិបត្តិការឧត្តមសិក្សា វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានបង់ខាតចំនួន ២០៣.៤០៣ដុល្លារអាមេរិក ខណៈទ្រព្យសកម្មបានកើនឡើង៥៨,៦៧% រហូតដល់ ២៦.៦០៥.៩៤៩ដុល្លារអាមេរិកមូលនិធិម្ចាស់ហ៊ុនបានកើនឡើង ចំនួន២៩,៨៥% រហូតដល់ ២០.៨៦២.៩៩២ដុល្លារអាមេរិក។ អនុបាតប្រសិទ្ធភាពប្រតិបត្តិការបានកើនឡើងពី៥៩,៣៤% រហូតដល់៧២,៣៣% និងអត្រាប្រាក់ចំណូលដែលបានមកពីការហ្វឹកហ្វឺន និងបណ្តុះបណ្តាលសិក្ខាកាមមកពីខាងក្រៅ (ទាំងក្នុងនិងក្រៅប្រទេស) រួមនឹងចំណូលផ្សេងៗ ធៀបនឹងចំណូលដុលបានថយចុះពី១៩,៥៤% មកត្រឹម ១៧,៣៦% ប៉ុណ្ណោះ។

## ផែនការយុទ្ធសាស្ត្រចម្បងៗសម្រាប់ឆ្នាំ២០១៧

ដើម្បីសម្រេចបានសមិទ្ធផលសម្រាប់ឆ្នាំ២០១៧ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានកំណត់ផែនការជាអាទិភាពដូចតទៅ៖

១- បន្តពង្រឹងលើការដឹកនាំត្រួតពិនិត្យដំណើការអាជីវកម្មរបស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដើម្បីធានាបាននូវ អភិបាលកិច្ចសាជីវកម្មល្អ និងការបង្កើនអត្ថប្រយោជន៍ជូនដល់ភាគទុនិកកម្មករនិយោជិត និងសហគមន៍ទាំងអស់ ។

២- បន្តពង្រឹងលើការប្រតិបត្តិគោលការណ៍ទាំងអស់ឱ្យបានខ្ជាប់ខ្ជួន និងជំរុញការអភិវឌ្ឍគោលការណ៍ប្រតិបត្តិ និងគ្រប់គ្រងកិច្ចការជំនួញ ឱ្យមានភាពត្រឹមត្រូវ គ្រប់គ្រាន់ និងទាន់សម័យ ស្របតាមការវិវឌ្ឍថ្មីៗរបស់ក្រុមហ៊ុនមេ និងទីផ្សារដោយធានាបាននូវអនុលោមភាពតាមច្បាប់ជាតិនិងអន្តរជាតិ ជាពិសេសស្របទៅតាមផែនការកំណែទម្រង់របស់ក្រសួងអប់រំយុវជននិងកីឡា ដែលនឹងក្លាយជាស្ថាប័នអាណាព្យាបាល ។

៣- លើកកម្ពស់ និងពង្រឹងវប្បធម៌ គុណភាព តម្លាភាព និងភាពមិនអត់ឱនដោយអនុលោមតាមក្រុមហ៊ុនមេ និងដើម្បីក្លាយទៅជាស្ថាប័នគំរូនៅក្នុងវិស័យដែលខ្លួនកំពុងតែប្រតិបត្តិការ ។

៤- ជំរុញការអភិវឌ្ឍកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច ដែលមានគុណភាពខ្ពស់ ដោយអនុលោមតាមក្របខ័ណ្ឌគុណវុឌ្ឍិជាតិនិងអាស៊ាន ដើម្បីរួមចំណែកគាំទ្រដល់វិស័យហិរញ្ញវត្ថុ និងធនាគារ ទាំងនៅក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ ។

៥- បង្កើតបណ្តាញសិក្សាដ៏រឹងមាំក្នុងភាពជាដៃគូ និងកម្មវិធីផ្លាស់ប្តូរសាស្ត្រាចារ្យ...ជាមួយគ្រឹះស្ថានដែលមានកេរ្តិ៍ឈ្មោះល្បី ដើម្បីអភិវឌ្ឍវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ឱ្យក្លាយជា មជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលថ្នាក់តំបន់ សម្រាប់វិស័យហិរញ្ញវត្ថុនិងធនាគារ ។

៦- ផ្តោតការយកចិត្តទុកដាក់ខ្ពស់ ក្នុងការវិនិយោគលើធនធានមនុស្សតាមរយៈការកសាងសមត្ថភាពបន្ថែមដល់ថ្នាក់គ្រប់គ្រង និងបុគ្គលិកទាំងចំណេះដឹងជំនាញ និងចំណេះដឹងភាសាយានដើម្បីឱ្យធនធានមនុស្សរបស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បំពេញការងារប្រកបដោយភាពវិជ្ជាជីវៈ គុណភាព ប្រសិទ្ធភាព និងផលិតភាពការងារខ្ពស់ ធានាបាននូវការផ្តល់សេវាកម្មអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈប្រកបដោយគុណភាពខ្ពស់បំផុត ។

៧- ធ្វើឱ្យប្រាកដឡើងនូវទស្សនវិស័យ នៃការផ្តល់នូវសេវាកម្មអប់រំប្រកបដោយគុណភាពខ្ពស់បំផុត ។ កំណត់នូវភាពលេចធ្លោរបស់ស្ថាប័ននៅក្នុងទីផ្សារថាជាគ្រឹះស្ថានអប់រំ ប្រកបដោយវិន័យនិងសីលធម៌ខ្ពស់ ដែលផ្តល់តម្លៃ និងកិត្តិយសដល់ បទដ្ឋានសិក្សាធិការ និងវិជ្ជាជីវៈដ៏ល្អវិសេស ។

តាងនាមឱ្យក្រុមប្រឹក្សាភិបាលនៃ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ខ្ញុំសូមសម្តែងនូវគារវកិច្ច និងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាក្រុមហ៊ុនមេអតិថិជន-សិស្សនិស្សិត និងសាធារណជន ព្រមទាំងដៃគូជាតិអន្តរជាតិ ជាពិសេសរាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់ការជឿទុកចិត្ត និងគាំទ្រ ដល់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ក្នុងបេសកកម្មអប់រំ-បណ្តុះបណ្តាលធនធានមនុស្សកន្លងមក ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សូមសម្តែងនូវអំណរគុណ និងកោតសរសើរ ចំពោះសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ក៏ដូចជាកម្មករនិយោជិតនិងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដាដែលមានការប្តេជ្ញាចិត្តខ្ពស់ និងទទួលជោគជ័យក្នុងការបំពេញកិច្ចការងារមួយឆ្នាំកន្លងមកនេះ ។

ទីបញ្ចប់ ខ្ញុំសូមបួងសួងសូមឱ្យលោកអ្នកព្រមទាំងក្រុមគ្រួសារទាំងអស់ទទួលបាននូវសុខភាពល្អសិរីសួស្តីជោគជ័យមង្គលនិងវិបុលសុខជានិច្ចនិរន្តរ៍តរៀងទៅ ។




បណ្ឌិត សូ ផនណារី
*ប្រធានក្រុមប្រឹក្សាភិបាល*

ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧



រូបថតអនុស្សាវរីយ ឯកឧត្តមបណ្ឌិត ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ជាមួយ លោកស្រីបណ្ឌិត សូ ផនណារី

# របាយការណ៍នាយកវិទ្យាស្ថាន



**លោក ឆន ពន្លឺ**
នាយកវិទ្យាស្ថាន

ស្ថិតនៅក្នុងដំណាក់កាលនៃការអនុវត្ត វិធានការកំណែទម្រង់ដែលមានលក្ខណៈកាន់តែស៊ីជម្រៅ និងមុតស្រួចក្នុងបរិបទកំណែទម្រង់វិស័យអប់រំឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព ជាពិសេសកំណែទម្រង់ឧត្តមសិក្សា ឆ្នាំ២០១៦គឺជាឆ្នាំនៃកំណត់ត្រាប្រវត្តិសាស្ត្រមួយសម្រាប់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដែលបេសកកម្មរួមចំណែក អភិវឌ្ឍន៍ធនធានមនុស្សរបស់ខ្លួន (អេស៊ីលីដា ត្រេននីង សេនធ័រ) ត្រូវបានទទួលនូវការវាយតម្លៃ និងការផ្តល់នូវទំនុកចិត្តខ្ពស់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈអនុក្រឹត្យលេខៈ ១៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការទទួលស្គាល់ការកម្លាយខ្លួនជា **វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា** ដើម្បីធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ លើដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម។ លើសពីនេះ ទៅទៀតបរិមាណនិស្សិតដែលបានចុះឈ្មោះចូលសិក្សា សម្រាប់ឆ្នាំសិក្សាដំបូង (២០១៦-២០១៧) របស់វិទ្យាស្ថាន បានបង្កើតនូវកំណត់ត្រាថ្មីមួយ បង្ហាញពីសន្ទុះនៃការគាំទ្រ និងការផ្តល់ទំនុកចិត្តខ្ពស់ ពីសំណាក់សិស្ស-និស្សិត ព្រមទាំងអាណាព្យាបាល មកលើ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

ដើម្បីជាសក្ខីកម្មឆ្លើយតប ទៅនឹងជំនឿទុកចិត្តខ្ពស់របស់មហាជន និងដើម្បីបង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំលើបេសកកម្ម ក្នុងវិស័យអប់រំរបស់ខ្លួន វិទ្យាស្ថាន បានវិនិយោគទុន ជាង ៣៧ លានដុល្លារអាមេរិក ដើម្បីសាងសង់អគារវិទ្យាស្ថាន ស្របតាមបទដ្ឋានអន្តរជាតិ លើផ្ទៃដីទំហំ ៧.៥៧ ហិចតា ។

ស្របជាមួយនឹងគតិពេចន៍ **"ថ្នាលអប់រំដែលលោកអ្នកជឿទុកចិត្ត"** និងគុណតម្លៃស្នូល **"គុណភាព សីលធម៌ ភាពខារ"** និស្សិតដែលទទួលបាន ការបណ្តុះបណ្តាលពីវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នឹងមានទំនុកចិត្តខ្ពស់លើសមត្ថភាពវិជ្ជាជីវៈពិតប្រាកដរបស់ខ្លួនលើជំនាញហិរញ្ញវត្ថុ និងធនាគារនិងសីលធម៌ ដ៏ល្អប្រពៃដែលជាធាតុសំខាន់ចាំបាច់បំផុត ដើម្បីបង្កើនសក្តានុភាពសម្រាប់យកប្រៀបលើការប្រកួតប្រជែងទីផ្សារការងារ ទាំងនៅក្នុងស្រុកនិងក្នុងតំបន់ ព្រមទាំងធានាបាននូវវិវឌ្ឍនាការក្នុងអាជីពការងារ ។

# សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៦

## ការគ្រប់គ្រងកិច្ចការបណ្តុះបណ្តាល

- បានបណ្តុះបណ្តាលគ្រូហ្វឹកហ្វឺនថ្មីបន្ថែមទៀត ចំនួន ១៣៥នាក់ (គ្រូហ្វឹកហ្វឺន នៅការិយាល័យកណ្តាលចំនួន ៥៩នាក់ និងនៅសាខាចំនួន ៧៦នាក់) ដើម្បីលើកស្ទួយគុណភាព និងប្រសិទ្ធភាព នៃការបណ្តុះបណ្តាល ឆ្លើយតបទៅនឹងតម្រូវការ និងការវិវឌ្ឍថ្មីៗ របស់អតិថិជនខាងក្នុង និងខាងក្រៅ។
- បានចាត់ចែងអភិវឌ្ឍន៍ និងធ្វើបច្ចុប្បន្នកម្ម លើគោលការណ៍និតិវិធី និងកម្មវិធីសិក្សានៃវគ្គហ្វឹកហ្វឺន កម្មករនិយោជិតថ្មី និងវគ្គបណ្តុះបណ្តាលកម្មករនិយោជិត ដែលកំពុងបម្រើការងារ ដោយសហការជាមួយ នាយកដ្ឋាន-ការិយាល័យដែលពាក់ព័ន្ធ ដើម្បីធានាបាននូវភាពទាន់សម័យស្របទៅតាមតម្រូវការរបស់សិក្ខាកាម និងវិវឌ្ឍនាការរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។
- បានចាត់ចែងការបណ្តុះបណ្តាល ដល់កម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេសចំនួន ៤.៨៦២ វគ្គ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៤៧.៣០៣នាក់។ ជាមធ្យមនៅក្នុងឆ្នាំ ២០១៦ បុគ្គលិកធនាគារ អេស៊ីលីដាម្នាក់ៗ ទទួលបានការបណ្តុះបណ្តាល ចំនួន ៤ដង ។
- បានបន្តសុពលភាព និងបានចុះអនុស្សារណៈយោគយល់គ្នាថ្មីៗបន្ថែមជាមួយគ្រឹះស្ថានធនាគារមីក្រូហិរញ្ញវត្ថុ អង្គការប្រតិបត្តិការឥណទាននិងគ្រឹះស្ថានសិក្សា និងក្រុមហ៊ុនឯកជនផ្សេងៗទៀត សរុបចំនួន ៦៤ (គិតត្រឹមខែធ្នូ ឆ្នាំ២០១៦) ដើម្បីផ្តល់ឱកាសការងារដល់និស្សិតដែលបានបញ្ចប់ដោយជោគជ័យ ក្នុងវគ្គសិក្សាអភិវឌ្ឍន៍ជំនាញខ្លីៗ របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។
- បានចុះកិច្ចព្រមព្រៀងសហការជាមួយនឹង វិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុក្រុងឡុងដ៍ (London Institute of Banking & Finance -LIBF) ដើម្បីរួមសហការផ្តល់នូវការបណ្តុះបណ្តាល វគ្គជំនាញខ្ពស់អន្តរជាតិ លើវិស័យធនាគារ និងហិរញ្ញវត្ថុ ដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ក្នុងប្រទេសកម្ពុជា និងក្នុងតំបន់ ។
- បានបន្តផ្តល់ការហ្វឹកហ្វឺន ចែករំលែកបទពិសោធន៍ដ៏ជោគជ័យរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ជូនដល់សិក្ខាកាមជានិស្សិត និងសិក្ខាកាមមកពីបណ្តាក្រុមហ៊ុន អង្គការ ស្ថាប័នធនាគារ ហិរញ្ញវត្ថុជាតិ និងអន្តរជាតិ សរុបចំនួន ៥២ វគ្គ ដោយមានសិក្ខាកាមចូលរួមសរុបចំនួន ៨២២ នាក់។

## កិច្ចការអប់រំសិក្សា

- បានទទួលនូវការវាយតម្លៃ និងការផ្តល់នូវទំនុកចិត្តខ្ពស់ ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈអនុក្រឹត្យលេខៈ ១៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ស្តីពីការទទួលស្គាល់ការកម្លាយខ្លួនជា វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដើម្បីធ្វើការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ លើដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម។

- ដើម្បីចូលរួមក្នុងការលើកកម្ពស់វិស័យអប់រំ សម្រាប់ប្រយោជន៍ជាតិ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បានសហការជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងការផ្តល់ឥណទាននិស្សិតដែលមានរយៈពេលវែងរហូតដល់៨ឆ្នាំ ជាមួយនឹងអត្រាការប្រាក់ពិសេស និងរបៀបសងត្រឡប់ដែលមានភាពលក្ខណៈអនុគ្រោះខ្ពស់ ដើម្បីបើកឱកាសឱ្យនិស្សិតទាំងអស់ ទាំងនិស្សិតដែលមានលទ្ធភាពនិងមិនមានលទ្ធភាព

បង់ថ្លៃសិក្សាសុទ្ធតែមានឱកាសសិក្សានៅវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ដូចៗគ្នាផងដែរ។

- នាខែមេសា ឆ្នាំ២០១៦ វិទ្យាស្ថានបានសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (Iinternational Financial Corporation-IFC) លើគម្រោងវិនិយោគសាងសង់អគារវិទ្យាស្ថានកម្រិតស្តង់ដារអន្តរជាតិតាមរយៈការចុះកិច្ចព្រមព្រៀងកម្ចីឥណទានពី IFC ចំនួន១៣លានដុល្លារអាមេរិក ។
- នាខែឧសភា ឆ្នាំ២០១៦ វិទ្យាស្ថាន បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនអ៊ី&អេខនសាល់ធេន (E& A Consultant) ក្នុងទំហំទឹកប្រាក់ចំនួន៩៥.៥៣៥ដុល្លារអាមេរិក ដើម្បីសិក្សានិងវាយតម្លៃលើហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ និងដើម្បីស្នើសុំអនុញ្ញាតជាគោលការណ៍ពីក្រសួងបរិស្ថានសម្រាប់គម្រោងសាងសង់អគារវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- នាខែតុលា ឆ្នាំ២០១៦ វិទ្យាស្ថាន បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនសាជីវកម្មពិស្ណុការអន្តរជាតិ (PISNOKA International Corporation) ក្នុងទំហំទឹកប្រាក់ចំនួន១៨.២៦០.០០០ដុល្លារអាមេរិក ដើម្បីសាងសង់អគារវិទ្យាស្ថាន សរុបមានចំនួន៦អគារ រួមមាន៖ អគារសិក្សាកម្ពស់០៥ជាន់ ចំនួន២, អគាររដ្ឋបាល (រួមមានទាំងអាហារដ្ឋាននិងបណ្ណាគារ) កម្ពស់០៣ជាន់ ចំនួន១, អគារបណ្ណាល័យកម្ពស់០៣ជាន់ចំនួន១, អគារអន្តេវាសិកដ្ឋានសម្រាប់និស្សិត ស្នាក់នៅកម្ពស់០៥ជាន់ ចំនួន២ ព្រមទាំងទីលានកីឡាបាល់ទាត់ បាល់ទះ បាល់បោះ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត នៅក្នុងបរិវេណវិទ្យាស្ថានទាំងមូល ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនិងគ្រូបង្រៀន សរុបចំនួន៤៦នាក់ ឱ្យចូលរួមវគ្គបណ្តុះបណ្តាលគរុកោសល្យគ្រូបង្រៀននៅវិទ្យាស្ថានជាតិអប់រំ និងបានចាត់ចែងបណ្តុះបណ្តាល(ផ្ទៃក្នុង)ដល់គ្រូបង្រៀនចំនួន២៣នាក់ ដើម្បីធានាដល់គុណភាពនៃការផ្តល់នូវសេវាកម្មអប់រំ ប្រកបដោយជំនាញវិជ្ជាជីវៈនិងគរុកោសល្យ។
- បានចាត់បញ្ជូនថ្នាក់គ្រប់គ្រង និងមន្ត្រីជំនាញពាក់ព័ន្ធរបស់វិទ្យាស្ថាន សរុបចំនួន០៦នាក់ ឱ្យចូលរួមវគ្គបណ្តុះបណ្តាល និងវគ្គសិក្ខាសាលាចំនួន៤វគ្គ ដែលរៀបចំឡើងដោយក្រសួងអប់រំ យុវជន និងកីឡា និងដោយសមាគមគ្រឹះស្ថានឧត្តមសិក្សា ដើម្បីធានាបាននូវភាពទាន់សម័យ និងអនុលោមភាពនៃប្រតិបត្តិការសេវាកម្មអប់រំ ។
- បានចុះអនុស្សារណៈនៃការយោគយល់គ្នា ជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ដើម្បីផ្តល់ឱកាសដល់និស្សិតរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា អាចធ្វើទស្សនកិច្ចសិក្សា, ចុះហាត់ការដោយផ្ទាល់នៅតាមបណ្តាសាខា និងការិយាល័យកណ្តាល នៃធនាគារ អេស៊ីលីដា ភីអិលស៊ី និងការសិក្សាជាមួយសាស្ត្រាចារ្យដែលកំពុងបម្រើការងារដោយជោគជ័យ នៅក្នុងធនាគារ អេស៊ីលីដា ភីអិលស៊ី ។
- បានទទួលនូវការអនុញ្ញាតជាផ្លូវការលើការផ្សព្វផ្សាយពាណិជ្ជកម្មសេវាអប់រំកម្រិតឧត្តមសិក្សា ស្របតាមបញ្ញត្តិរបស់ ក្រសួងអប់រំយុវជន និងកីឡា តាមរយៈទិដ្ឋាការអនុញ្ញាតលេខ ០២/២០១៦គ.ព.ឧ.រ.ផ ។
- បានទទួលចុះឈ្មោះនិស្សិតចំនួន ៤១០នាក់ (ថ្នាក់បរិញ្ញាបត្ររង ចំនួន៨៨នាក់ និងថ្នាក់បរិញ្ញាបត្រ ចំនួន៣២២នាក់) ឱ្យចូលសិក្សាសម្រាប់ឆ្នាំសិក្សាដំបូង (២០១៦-២០១៧) ក្នុងនោះវិទ្យាស្ថានបានផ្តល់អាហារូបករណ៍ប្រភេទ ក (១០០% បូកប្រាក់ឧបត្ថម្ភ ៤.៨០០ដុល្លារ), ប្រភេទ ខ (១០០%) និងប្រភេទ គ (៥០%) ដល់និស្សិតសរុបចំនួន ៤១នាក់ ។
- បានទទួលការអនុម័តពីក្រុមប្រឹក្សាភិបាល លើសំណើសុំបង្កើនដើមទុនចំនួន ៥លានដុល្លារអាមេរិក សម្រាប់គាំទ្រដល់ដំណើរការសាងសង់អគារវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

## លទ្ធផលប្រតិបត្តិការក្នុងឆ្នាំ២០១៦

- ទ្រព្យសកម្មកើនឡើងពី ១៦.៧៦៧.៦៩៤ ដុល្លារអាមេរិក រហូតដល់ ២៦.៦០៥.៩៤៩ ដុល្លារអាមេរិក ។
- មូលនិធិម្ចាស់ហ៊ុនកើនឡើងពី ១៦.០៦៦.៣៩៥ ដុល្លារអាមេរិក រហូតដល់ ២០.៨៦២.៩៩២ ដុល្លារអាមេរិក ។
- អនុបាតប្រសិទ្ធភាពប្រតិបត្តិការបានកើនឡើងពី ៥៩,៣៤% រហូតដល់ ៧២,៣៣%។
- អត្រាប្រាក់ចំណូលដែលបានមកពីការហ្វឹកហ្វឺននិងបណ្តុះបណ្តាលសិក្ខាកាមមកពីខាងក្រៅរួមនឹងចំណូលផ្សេងៗ ធៀបនឹងចំណូលដុល បានថយចុះពី ១៩,៥៤%មកនៅត្រឹម១៧,៣៦%។
- ខាតបង់ប្រាក់ក្នុងឆ្នាំប្រតិបត្តិការចំនួន (២០៣.៤០៣) ដុល្លារអាមេរិក
- ការបណ្តុះបណ្តាលកម្មករនិយោជិតធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ឆ្នាំ ២០១៦ ៖

| | | |
|---|---|---|
| - វគ្គហ្វឹកហ្វឺនកម្មករនិយោជិតថ្មី | ចំនួន ២៨ វគ្គ | សរុបសិក្ខាកាម ចំនួន ១.៣០៧ នាក់ |
| - វគ្គហ្វឹកហ្វឺនការងារដំបូង | ចំនួន ១.២៩៩ វគ្គ | សរុបសិក្ខាកាម ចំនួន ១.៤៨០ នាក់ |
| - វគ្គបណ្តុះបណ្តាលកម្មករនិយោជិតដែលកំពុងបម្រើការងារ | ចំនួន ៣.៥២៩ វគ្គ | សរុបសិក្ខាកាម ចំនួន ៤៤.៣៤១ នាក់ |
| - វគ្គបណ្តុះបណ្តាលជំនាញគ្រូហ្វឹកហ្វឺនថ្មី | ចំនួន ៣ វគ្គ | សរុបសិក្ខាកាម ចំនួន ១៣៥ នាក់ |

- ការបណ្តុះបណ្តាលកម្មករនិយោជិតក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេស ធនាគារ អេស៊ីលីដា ភីអិលស៊ី ៖

| | | |
|---|---|---|
| - វគ្គហ្វឹកហ្វឺននៅនឹងកន្លែងការងារ | ចំនួន ០២ វគ្គ | សរុបសិក្ខាកាម ចំនួន ០៤ នាក់ |
| - វគ្គហ្វឹកហ្វឺននៅក្នុងថ្នាក់ | ចំនួន ០១ វគ្គ | សរុបសិក្ខាកាម ចំនួន ៣៦ នាក់ |

- ការបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍ សម្រាប់ស្ថាប័នខាងក្រៅ ៖

| | | |
|---|---|---|
| - វគ្គសិក្ខាសាលាសម្រាប់ស្ថាប័នក្នុងស្រុក | ចំនួន ៣០ វគ្គ | សរុបសិក្ខាកាម ចំនួន ៥១១ នាក់ |
| - វគ្គទស្សនកិច្ចសិក្សាសម្រាប់ស្ថាប័នពីក្រៅប្រទេស | ចំនួន ០៥ វគ្គ | សរុបអ្នកចូលរួម ចំនួន ៤០ នាក់ |
| • វគ្គបណ្តុះបណ្តាលជំនាញសម្រាប់និស្សិត | ចំនួន ១៧ វគ្គ | សរុបសិក្ខាកាម ចំនួន ២៧១ នាក់ ។ |
| • កម្មវិធីថ្នាក់ឧត្តមសិក្សា | | |
| - ថ្នាក់បំប៉ន | ចំនួន១៤ថ្នាក់ | សរុបនិស្សិត ចំនួន ៣២៥ នាក់ ។ |
| - ថ្នាក់បរិញ្ញាបត្ររង | ចំនួន០៥ថ្នាក់ | សរុបនិស្សិត ចំនួន ៨៨ នាក់ ។ |
| - ថ្នាក់បរិញ្ញាបត្រ | ចំនួន១៤ថ្នាក់ | សរុបនិស្សិត ចំនួន ៣២២ នាក់ ។ |
| • វគ្គសិក្សាភាសាអង់គ្លេសកម្រិតទូទៅ | ចំនួន៣០ថ្នាក់ | សរុបសិក្ខាកាម ចំនួន ២៨០នាក់ ។ |

## យុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០១៧ និងឆ្នាំបន្តបន្ទាប់

- បន្តផ្តោតទៅលើការវិនិយោគលើធនធានមនុស្ស តាមរយៈការកសាងសមត្ថភាពបន្ថែម ដល់ថ្នាក់គ្រប់គ្រង សាស្ត្រាចារ្យ និងបុគ្គលិកជំនាញដែលពាក់ព័ន្ធ ទាំងចំណេះដឹងជំនាញ និងចំណេះដឹងភាសាយាន ដើម្បីឱ្យធនធានមនុស្សរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា បំពេញការងារប្រកបដោយភាពជំនាញវិជ្ជាជីវៈ គុណភាព ប្រសិទ្ធភាព និងផលិតភាពការងារខ្ពស់ ធានាបាននូវបណ្តល់សេវាកម្មអប់រំ បណ្តុះបណ្តាល ប្រកបដោយ គុណភាពខ្ពស់បំផុត ។
- សិក្សានិងសហការជាមួយម្ចាស់ក្រុមហ៊ុនឬសហគ្រាសជាប្រចាំដើម្បីស្វែងយល់ និងរកឱ្យឃើញអំពីតម្រូវការជាក់ស្តែងនៅក្នុងទីផ្សារការងារ ។ កម្មវិធីសិក្សា មានរួមបញ្ចូលនូវមុខវិជ្ជាជំនាញមួយចំនួនដែលចាំបាច់សម្រាប់ការអនុវត្តជាក់ស្តែង និងផ្អែកទៅលើការស្រាវជ្រាវ និងការពិនិត្យតាមដានលើតម្រូវការរបស់ម្ចាស់ក្រុមហ៊ុន ឬសហគ្រាស និងនិន្នាការរបស់ទីផ្សារការងារ ។
- បន្តធ្វើការបណ្តុះបណ្តាលបំពាក់បំប៉នវិធីសាស្ត្រ និងបច្ចេកទេសក្នុងការបង្រៀនជាប្រចាំដល់គ្រូហ្វឹកហ្វឺន និងសាស្ត្រាចារ្យទាំងអស់ ដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធភាពនៃការផ្ទេរ និងការទទួលចំណេះដឹង ជំនាញ បទពិសោធន៍ និងរួមចំណែកដល់ការធ្វើឱ្យកាន់តែប្រសើរឡើងនូវអាកប្បកិរិយាជាវិជ្ជមានរបស់សិក្ខាកាម និងនិស្សិត ។
- បន្តពង្រីកបណ្តាញសិក្សាដ៏រឹងមាំ ក្នុងភាពជាដៃគូ និងកម្មវិធីផ្លាស់ប្តូរសាស្ត្រាចារ្យ...ជាមួយគ្រឹះស្ថានដែលមានកេរ្តិ៍ឈ្មោះល្បី ដើម្បីអភិវឌ្ឍន៍ខ្លួនឱ្យក្លាយជាមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលថ្នាក់តំបន់ សម្រាប់វិស័យហិរញ្ញវត្ថុ និងធនាគារ ។
- បង្កើតមជ្ឈមណ្ឌលសម្រាប់គរុកោសល្យនវានុវត្តន៍ ដើម្បី(១)-ផ្តល់ការគាំពារដល់គ្រូបង្រៀនក្នុងគោលដៅធ្វើឱ្យប្រសើរឡើងនូវភាពវិជ្ជាជីវៈនៃការបង្ហាត់បង្រៀនការរៀនសូត្រនិងវង្វាយតម្លៃ (២)-ផ្តល់វេទិកាសម្រាប់ការពិគ្រោះយោបល់លើកម្មវិធីសិក្សាសម្រាប់កម្មវិធីថ្មី និងការកែលម្អកម្មវិធីដែលមានស្រាប់និង (៣)-បង្កើតលក្ខខណ្ឌអំណោយផល និងលើកកម្ពស់កិច្ចការស្រាវជ្រាវក្នុងការបង្ហាត់បង្រៀន ការរៀនសូត្រនិងវង្វាយតម្លៃ ។
- អភិវឌ្ឍន៍សេវាកម្មហ្វឹកហ្វឺនថ្មីៗបន្ថែម និងបង្កើនការលក់សេវាអប់រំបណ្តុះបណ្តាលដល់អតិថិជនខាងក្រៅ និងនិស្សិត ដើម្បីទទួលបាននូវអត្រាប្រាក់ចំណូលដែលមានប្រភពមកពីខាងក្រៅ រួមនឹងចំណូលផ្សេងៗ ធៀបនឹងចំណូលដុលធំជាង ៤៤% ។
- បង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយ កាត់បន្ថយនូវចំណាយមិនចាំបាច់តាមរយៈការសន្សំសំចៃការប្រើប្រាស់ឧបករណ៍ និងសម្ភារទូទៅ ដើម្បីរក្សាបាននូវអនុបាតប្រសិទ្ធភាពប្រតិបត្តិការឱ្យនៅទាបជាង ៤៩% ។

ជាចុងបញ្ចប់ យើងខ្ញុំសូមសម្តែងនូវគារវកិច្ច និងកតញ្ញូយ៉ាងជ្រាលជ្រៅចំពោះសិស្ស-និស្សិត អាណាព្យាបាល អតិថិជនដ៏ឆ្លាតវៃ ក្រុមហ៊ុនមេ ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាយោបល់ ថ្នាក់គ្រប់គ្រង សាស្ត្រាចារ្យ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ ព្រមទាំងដៃគូជាតិ និងអន្តរជាតិ និងជាពិសេសរាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់ទំនុកចិត្ត និងផ្តល់ការគាំទ្រយ៉ាងកក់ក្តៅដល់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ក្នុងបេសកកម្មអប់រំបណ្តុះបណ្តាលធនធានមនុស្សកន្លងមក ។

យើងខ្ញុំសូមបួងសួងឱ្យលោកអ្នក និងក្រុមគ្រួសារទទួលបាននូវសេចក្តីសុខកាយ សប្បាយចិត្ត ចម្រើនដោយប្រយោជន៍ ជោគជ័យក្នុងនាទីការងារ និងមុខជំនួញប្រកបដោយគុណភាព និងប្រសិទ្ធភាពដ៏ឧត្តុង្គឧត្តម កុំបីឃ្លៀងឃ្លាតឡើយ ។




លោក ឆន ពន្លឺ

*នាយកវិទ្យាស្ថាន*

ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧

# អង្គការលេខ


ក្រុមប្រឹក្សាភិបាល
ក្រុមប្រឹក្សាសិក្សាធិការ
នាយក-នាយិកា
ក្រុមប្រឹក្សាវិន័យ
គណៈកម្មាធិការប្រតិបត្តិ
ទីប្រឹក្សា
គណៈកម្មាធិការ អភិវឌ្ឍន៍វិសោធនកម្ម
គណៈកម្មាធិការ គ្រប់គ្រងហានិភ័យ
គណៈកម្មាធិការ កំណត់ថ្លៃ
គណៈកម្មាធិការស្រាវជ្រាវ និងអភិវឌ្ឍន៍កម្មវិធីសិក្សា
នាយក-នាយិការង
ប្រធានការិយាល័យ ទំនាក់ទំនងសាធារណៈ
ប្រធានការិយាល័យ ផែនការ និងហិរញ្ញវត្ថុ
ប្រធានការិយាល័យ បុគ្គលិក និងរដ្ឋបាល
ប្រធានមជ្ឈមណ្ឌល ហ្វឹកហ្វឺន
ប្រធានការិយាល័យសិក្សា និងកិច្ចការនិស្សិត
ប្រធានដេប៉ាតឺម៉ង់ គ្រប់គ្រងពាណិជ្ជកម្ម
ប្រធានផ្នែក ធានាគុណភាពផ្ទៃក្នុង
ប្រធានផ្នែក ទីផ្សារ
ប្រធានផ្នែក ទំនាក់ទំនង និងសហប្រតិបត្តិការ
ប្រធានផ្នែក គណនេយ្យ
ប្រធានផ្នែក ផែនការថវិកា
ភ្នាក់ងារ គ្រប់គ្រងហានិភ័យ
ប្រធានផ្នែក បុគ្គលិក និងរដ្ឋបាល
ភ្នាក់ងារ បច្ចេកវិទ្យាព័ត៌មាន
ប្រធានផ្នែក ហ្វឹកហ្វឺន
ប្រធានផ្នែក អភិវឌ្ឍន៍ការហ្វឹកហ្វឺន
សាស្ត្រាចារ្យ ជាន់ខ្ពស់
ប្រធានផ្នែក គាំទ្រការសិក្សា និង កិច្ចការនិស្សិត
ប្រធានផ្នែក វិសោធនកម្ម
ប្រធានផ្នែក ចុះឈ្មោះ និងបញ្ជិកា
ប្រធានផ្នែក គ្រប់គ្រងបណ្ណាល័យ
ប្រធានផ្នែក ស្រាវជ្រាវ និងអភិវឌ្ឍន៍ កម្មវិធីសិក្សា
កម្មវិធី ថ្នាក់ត្រៀម
កម្មវិធី ថ្នាក់បរិញ្ញាបត្ររង (ហិរញ្ញវត្ថុ និងធនាគារ)
កម្មវិធី ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ (ហិរញ្ញវត្ថុ និងធនាគារ)
កម្មវិធី ថ្នាក់បរិញ្ញាបត្រ (ហិរញ្ញវត្ថុ និងធនាគារ)
ប្រធានផ្នែក សវនកម្មផ្ទៃក្នុង

# ភាគទុនិក

វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ជាសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីពាណិជ្ជកម្ម ដោយគោរពទៅតាមច្បាប់នៃ ព្រះរាជាណាចក្រកម្ពុជា ។ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានការិយាល័យ ស្ថិតនៅអគារលេខ៥០ ផ្លូវលេខ៥១៦ កែង៣៣៥ ភូមិ៦ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ និងមានភាគទុនិក កាន់កាប់ភាគហ៊ុន ១០០ ភាគរយ ដោយធនាគារ អេស៊ីលីដា ភីអិលស៊ី ជាក្រុមហ៊ុនមេ តំណាងដោយ លោកបណ្ឌិត អ៊ិន ចាន់នី ។

ភាគទុនិក គឺជាម្ចាស់របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។ ភាគទុនិកមានសិទ្ធិអនុម័តលើយុទ្ធសាស្ត្រនានា ប៉ុន្តែភាគទុនិក ពុំមានសិទ្ធិអំណាចគ្រប់គ្រងផ្ទាល់លើការងារទាំងអស់នេះទេ ទោះបីជា យ៉ាងណាក៏ដោយ ភាគទុនិកអាចផ្ទេរការទទួលបន្ទុកទាំងនេះ ទៅឱ្យក្រុមប្រឹក្សាភិបាល តាមរយៈអនុស្សរណៈ និងលក្ខន្តិកៈ របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។



**បណ្ឌិត អ៊ិន ចាន់នី**

តំណាងភាគទុនិក

ជនជាតិខ្មែរ កើតក្នុងខែមិថុនា ឆ្នាំ១៩៦០ ។ បណ្ឌិត អ៊ិន ចាន់នី ជាប្រធាននាយកប្រតិបត្តិ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំងពីធនាគារបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០ ។ លោកបណ្ឌិតបានចូលរួមក្នុងក្រុមប្រឹក្សាភិបាល របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែកញ្ញា ឆ្នាំ២០១៤ ។ បណ្ឌិត អ៊ិន ចាន់នី ជាសហស្ថាបនិករបស់សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (អេស៊ីលីដា) តាំងពីខែមករា ឆ្នាំ១៩៩៣ ។ ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ លោកបណ្ឌិតជាអ្នកដឹកនាំ គណៈកម្មាធិការប្រតិបត្តិ ទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្ររួម និងដំណើរការងារអាជីវកម្មប្រចាំថ្ងៃ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ព្រមទាំងប្រតិបត្តិផែនការអាជីវកម្ម ។ លោកបណ្ឌិតទទួលខុសត្រូវផ្ទាល់ ចំពោះក្រុមប្រឹក្សាភិបាល ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកបណ្ឌិត រួមមាន ជាប្រធានក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ឡាវ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ព្រមទាំងជាតំណាងភាគទុនិករបស់ ធនាគារ អេស៊ីលីដា ឡាវ, អេស៊ីលីដា ស៊ីយូរីធី ភីអិលស៊ី, វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា, ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា, និងអេស៊ីលីដា ប្រូភើធី អិលធីឌី ។ លោកបណ្ឌិតក៏ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ ។

ក្រៅពីមុខងារ និងតួនាទីនៅក្នុងអេស៊ីលីដា លោកបណ្ឌិតគឺជាប្រធានសមាគមពាណិជ្ជកម្មនិងវិនិយោគកម្ពុជា-ជប៉ុន (ស.ព.វ.ក.ជ) និងសមាជិកអនុគណៈកម្មាធិការរាជរដ្ឋាភិបាល សម្រាប់អភិបាលកិច្ចសាជីវកម្ម ។ លោកបណ្ឌិតជាអ្នកតំណាងរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាសមាជិករបស់វេទិកាសេដ្ឋកិច្ចពិភពលោក ។

នៅក្នុងឆ្នាំ១៩៩៨ លោកបានបញ្ចប់វគ្គគ្រប់គ្រងស្តីពីស្ថាប័នហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍សហគ្រាសឯកជន (FIPED) ពីសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម និងបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុនពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។

## ធនាគារ អេស៊ីលីដា ភីអិលស៊ី

ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានបង្កើតឡើង តាមប្រព័ន្ធច្បាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ។ ធនាគារ អេស៊ីលីដា បានចាប់បដិសន្ធិឡើងនៅក្នុងខែមករា ឆ្នាំ១៩៩៣ ក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលមានទិសដៅអភិវឌ្ឍន៍មុខរបរខ្នាតតូចបំផុត និងខ្នាតតូច តាមរយៈការផ្តល់ឥណទាន ។

នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០០ ធនាគារ អេស៊ីលីដា បានទទួលអាជ្ញាប័ណ្ណជាធនាគារឯកទេសពីធនាគារជាតិនៃកម្ពុជា ។ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារ អេស៊ីលីដា បានទទួលអាជ្ញាប័ណ្ណជាធនាគារពាណិជ្ជពីធនាគារជាតិនៃកម្ពុជា ដែលធ្វើឱ្យធនាគារ អេស៊ីលីដា មានលទ្ធភាពបំពេញទៅតាមតម្រូវការរបស់អតិថិជននូវសេវាធនាគារបានទូទៅ និងទូលំទូលាយថែមទៀត ហើយក៏បានប្តូរឈ្មោះជាផ្លូវការមកជា "ធនាគារ អេស៊ីលីដា ភីអិលស៊ី" ។

នៅចុងខែធ្នូ ឆ្នាំ២០១៦ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានបណ្តាញប្រតិបត្តិការ ចំនួន ២៥៩ សាខា កម្មករនិយោជិតចំនួន ១២.៣២៥ នាក់ និងមានទ្រព្យសកម្មសរុបចំនួន ៤.៥៦១,០២ លានដុល្លារអាមេរិក ។

ព័ត៌មានបន្ថែមសូមចូលទស្សនាគេហទំព័រ: www.acledabank.com.kh



លោកប្រធាននាយកប្រតិបត្តិ ធនាគារ អេស៊ីលីដា ភីអិលស៊ី ចែករំលែកបទពិសោធន៍រីកចម្រើន ដល់សិក្ខាកាមមកពីប្រទេសប៉ាគីស្ថាន

# ក្រុមប្រឹក្សាភិបាល

សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយតំណាងភាគទុនិក សម្រាប់អាណត្តិបី(៣)ឆ្នាំ ដើម្បីធ្វើសកម្មភាពតំណាងឱ្យភាគទុនិក ។ តាមលក្ខន្តិកៈបានបញ្ជាក់ថាសមាសភាពក្រុមប្រឹក្សាភិបាល ត្រូវមានយ៉ាងតិចបី(៣)រូប និង ៖

- ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវកំណត់យុទ្ធសាស្ត្ររបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និងដឹកនាំត្រួតពិនិត្យ ដំណើរការកិច្ចការអាជីវកម្ម ។ សមាជិក-សមាជិកា ក្រុមប្រឹក្សាភិបាល ត្រូវធ្វើកិច្ចការណាដែលផ្ដល់ផលប្រយោជន៍ខ្ពស់បំផុតដល់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។
- អំណាចរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តរួមគ្នា ហើយគ្មានសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលណាម្នាក់ មានអំណាចចាត់ចែងមន្ត្រី ឬនិយោជិតរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចុះហត្ថលេខាលើកិច្ចសន្យាណាមួយ ឬចាត់ចែងប្រតិបត្តិការរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា លុះត្រាតែបានទទួលអំណាចពិសេស ដើម្បីចាត់ចែងទៅតាមសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។
- សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលម្នាក់ៗ អាចពិនិត្យមើលដោយគ្មានកម្រិតនូវបញ្ជី ឬរបាយការណ៍របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅក្នុងពេលម៉ោងធ្វើការធម្មតា ។

ក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវជ្រើសតាំងក្នុងចំណោមសមាជិក-សមាជិការបស់ខ្លួនមួយ(១)រូប ដើម្បីធ្វើជាប្រធានដោយសម្លេងឆ្នោតគាំទ្រភាគច្រើន ។ ប្រធានក្រុមប្រឹក្សាភិបាលជាអ្នកដឹកនាំរាល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ។ សម្លេងឆ្នោតគាំទ្រភាគច្រើន នៃសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ដែលកំពុងបម្រើការងារនៅការិយាល័យ អាចផ្លាស់ប្ដូរប្រធានក្រុមប្រឹក្សាភិបាលបាន ប៉ុន្តែមិនអាចដកហូតតួនាទីជាសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលបានឡើយ ។

សមាជិក-សមាជិកាក្រុមប្រឹក្សាណាម្នាក់ ដែលមានផលប្រយោជន៍ហិរញ្ញវត្ថុទោះផ្ទាល់ ឬដោយប្រយោលក៏ដោយ ឬបើមានសមាជិកក្រុមគ្រួសារផ្ទាល់មានផលប្រយោជន៍បែបនេះ មុនពេលក្រុមប្រឹក្សាភិបាលធ្វើការសម្រេចលើសំណើណាក៏ដោយ សមាជិក-សមាជិកាក្រុមប្រឹក្សារូបនោះ ត្រូវតែជម្រាបសមាជិក-សមាជិកាក្រុមប្រឹក្សាដទៃទៀត ពីផលប្រយោជន៍នោះ មុនពេលអង្គប្រជុំក្រុមប្រឹក្សាភិបាលធ្វើការអនុម័ត ហើយសមាជិក-សមាជិកាក្រុមប្រឹក្សារូបនោះ មិនត្រូវចូលរួមពិភាក្សាលើសំណើនោះទេ លុះត្រាណាតែតម្រូវឱ្យចូលរួមពិភាក្សាដោយមានសម្លេងឆ្នោតគាំទ្រភាគច្រើន ពីសមាជិក-សមាជិកាក្រុមប្រឹក្សាដទៃទៀត ដែលចូលរួមក្នុងអង្គប្រជុំនោះ ។ សមាជិក-សមាជិកាក្រុមប្រឹក្សារូបនោះ មិនត្រូវបោះឆ្នោតលើករណីបែបនោះទេ ប៉ុន្តែវត្តមានរបស់សមាជិក-សមាជិកាក្រុមប្រឹក្សារូបនោះអាចរាប់បញ្ចូលក្នុងកូរ៉ុមនៃអង្គប្រជុំ ។

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវលើអភិបាលកិច្ចសាជីវកម្ម និងការជំរុញអភិវឌ្ឍន៍ជោគជ័យរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។ ក្រុមប្រឹក្សាភិបាលជាអ្នកតែងតាំងនាយកវិទ្យាស្ថាន សម្រាប់ដឹកនាំកិច្ចការវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និងអាចដកតំណែង នាយកវិទ្យាស្ថានវិញបាន ។

ក្រុមប្រឹក្សាភិបាលអាចបង្កើតគណៈកម្មាធិការនានា ដែលយល់ថាចាំបាច់ក្នុងការដឹកនាំកិច្ចការជំនួញ និងប្រតិបត្តិការរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។ គណៈកម្មាធិការទាំងនេះ បង្កើតឡើងតាមឆន្ទៈរបស់ក្រុមប្រឹក្សាភិបាល ហើយសមាជិក-សមាជិកាទាំងអស់ នៃ គណៈកម្មាធិការទាំងនេះ ត្រូវតែអនុវត្តទៅតាមឆន្ទៈរបស់ ក្រុមប្រឹក្សាភិបាល ។



ក្រុមប្រឹក្សាភិបាល វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា



## បណ្ឌិត ស៊ូ ផនណារី

ប្រធានក្រុមប្រឹក្សាភិបាល

ជនជាតិខ្មែរ កើតក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៣ ។ លោកស្រីបានបញ្ចប់ថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងធុរកិច្ច និងចូលបម្រើការនៅអេស៊ីលីដា ចាប់តាំងពីខែសីហា ឆ្នាំ១៩៩៣។ លោកស្រីបណ្ឌិតបានក្លាយជាប្រធានក្រុមប្រឹក្សាភិបាលរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅក្នុងខែមករា ឆ្នាំ២០១៦។

ក្នុងមុខតំណែងជា អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ នៃធនាគារ អេស៊ីលីដា ភីអិលស៊ី លោកស្រីបណ្ឌិតក៏ជា សមាជិកាគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកដឹកនាំលើប្រតិបត្តិការរបស់ធនាគារ និងគ្រប់គ្រងនាយកដ្ឋានប្រតិបត្តិការ, នាយកដ្ឋានហិរញ្ញប្បទានពាណិជ្ជកម្ម, នាយកដ្ឋានទីផ្សារ, នាយកដ្ឋានអភិវឌ្ឍន៍ផលិតផល, នាយកដ្ឋានឥណទាន, នាយកដ្ឋានសេវាឥណទាន, និងនាយកដ្ឋានសេវាហិរញ្ញវត្ថុ។ លោកស្រីបណ្ឌិតទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រនិងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ដោយផ្តោតទៅលើផែនការយុទ្ធសាស្ត្រលក់ផលិតផល និងសេវាកម្មដែលមានស្រាប់ និងថ្មីៗ ។ លោកស្រីបណ្ឌិតទទួលខុសត្រូវទៅលើ ការដឹកនាំត្រួតពិនិត្យនិងវាយតម្លៃលើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ។ លើសពីនេះ លោកស្រីបណ្ឌិត ក៏ជាសមាជិកាគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងបំណុល, គណៈកម្មាធិការកំណត់ថ្លៃផលិតផល និងសេវាកម្ម, និងគណៈកម្មាធិការឥណទាននៃថ្នាក់គ្រប់គ្រង ។ លោកស្រីបណ្ឌិត ទទួលខុសត្រូវចំពោះប្រធាននាយកប្រតិបត្តិ។ ទំនួលខុសត្រូវផ្សេងទៀតរបស់លោកស្រីបណ្ឌិត ជាក្រុមប្រឹក្សាភិបាលរបស់ អេស៊ីលីដា ត្រេននីង សេនធ័រ នៅខែសីហា ឆ្នាំ២០១១ និងក្លាយជាប្រធានក្រុមប្រឹក្សាភិបាល ចាប់ពីខែមេសា ឆ្នាំ២០១៣។

លោកស្រីបានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន។



## លោក ព្រំ វិសុទ្ធ

អភិបាល

ជនជាតិខ្មែរ កើតក្នុងខែមករា ឆ្នាំ១៩៧៥ ។ លោក ព្រំ វិសុទ្ធ បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅខែមករា ឆ្នាំ២០១៦។ លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី នៅ២០០៦។

លោក បានចូលបម្រើការនៅអេស៊ីលីដាចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៨ ។ ក្នុងមុខតំណែងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុនរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី លោកក៏ជាសមាជិកគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្ររួមនិងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ដោយអនុលោមទៅតាមបទបញ្ញត្តិ ព្រមទាំងទំនាក់ទំនងជាមួយ ភាគទុនិក និងក្រុមប្រឹក្សាភិបាល ។ លោកជាសមាជិកគណៈកម្មាធិការឥណទាននៃថ្នាក់គ្រប់គ្រងដែលទទួលបន្ទុកគ្រប់គ្រងលើនាយកដ្ឋាននីតិកម្ម, ការិយាល័យគ្រប់គ្រងវិវាទ, ការិយាល័យប្រឹក្សាបុត្រសម្ព័ន្ធ, និងការិយាល័យលេខាធិការក្រុមហ៊ុន។ លោកទទួលខុសត្រូវដោយផ្ទាល់ ចំពោះប្រធាននាយកប្រតិបត្តិ។ ទំនួលខុសត្រូវផ្សេងទៀត របស់លោករួមមាន ៖ ជាសមាជិកក្រុមប្រឹក្សាភិបាល អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ចាប់ពីឆ្នាំ២០១០ អេស៊ីលីដា ត្រេននីង សេនធ័រ ចាប់ពីឆ្នាំ២០១១ និងអេស៊ីលីដា ប្រូភើធី អិលធីឌី ចាប់តាំងពីឆ្នាំ២០១៦ ។

លោកបានបញ្ចប់ការសិក្សា ពីកម្មវិធីជំនាញលេខាធិការក្រុមហ៊ុន និងបានបញ្ចប់ការសិក្សាពី វិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន។



## បណ្ឌិត អ៊ុង សំអុល

អភិបាល

ជនជាតិខ្មែរ កើតឆ្នាំ១៩៦៣ លោកបណ្ឌិត អ៊ុង សំអុល បានចូលជាក្រុមប្រឹក្សាភិបាលរបស់វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅក្នុង ខែមករា ឆ្នាំ២០១៦។ លោកបានទទួល សញ្ញាបត្របណ្ឌិតស្រាវជ្រាវឯកទេសសេដ្ឋកិច្ច នៅសាកលវិទ្យាល័យបៀលប្រាយ រាជធានីភ្នំពេញក្នុងឆ្នាំ២០១៣ ។ លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្ម ជំនាញគណនេយ្យនិងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យបៀលប្រាយ រាជធានីភ្នំពេញ ក្នុងឆ្នាំ២០០៥។លោកបានបញ្ចប់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញធនាគារ និងហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យន័រតុន រាជធានីភ្នំពេញ ក្នុងឆ្នាំ២០០១។ លោកបានទទួលសញ្ញាបត្រ គណនេយ្យ និងហិរញ្ញវត្ថុ នៅមហាវិទ្យាល័យ ពាណិជ្ជសាស្ត្រភ្នំពេញ ក្នុងឆ្នាំ១៩៨៨។

លោកបានចាប់ផ្តើមបម្រើការងារឱ្យ អេស៊ីលីដា ក្នុងតួនាទីជាគណនេយ្យករ នៅខែមករា ឆ្នាំ១៩៩៨ បន្ទាប់មកត្រូវបានតែងតាំងជាប្រធានផ្នែកត្រួតពិនិត្យឥណទាននៅក្នុងឆ្នាំ១៩៩៩។ លោកបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្នែកគ្រប់គ្រង និងគណនេយ្យជាច្រើន នៅក្នុងប្រទេសកម្ពុជា។ នៅឆ្នាំ២០០១ លោកត្រូវបានតែងតាំងជានាយកធនាគារ អេស៊ីលីដា សាខាខេត្តកំពង់ធំ ជានាយករងនាយកដ្ឋានប្រតិបត្តិការនៅការិយាល័យកណ្តាល ក្នុងឆ្នាំ២០០៤ ជានាយកនៃនាយកដ្ឋានហិរញ្ញប្បទានពាណិជ្ជកម្ម នៅខែមករា ឆ្នាំ២០០៦ និងជានាយកប្រតិបត្តិហិរញ្ញប្បទានពាណិជ្ជកម្ម ចាប់ពីខែកក្កដា ឆ្នាំ២០០៦។ លោកបណ្ឌិត អ៊ុង សំអុល បានចាត់តាំងជាសមាជិកក្រុមប្រឹក្សាភិបាល អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ីក្នុងខែមីនា ឆ្នាំ២០១១ និងត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាល អេស៊ីលីដា ត្រេននីង សេនធ័រ ក្នុងខែសីហា ឆ្នាំ២០១៣។



## លោក Pieter Kooi

អភិបាល

ជនជាតិហុល្លង់ដ៍ កើតក្នុងឆ្នាំ១៩៥៨ បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅក្នុងខែមករា ឆ្នាំ២០១៦ និងត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការសវនកម្ម សីលធម៌ និងសម្របសម្រួលកិច្ចការច្បាប់ នៃក្រុមប្រឹក្សាភិបាលនៅក្នុងខែកញ្ញា ឆ្នាំ២០១៦។ លោកទទួលបាន អនុបណ្ឌិតផ្នែកហិរញ្ញវត្ថុសាជីវកម្ម និងសង្គមវិទ្យា នៅសាកលវិទ្យាល័យ Erasmus ក្នុងទីក្រុង Rotterdam ប្រទេសហុល្លង់ដ៍ ។ ចាប់ពីឆ្នាំ១៩៩៣ លោកបានធ្វើជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុឱ្យអេស៊ីលីដា រយៈពេលជាង ៧ឆ្នាំ ដើម្បីកម្លាយខ្លួនពីកម្មវិធីអភិវឌ្ឍន៍ទៅជាធនាគារពាណិជ្ជ ។ ចាប់ពីឆ្នាំ១៩៩៩ បណ្ឌិត Pieter KOOI បានបម្រើការងារជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុ រយៈពេលខ្លី ដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុ នៅក្នុង ១៥ប្រទេស ដែលភាគច្រើនស្ថិតក្នុងទ្វីបអាហ្វ្រិក និងអាស៊ី ។

បណ្ឌិត Pieter KOOI បានចូលជាក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងខែតុលា ឆ្នាំ២០០០។ ចាប់ពីខែកញ្ញា ឆ្នាំ២០០២ ដល់ខែធ្នូ ឆ្នាំ២០០៥ លោកមានតួនាទីជានាយកផ្នែកមីក្រូហិរញ្ញវត្ថុ របស់ UNCDF ក្នុងទីក្រុងញូវយ៉ក ។ ចាប់ពីខែមីនា ឆ្នាំ២០០៦ រហូតដល់ខែឧសភា ឆ្នាំ២០១១ លោកបានធ្វើជាទីប្រឹក្សាក្រៅម៉ោងឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងការបង្កើតធនាគារ អេស៊ីលីដា ឡាវ, អេស៊ីលីដា ត្រេននីង សេនធ័រ, និងអេស៊ីលីដា ស៊ីយូរីធី ។ បច្ចុប្បន្នលោកធ្វើជាក្រុមប្រឹក្សាភិបាលនៅក្នុងស្ថាប័នជាច្រើន និងផ្តល់ការប្រឹក្សារយៈពេលខ្លី ហើយថែមទាំងបង្ហាត់បង្រៀនអំពីមីក្រូហិរញ្ញវត្ថុ អភិបាលកិច្ច និងយុទ្ធសាស្ត្រគ្រប់គ្រង ។ លោកបានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន។



## លោក ឆន ពន្លឺ

អភិបាល

ជនជាតិខ្មែរកើតក្នុងឆ្នាំ១៩៧៨, លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មជំនាញគ្រប់គ្រងពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅក្នុងឆ្នាំ២០០៥ ។ នៅក្នុងឆ្នាំ១៩៩៩ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្មជំនាញទីផ្សារ ពីមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ដែលសហការកម្មវិធីសិក្សាជាមួយ University of San Francisco និង Georgetown University ។ លោកបានចូលបម្រើការជាមួយ អេស៊ីលីដា នៅក្នុង ខែវិច្ឆិកា ឆ្នាំ១៩៩៩ ។ ចាប់ពីឆ្នាំ២០០៣ មកលោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទៀត ទាំងនៅក្នុងប្រទេស និងពីបណ្តាប្រទេសមួយចំនួន ទាក់ទងនឹងការបណ្តុះបណ្តាលធនាគារនិងហិរញ្ញវត្ថុ, ការគ្រប់គ្រង និងអភិវឌ្ឍន៍កម្មវិធីបណ្តុះបណ្តាល។ លោកបានបំពេញទស្សនកិច្ចសិក្សា នៅសាកលវិទ្យាល័យមួយចំនួននៃកោះតៃវ៉ាន់, Harvard Business School នៃសហរដ្ឋអាមេរិក Frankfurt School of Finance and Management នៃប្រទេសអាល្លឺម៉ង់ លើប្រធានបទមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍខ្លួនទៅជាសាលាពាណិជ្ជសាស្ត្រខ្នាតអន្តរជាតិ។ នៅក្នុងឆ្នាំ២០១៦ លោកបានបញ្ចប់វគ្គបណ្តុះបណ្តាលខ្នាតអន្តរជាតិលើកទី៣៦ នៅប្រទេសអ៊ីស្រាអ៊ែល សម្រាប់ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សាដែលរៀបចំដោយវិទ្យាស្ថានគ្រប់គ្រងអន្តរជាតិកាលីឡេ ។

លោកបានទទួលមុខតំណែងជា អគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ ក្នុងឆ្នាំ២០១១ ។ នាពេលបច្ចុប្បន្ននេះ លោកមានតួនាទីជា នាយកវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។ លោកបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅខែតុលា ឆ្នាំ២០១៦ ។ ក្រៅពីនេះ លោកគឺជាតំណាងភាគទុនិក របស់អេស៊ីលីដា ត្រេននីង សេនធ័រ នៅក្នុងធនាគារ អេស៊ីលីដាឡាវ លីមីធីត ចាប់ពីឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ន ។



## បណ្ឌិត ឌី សមស៊ីដេត

អភិបាល

ជនជាតិខ្មែរ កើតក្នុងខែមករា ឆ្នាំ១៩៧១ ។ លោកបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតផ្នែកទស្សនវិជ្ជានៅក្នុងផ្នែកអប់រំនិងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យហ៊ីរ៉ូស៊ីម៉ា ប្រទេសជប៉ុននៅ ខែមីនា ឆ្នាំ២០០៥។ លោកបានចូលរួមជាក្រុម ប្រឹក្សាភិបាលនៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅខែមករា ឆ្នាំ២០១៦។ ហើយបានក្លាយទៅជាប្រធានកម្មាធិការកិច្ចការអប់រំចាប់ពីខែកញ្ញាឆ្នាំ២០១៦ ។ លោកមានបទពិសោធន៍ជាច្រើនឆ្នាំដែលទាក់ទងទៅនិងការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។ លោកមានបទពិសោធន៍ជាង១០ឆ្នាំក្នុងការបង្រៀន និងការស្រាវជ្រាវគោលនយោបាយនិងផែនការអប់រំ ការប្រៀបធៀបការសិក្សាភាពជាអ្នកដឹកនាំនិងវគ្គសិក្សាទំនាក់ទំនងឲ្យមានប្រសិទ្ធភាពរបស់កម្មវិធីសាកលវិទ្យាល័យប្រទេសជប៉ុន និងប្រទេសកម្ពុជា។ ចាប់ពីឆ្នាំ២០១២ដល់២០១៥ គាត់គឺជានាយកនៃកម្មវិធីសិក្សាក្រោយបរិញ្ញាបត្រ និងជាព្រឹទ្ធបុរសនៃមហាវិទ្យាល័យអប់រំ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។ លោកបានផ្តល់សេវាកម្មពិគ្រោះយោបល់ដល់កម្មវិធីនានា និងគម្រោងនៃការអភិវឌ្ឍនិងភ្នាក់ងារស្រាវជ្រាវដូចជា៖ CDRI, ADB, OECD, SEAMEO, SDC, GIZ និងUNESCO ចាប់តាំងពីឆ្នាំ២០១០ នៅក្នុងប្រទេសកម្ពុជា ប្រទេសមីយ៉ាន់ម៉ា និងប្រទេសឥណ្ឌូនេស៊ី ។

បច្ចុប្បន្ននេះលោកបានក្លាយជាអគ្គនាយករងសម្រាប់ការអប់រំ ក្នុងក្រសួងអប់រំយុវជននិងកីឡា ទទួលបន្ទុកកំណែទម្រង់របស់គ្រូបង្រៀន ។

# គណៈកម្មាធិការប្រតិបត្តិ

នាយកវិទ្យាស្ថាន ត្រូវបានតែងតាំងឡើងដោយ ក្រុមប្រឹក្សាភិបាល ដើម្បី ទទួលខុសត្រូវលើការគ្រប់គ្រងដំណើរការអាជីវកម្មប្រចាំថ្ងៃ របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅក្នុងរង្វង់គោលការណ៍ និង យុទ្ធសាស្ត្រ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ។ ប៉ុន្តែកិច្ចការជាក់លាក់មួយចំនួន អាចត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

នាយកវិទ្យាស្ថាន ជាអ្នកតែងតាំង និងដឹកនាំគណៈកម្មាធិការប្រតិបត្តិ ដែលរួមមានសមាសភាពនៃថ្នាក់ដឹកនាំជាន់ខ្ពស់ ដោយលោកយល់ឃើញថាសមស្រប (ករណីមានការផ្លាស់ប្តូរណាមួយ ត្រូវជូនដំណឹងទៅ ក្រុមប្រឹក្សាភិបាល ឱ្យបានទាន់ពេលសមស្រប) ។ ភារកិច្ចទទួលខុសត្រូវ និងដំណើរការនៃគណៈកម្មាធិការប្រតិបត្តិ នឹងត្រូវកំណត់ដោយនាយកវិទ្យាស្ថាន តាមការសម្រេចក្រោមចំណុចសំខាន់ៗ ទូទៅដូចជា ៖

- ទិសដៅយុទ្ធសាស្ត្រ៖ អភិវឌ្ឍន៍គោលការណ៍ គោលដៅយុទ្ធសាស្ត្រ និងទិសដៅ សម្រាប់ក្រុមប្រឹក្សាភិបាលអនុម័ត ។
- ការអនុវត្ត ៖ ប្រមូលផ្តុំនូវរាល់ធនធាន ដើម្បីអនុវត្តតាមយុទ្ធសាស្ត្រ ដែលបានកំណត់ និងការប្រតិបត្តិតាមគោលដៅ ដែលបានអនុម័ត ។
- ហានិភ័យ ៖ កំណត់ និងវាយតម្លៃលើហានិភ័យ នៅក្នុងយុទ្ធសាស្ត្ររបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និងចាត់ចែងបញ្ហាដែលកើតឡើង ។
- ការប្រតិបត្តិ ៖ ធានាថា វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ប្រតិបត្តិ អនុលោមទៅតាមតម្រូវការរបស់ សាជីវកម្ម ច្បាប់ និងបទប្បញ្ញត្តិទាំងអស់ ។



**លោក ឆន ពន្លឺ**

នាយកវិទ្យាស្ថាន

ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៧៨, លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅក្នុងឆ្នាំ២០០៥ ។ នៅក្នុងឆ្នាំ១៩៩៩ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញទីផ្សារ ពីមហាវិទ្យាល័យពាណិជ្ជសាស្ត្រ ដែលសហការកម្មវិធីសិក្សាជាមួយ University of San Francisco និង Georgetown University ។

ចាប់ពីឆ្នាំ២០០៣ មកលោកបានបំពេញទស្សនកិច្ច និងចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន ទាំងនៅក្នុងប្រទេសនិងពីបណ្តាប្រទេសមួយចំនួន ទាក់ទងនឹងការបណ្តុះបណ្តាលធនាគារនិងហិរញ្ញវត្ថុ, ការគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាល, វគ្គបណ្តុះបណ្តាលជំនាញរៀបចំនិងអភិវឌ្ឍន៍កម្មវិធីសិក្សា, វគ្គបណ្តុះបណ្តាលគ្រូហ្វឹកហ្វឺន, វគ្គប្រឹក្សាយោបល់បែបវិជ្ជាជីវៈ និងវគ្គបណ្តុះបណ្តាលជាច្រើនផ្សេងទៀត។ លោកបានបំពេញទស្សនកិច្ចសិក្សានៅសាកលវិទ្យាល័យមួយចំនួន នៃកោះតៃវ៉ាន់, Harvard Business School នៃសហរដ្ឋអាមេរិក Frankfurt School of Finance and Management នៃប្រទេសអាល្លឺម៉ង់ លើប្រធានបទមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍខ្លួនទៅជាសាលាពាណិជ្ជសាស្ត្រខ្នាតអន្តរជាតិ។ នៅក្នុងឆ្នាំ២០១៦ លោកបានបញ្ចប់វគ្គបណ្តុះបណ្តាលខ្នាតអន្តរជាតិលើកទី៣៦ នៅប្រទេសអ៊ីស្រាអ៊ែលសម្រាប់ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ដែលរៀបចំដោយវិទ្យាស្ថានគ្រប់គ្រងអន្តរជាតិកាលីឡេ ។

លោកបានចូលបម្រើការជាមួយ អេស៊ីលីដា មីក្រូហិរញ្ញវត្ថុ នៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៩ ក្នុងមុខតំណែងជាគណនេយ្យករ និងត្រូវបានដំឡើងមុខងារតួនាទីទៅជា ប្រធានគណនេយ្យករសាខា នៅក្នុងខែកុម្ភៈ ឆ្នាំ២០០០។ ជាបន្តនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៥ លោកត្រូវបានផ្លាស់ប្តូរមុខងារតួនាទីទៅជា ប្រធានទីផ្សារសាខា និងត្រូវបានដំឡើងមុខងារតួនាទីជា នាយកសាខា ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងឆ្នាំ២០០៧ និងត្រូវ បានផ្លាស់ប្តូរមុខតំណែងជា នាយកការិយាល័យបណ្តុះបណ្តាលមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា-អាស៊ាន នៅក្នុងឆ្នាំ២០០៩។ នាខែសីហា ឆ្នាំ២០១១ លោកបានទទួលមុខតំណែងជាអគ្គនាយក អេស៊ីលីដា ត្រេននីង សេនធ័រ ។ នាពេលបច្ចុប្បន្ននេះ លោកមានតួនាទីជា នាយកវិទ្យាស្ថាន និងជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាភិបាល វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។ ក្រៅពីនេះ លោកគឺជា តំណាងភាគទុនិករបស់ អេស៊ីលីដា ត្រេននីង សេនធ័រ នៅក្នុងធនាគារ អេស៊ីលីដាឡាវ លីមីធីត ចាប់ពីឆ្នាំ ២០១៣ រហូតមកដល់បច្ចុប្បន្ន ។



**លោក ហុង ហោម្ហលី**
នាយករង និងជា
ប្រធានការិយាល័យផែនការ និងហិរញ្ញវត្ថុ

លោក ជាជនជាតិខ្មែរ កើតនៅឆ្នាំ១៩៨០ ក្នុងខេត្តកំពង់ឆ្នាំង។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅក្នុងឆ្នាំ២០០២ និងបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ ពីវិទ្យាស្ថានជាតិគ្រប់គ្រងនៅក្នុងឆ្នាំ២០០៣។ បច្ចុប្បន្ន លោកកំពុងបន្តសិក្សា ថ្នាក់គណនេយ្យជំនាញ ACCA ។ លោកធ្លាប់បានចូលរួមវគ្គហ្វឹកហ្វឺនជាច្រើន ទាក់ទងទៅនឹងវិស័យហិរញ្ញវត្ថុ និងធនាគារ ការគ្រប់គ្រងនិងដឹកនាំ វគ្គហ្វឹកហ្វឺនគ្រូបង្រៀន វគ្គសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ វគ្គស៊ើបអង្កេត និងការពារការក្លែងបន្លំ ។ល។

លោកបានចូលបម្រើការងារជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងឆ្នាំ២០០៣ ក្នុងមុខដំណែងជាគណនេយ្យករសាខា ហើយត្រូវបានដំឡើងមុខងារជាអនុប្រធានគណនេយ្យករសាខា នៅក្នុង ឆ្នាំ២០០៥ ។ នៅក្នុងឆ្នាំ២០០៨ លោកត្រូវបានតែងតាំងជា អនុប្រធានផ្នែក សវនកម្មសេវាធនាគារអេឡិចត្រូនិច និងសេវាហិរញ្ញប្បទានពាណិជ្ជកម្ម នៃធនាគារ អេស៊ីលីដា ភីអិលស៊ី ការិយាល័យកណ្តាល និង នៅឆ្នាំ២០០៩ ត្រូវបានតែងតាំងជាជំនួយការនាយិកាប្រតិបត្តិសវនកម្ម និង នៅឆ្នាំ២០១២ លោកត្រូវបានតែងតាំងជានាយកការិយាល័យសវនកម្មហិរញ្ញវត្ថុ។ នៅក្នុងឆ្នាំ២០១៦ លោកត្រូវបានផ្លាស់ប្តូរមុខងារជា នាយករង និងជា ប្រធានការិយាល័យផែនការនិងហិរញ្ញវត្ថុ នៃ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។



**លោក ហាស់ សម្បត្តិ**
ប្រធានការិយាល័យបុគ្គលិក និងរដ្ឋបាល

ជនជាតិខ្មែរ កើតឆ្នាំ១៩៥៩ ។ លោកបានទទួល សញ្ញាបត្រភាសាអង់គ្លេស ពី Gwynedd-Mercy College ( USA ) ក្នុងឆ្នាំ១៩៨៧ ។ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាល ជំនាញគ្រប់គ្រងឥណទាន និង ការដោះស្រាយបំណុល ជាមួយ Mekong Project Development Facility ( MPDF ) នៅក្នុងឆ្នាំ ២០០២ ។ នៅឆ្នាំ១៩៩៥ លោកបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញទីផ្សារ ជាមួយ Care International នៅប្រទេសថៃ និងបានចូលរួមវគ្គបណ្តុះបណ្តាល Micro Banking System ជាមួយ ធនាគារ RAKYAT ( BRI ) នៅប្រទេស ឥណ្ឌូណេស៊ី ក្នុងឆ្នាំ១៩៩៨ ។ ចាប់ពីឆ្នាំ១៩៩៤ មក លោកបានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ ជាច្រើនទៀត ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស។

លោកបានចូលបម្រើការងារជាមួយ ធនាគារ អេស៊ីលីដា នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៤ ក្នុងតួនាទី ជាមន្ត្រីឥណទាន ហើយលោកត្រូវបានតែងតាំងជាប្រធានការិយាល័យស្រុកនៅឆ្នាំ១៩៩៧ ។

នៅក្នុងឆ្នាំ ១៩៩៨ លោកត្រូវបានតែងតាំងជា នាយករងសាខា និងត្រូវបានតែងតាំងជានាយកសាខា ក្នុងឆ្នាំ២០០១ ។ នៅឆ្នាំ២០០៨ លោកត្រូវ បានតែងតាំងជា នាយកការិយាល័យគ្រប់គ្រង ការិយាល័យកណ្តាល ។ នៅក្នុងឆ្នាំ២០១០ លោកត្រូវបានផ្លាស់មុខងារតួនាទី ទៅជានាយករងនាយកដ្ឋានរដ្ឋបាល ។ ចាប់ពីខែកុម្ភៈ ឆ្នាំ២០១៣ មកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ លោកមានតួនាទីជា នាយកការិយាល័យហិរញ្ញវត្ថុ និង រដ្ឋបាល នៃ អេស៊ីលីដា ត្រេននីង សេនធ័រ ។ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ដល់ថ្ងៃទី ៣១ ខែមករាឆ្នាំ ២០១៦ លោកមានតួនាទីជានាយកការិយាល័យបុគ្គលិក និងរដ្ឋបាល នៃអេស៊ីលីដា ត្រេននីង សេនធ័រ ។ ចាប់ពីខែកុម្ភៈ ឆ្នាំ២០១៦ មកដល់បច្ចុប្បន្ន លោកមានតួនាទីជា ប្រធានការិយាល័យបុគ្គលិក និងរដ្ឋបាល នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។



**លោក សូ សុវណ្ណារ៉េត**
ប្រធានមជ្ឈមណ្ឌលហ្វឹកហ្វឺន

កើតខែមិថុនា ឆ្នាំ១៩៧៣, លោកបានទទួលសញ្ញាបត្រថ្នាក់អនុបណ្ឌិត គ្រប់គ្រងអភិវឌ្ឍន៍ ( MDM ) ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យន័រតុន នៅឆ្នាំ២០០៨ ។ លោកបានបញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រង ជំនាញគ្រប់គ្រង ពីវិទ្យាស្ថាន វិទ្យាសាស្ត្រគ្រប់គ្រង នៅឆ្នាំ២០០៤ និងសញ្ញាបត្រភាសាអង់គ្លេស ផ្នែកទំនាក់ទំនងពាណិជ្ជកម្ម ពីវិទ្យាស្ថានអប់រំពាណិជ្ជសាស្ត្រ ( Institute for Business Education ) ក្នុងឆ្នាំ២០១០ ។ នៅឆ្នាំ២០១៥ លោកទទួលបាន សញ្ញាបត្រ Certified Expert in Risk Management ពីសាលា Frankfurt School of Finance and Management ប្រទេសអាល្លឺម៉ង់។ នៅក្នុងឆ្នាំ២០១១, លោកបានបញ្ចប់ វគ្គបណ្តុះបណ្តាលការគ្រប់គ្រង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅទីក្រុង Frankfurt ប្រទេសអាល្លឺម៉ង់ និង វគ្គបណ្តុះបណ្តាលគ្រូហ្វឹកហ្វឺន, វគ្គជំនាញរៀបចំនិងអភិវឌ្ឍន៍កម្មវិធីសិក្សា, និងវគ្គជំនាញប្រឹក្សាយោបល់បែបវិជ្ជាជីវៈ ជាមួយសាលា Robenny School of Business នៅប្រទេសចិន និងនៅទីក្រុងហុងកុង ។ ចាប់ពីឆ្នាំ១៩៩៤ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនទៀតទាំងក្នុងប្រទេស និងក្រៅប្រទេស ដូចជាៈ ជំនាញគ្រប់គ្រងឥណទាននិងការដោះស្រាយបំណុលជាមួយ MPDF, ជំនាញទីផ្សារជាមួយ CARE International នៅប្រទេសថៃ, វគ្គ Micro Banking System ជាមួយធនាគារ RAKYAT( BRI ) នៅប្រទេសឥណ្ឌូនេស៊ី, វគ្គជំនាញភ្នាក់ងារឥណទាន, វគ្គគ្រប់គ្រងសម្រាប់ នាយករង និងប្រធានការិយាល័យស្រុក, វគ្គ Coaching for Success & Leadership Effectiveness. និងវគ្គ Advanced Training and Capacity Building Strategies និងវគ្គ Specialized MFISV Program on Training Management ។

លោកបានចូលបម្រើការងារជាមួយ ធនាគារ អេស៊ីលីដា នៅឆ្នាំ១៩៩៤ ក្នុងតួនាទីជា មន្ត្រីឥណទាន និងមន្ត្រីទំនាក់ទំនង រវាងអង្គការពលកម្មអន្តរជាតិ និងអេស៊ីលីដា ហើយលោកត្រូវបានតែងតាំងជា ប្រធានការិយាល័យស្រុក នៅ ឆ្នាំ១៩៩៧ ។ លោកត្រូវបានតែងតាំង ជាប្រធានផ្នែកហ្វឹកហ្វឺន នៅឆ្នាំ ២០០៥ ដល់ខែមិថុនា ឆ្នាំ២០០៩ ហើយបន្ទាប់មក លោកក៏ត្រូវបានដំឡើងឋានៈ ជាជំនួយការនាយកប្រតិបត្តិហ្វឹកហ្វឺន នៅខែកក្កដា ឆ្នាំ២០០៩, និងត្រូវបានតែងតាំងជានាយកការិយាល័យសិក្សា ចាប់ពី ខែសីហា ឆ្នាំ២០១១ ដល់ ខែធ្នូ ឆ្នាំ២០១២, ហើយចាប់ពីខែមករា ឆ្នាំ ២០១៣ ដល់ ខែ កុម្ភៈ ឆ្នាំ ២០១៦ លោកត្រូវបានតែងតាំងជា នាយកការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍ ។ នាពេលបច្ចុប្បន្ននេះ លោកមានតួនាទីជាប្រធានមជ្ឈមណ្ឌលហ្វឹកហ្វឺន ។



**លោកស្រី ទូត សុវណ្ណា**
ប្រធានការិយាល័យសិក្សា និងកិច្ចការនិស្សិត

កើតក្នុងឆ្នាំ១៩៨០ សុវណ្ណា បានបញ្ចប់ថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ នៅក្នុងឆ្នាំ ២០១៤។ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស ជំនាញអប់រំ ពីសាកលវិទ្យាល័យនរ័តុន នៅក្នុងឆ្នាំ២០០២ ។

នៅក្នុងឆ្នាំ ២០០៩ លោកស្រីបានចូលរួមវគ្គទស្សនកិច្ចសិក្សា លើប្រធានបទ ការគ្រប់គ្រងការហ្វឹកហ្វឺន នៅ CARD MRI ប្រទេស ហ្វីលីពីន, វគ្គហ្វឹកហ្វឺនលើប្រធានបទ ការគ្រប់គ្រងទីផ្សារ នៅ AMiDA (Academy for Microfinance Development in Asia) បាលី ប្រទេសឥណ្ឌូណេស៊ី, វគ្គហ្វឹកហ្វឺនលើប្រធាន ការអភិវឌ្ឍលើជំនាញវិជ្ជាជីវៈ ជាមួយ Robenny School of Business នៅប្រទេសវៀតណាម, និង វគ្គហ្វឹកហ្វឺនលើប្រធានបទ ការបណ្តុះបណ្តាល គ្រូបង្រៀន ជាមួយ Frankfurt School of Finance & Management និងជាមួយ Center for Microfinance Leadership Women's World Banking ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

នៅក្នុងឆ្នាំ ២០១៤ លោកស្រីបានចូលរួមវគ្គទស្សនកិច្ចសិក្សាទៅសកលវិទ្យាល័យដែលល្បីៗ នៅប្រទេស តៃវ៉ាន់ ដើម្បីសិក្សាអំពីប្រព័ន្ធអប់រំរបស់សាកលវិទ្យាល័យនីមួយៗ ទាក់ទងនឹងការគ្រប់គ្រង និស្សិត និងបណ្ណាល័យ។

នៅក្នុងខែមីនា ឆ្នាំ២០០៤ លោកស្រីបានចូលបម្រើការក្នុងផ្នែកហ្វឹកហ្វឺននៃធនាគារ អេស៊ីលីដា ភីអិលស៊ី នៅឆ្នាំ២០០៨ លោកស្រីត្រូវបានតែងតាំងជា អនុប្រធានផ្នែកកម្មសិក្សា និងឆ្នាំ២០០៩ ត្រូវបានតំឡើងមុខងារជាប្រធានផ្នែកកម្មសិក្សា ។ នៅឆ្នាំ២០១១ ត្រូវបានផ្លាស់ប្តូរមុខងារជាប្រធានផ្នែកអភិបាលហ្វឹកហ្វឺន បន្ទាប់មកផ្លាស់ជាប្រធានផ្នែកហ្វឹកហ្វឺនខាងក្រៅ នៅឆ្នាំ២០១២។ នៅក្នុងឆ្នាំ២០១៤ លោកស្រីមានតួនាទីជា នាយិកាការិយាល័យសិក្សា និងកិច្ចការនិស្សិត នៃអេស៊ីលីដា ត្រេននីង សេនធ័រ។ បច្ចុប្បន្នលោកស្រីមានតួនាទីជា ប្រធានការិយាល័យសិក្សា និងកិច្ចការនិស្សិត នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា។



**លោក លឹម ឌីណា**
ប្រធានការិយាល័យទំនាក់ទំនងសាធារណៈ

ជនជាតិខ្មែរ កើតនៅឆ្នាំ១៩៨០។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ជំនាញធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យបៀលប្រាយនៅក្នុងឆ្នាំ២០១០ ។ លោកបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ ពីវិទ្យាស្ថានជាតិគ្រប់គ្រងនៅក្នុងឆ្នាំ២០០២។ លោកធ្លាប់បានចូលរួមវគ្គទស្សនកិច្ចសិក្សានៅសាកលវិទ្យាល័យជាច្រើន នៅតៃវ៉ាន់ដូចជា ៖Elite Study in Taiwan (ESIT) នៃក្រសួងអប់រំតៃវ៉ាន់, Chung Yuan Christian University (CYCU), National Cheng Kung University (NCKU), National Sun Yat-Sen University (NSYU), National Central University (NCU), National Taichung University of Education (NTUE), National Chung Hsing University (NCHU), and University of Taipeiនៅក្នុងឆ្នាំ២០១៤។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៣ លោកក៏បានចូលរួមនៅក្នុងវគ្គសិក្ខាសាលាចែករំលែកបទពិសោធន៍ រវាងធនាគារជាតិនៃប្រទេសកម្ពុជា និងធនាគារជាតិនៃសាធារណរដ្ឋប្រជាមានិតឡាវ ស្តីពីការគ្រប់គ្រង និងត្រួតពិនិត្យលើស្ថាប័នហិរញ្ញវត្ថុ នៅក្នុងប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

លោកបានចូលបម្រើការងារជាមួយធនាគារ អេស៊ីលីដា នៅក្នុងឆ្នាំ២០០៨ ក្នុងមុខតំណែង ភ្នាក់ងារបម្រើអតិថិជន ហើយត្រូវបានដំឡើងមុខងារជា អនុប្រធានភ្នាក់ងារទីផ្សារសាខា នៅក្នុងខែតុលា ឆ្នាំ២០០៨។ នៅក្នុងខែមិថុនា ឆ្នាំ២០១១ លោកត្រូវបានតែងតាំងជា ប្រធានភ្នាក់ងារទីផ្សារសាខាក្រុងភ្នំពេញ។ នៅក្នុងខែកញ្ញា ឆ្នាំ២០១២ លោកត្រូវបានផ្លាស់ប្តូរមុខងារជា ប្រធានផ្នែកទីផ្សារ នៃ អេស៊ីលីដា ត្រេននីង សេនធ័រ។ ចាប់ពីខែ កក្កដា ឆ្នាំ២០១៦ មកដល់បច្ចុប្បន្ន លោកមានតួនាទីជា ប្រធានការិយាល័យទំនាក់ទំនងសាធារណៈ នៃ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។



**លោកស្រី ហ៊ូ ស្មើ**
ប្រធានដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម

កើតក្នុងឆ្នាំ១៩៧៩ ស្មើ បានបញ្ចប់ថ្នាក់អនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រ នៅក្នុងឆ្នាំ ២០១៤។ លោកស្រីបានបញ្ចប់ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម ជំនាញគណនេយ្យ ពីសាកលវិទ្យាល័យគ្រប់គ្រងនៅក្នុងឆ្នាំ២០០២, លោកស្រីក៏បានបញ្ចប់ថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ ជំនាញគណិតវិទ្យា ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅក្នុងឆ្នាំ២០០០ និង ក្នុងឆ្នាំ២០០១ លោកស្រីបានទទួលសញ្ញាបត្រគ្រូមធ្យមសិក្សាទុតិយភូមិ ពីមហាវិទ្យាល័យគរុកោសល្យ ។

នៅក្នុងឆ្នាំ ២០១០លោកស្រីបានចូលរួម វគ្គហ្វឹកហ្វឺនលើប្រធានបទ ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈ ជាមួយ Frankfurt School of Finance & Management និង នៅក្នុងឆ្នាំ ២០១១លោកស្រីបានចូលរួម វគ្គហ្វឹកហ្វឺនលើប្រធានបទ ការបណ្តុះបណ្តាលគ្រូបង្រៀន ជាមួយ Frankfurt School of Finance & Management ។ នៅក្នុងឆ្នាំ ២០១៤ លោកស្រីបានចូលរួមវគ្គទស្សនកិច្ចសិក្សាទៅសកលវិទ្យាល័យដែលល្បីៗ នៅប្រទេស តៃវ៉ាន់ ដើម្បីសិក្សាអំពីប្រព័ន្ធអប់រំរបស់សាកលវិទ្យាល័យនីមួយៗ ទាក់ទងនឹងការគ្រប់គ្រង និស្សិត និងបណ្ណាល័យ។

នៅក្នុងខែតុលា ឆ្នាំ២០០៤ លោកស្រីបានចូលបម្រើការជាបុគ្គលិកផ្នែកអភិវឌ្ឍន៍ហ្វឹកហ្វឺន នៃធនាគារ អេស៊ីលីដា ភីអិលស៊ី ។ នៅឆ្នាំ២០០៨ លោកស្រីត្រូវបានតែងតាំងជា អនុប្រធានផ្នែកអភិវឌ្ឍន៍ហ្វឹកហ្វឺន និងឆ្នាំ២០០៩ ត្រូវបានដំឡើងមុខងារជាប្រធានផ្នែកអភិវឌ្ឍន៍ហ្វឹកហ្វឺន។ នៅឆ្នាំ២០១១ ត្រូវបានផ្លាស់ប្តូរមុខងារជា ប្រធានផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ និងបន្ទាប់មកផ្លាស់ជាអ្នកឯកទេសជាន់ខ្ពស់ផ្នែកស្រាវជ្រាវ និងអភិវឌ្ឍន៍ នៅឆ្នាំ២០១៤។ នៅក្នុងឆ្នាំ២០១៦ មកដល់បច្ចុប្បន្ន លោកស្រីមានតួនាទីជា ប្រធានដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

# ទីប្រឹក្សា

ទីប្រឹក្សា នៃ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានកាតព្វកិច្ចបំពេញតួនាទីឱ្យអស់ពីសមត្ថភាព ដើម្បីចូលរួមត្រួតពិនិត្យកែតម្រូវ និងផ្តល់យោបល់អភិវឌ្ឍធ្វើយ៉ាងណា ឱ្យសម្រេចនូវគោលដៅយុទ្ធសាស្ត្រ របស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា មានដូចជា៖

- ផ្តល់ការប្រឹក្សាយោបល់លើការរៀបចំផែនការ និងយុទ្ធសាស្ត្រដើម្បីដំណើរការ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ជាស្ថាប័នបុត្រសម្ព័ន្ធ ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រកបអាជីវកម្មដាច់ដោយឡែកប្រកបដោយនិរន្តរភាព ។
- ផ្តល់ការប្រឹក្សាយោបល់ លើការងារបណ្តុះ បណ្តាល គ្រប់គ្រងប្រតិបត្តិការ និងការងារទំនាក់ ទំនងសាធារណៈ ដើម្បីប្រែវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ទៅជាគ្រឹះស្ថានឧត្តមសិក្សាឈានមុខនៅក្នុងតំបន់ ។
- ផ្តល់ការបណ្តុះបណ្តាល ផ្ទេរបទពិសោធន៍ និងចំណេះដឹង ដល់អ្នកពាក់ព័ន្ធ ដើម្បីពង្រឹង សមត្ថភាព និងពង្រឹងប្រតិបត្តិការ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

ជនជាតិខ្មែរ កើតថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៦០ ។ លោកទទួលបានបរិញ្ញាបត្រអប់រំ នៅមហាវិទ្យាល័យ Advanced Education នៅប្រទេសថៃ ឆ្នាំ១៩៩២ ។

ចាប់ពីឆ្នាំ១៩៩៤មក លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន នៅក្នុងវិស័យ ធនាគារ មីក្រូហិរញ្ញវត្ថុ និងសហគ្រាសខ្នាតតូច និងមធ្យមនៅក្នុងប្រទេស និងនៅបណ្តាប្រទេសមួយចំនួនដូចជា៖ សហរដ្ឋអាមេរិក ថៃ ហុងកុង សិង្ហបុរី ហ្វីលីពីន ឥណ្ឌូណេស៊ី មីយ៉ាន់ម៉ា ឡាវ ។ ក្នុងឆ្នាំ១៩៩៩ លោកបានបញ្ចប់ វគ្គគ្រប់គ្រង ស្តីពីស្ថាប័នហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍ សហគ្រាសឯកជន( FIPED ) នៅសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក។

ចាប់ពីឆ្នាំ១៩៩៤ លោកបានបម្រើការងារជាមួយ អង្គការ អេស៊ីលីដា ជាភ្នាក់ងារផ្សព្វផ្សាយសហគ្រាសខ្នាតតូច( SEPO ) និងជាភ្នាក់ងារឥណទាន ។ ក្នុង ឆ្នាំ១៩៩៥ លោកត្រូវបានតែងតាំងជា នាយករង អេស៊ីលីដា សាខាខេត្តបាត់ដំបង ។ នៅក្នុង១៩៩៧ លោកជានាយក អេស៊ីលីដា សាខាខេត្តកំពង់ធំ ។ ឆ្នាំ២០០១ លោកជាប្រធាន ផ្នែកធនធានមនុស្ស នៅការិយាល័យកណ្តាល ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ ក្នុងឆ្នាំ២០០២ លោកជាប្រធានផ្នែកហ្វឹកហ្វឺន និងជានាយក ការិយាល័យហ្វឹកហ្វឺន នៅឆ្នាំ២០០៦ ហើយលោក ត្រូវបានតែងតាំងជា នាយកនាយកដ្ឋានហ្វឹកហ្វឺន ចាប់ពីឆ្នាំ២០០៩ ដល់ ខែកក្កដា ឆ្នាំ២០១១ ។ ចាប់ពីខែសីហា ឆ្នាំ២០១១ ដល់ឆ្នាំ ២០១៥ លោកមានតំណែងជា ទីប្រឹក្សា នៃអេស៊ីលីដា ត្រេននីង សេនធ័រ ។ ចាប់ពីខែមករា ឆ្នាំ២០១៦ រហូតមកដល់បច្ចុប្បន្ន លោកមានតំណែងជា ទីប្រឹក្សា នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។



**លោក ថោង ចាន់តារា**
ទីប្រឹក្សា

ជនជាតិខ្មែរ កើតថ្ងៃទី០១ ខែមករា ឆ្នាំ១៩៥៨។ លោកបានទទួល សញ្ញាបត្របណ្តុះបណ្តាលជំនាញគ្រូហ្វឹកហ្វឺន នៅឆ្នាំ២០១១ ពី Frankfurt School of Finance & Management សញ្ញាបត្របណ្តុះបណ្តាលជំនាញរៀបចំ និងអភិវឌ្ឍន៍កម្មវិធីហ្វឹកហ្វឺន នៅឆ្នាំ២០១១ ពី Robenny School of Business សញ្ញាបត្របណ្តុះបណ្តាលជំនាញគ្រូហ្វឹកហ្វឺន នៅឆ្នាំ២០០៦ ពីACE, សញ្ញាបត្រគ្រូហ្វឹកហ្វឺនគ្រូ នៅឆ្នាំ១៩៨៩, សញ្ញាបត្រគរុកោសល្យនៅឆ្នាំ១៩៩០ពីមជ្ឈមណ្ឌលហ្វឹកហ្វឺនគ្រូ នៅប្រទេសថៃ ។

លោកបានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន នៅក្នុងវិស័យ ធនាគារ មីក្រូហិរញ្ញវត្ថុ និងសហគ្រាសខ្នាតតូច និងមធ្យម នៅក្នុងប្រទេស និងនៅបណ្តាប្រទេស មួយចំនួនដូចជា ៖ នៅប្រទេសថៃ ចិន ឥណ្ឌូណេស៊ី ហ្វីលីពីន អ៊ីតាលី អាល្លឺម៉ង់ ។

លោកបានចូលបម្រើការងារជាមួយ ធនាគារ អេស៊ីលីដា នៅឆ្នាំ១៩៩៣ ជាភ្នាក់ងារផ្សព្វផ្សាយសហគ្រាសខ្នាតតូច និងជាគ្រូហ្វឹកហ្វឺន។ ឆ្នាំ១៩៩៤ លោកបានផ្លាស់មកបំពេញការងារជា អ្នកឯកទេសសហគ្រាសខ្នាតមធ្យម និងក្រុមគាំទ្របច្ចេកទេស។ នៅឆ្នាំ១៩៩៨ លោកត្រូវបានតែងតាំងជា នាយកមជ្ឈមណ្ឌលហ្វឹកហ្វឺន អេស៊ីលីដា។ ឆ្នាំ២០០០ លោកត្រូវបានតែងតាំងជានាយករងនាយកដ្ឋានឥណទាន។ ចាប់តាំងពីឆ្នាំ២០០១មក លោកត្រូវបានចាត់តាំងឱ្យកាន់មុខតំណែងជា អ្នកគ្រប់គ្រងជំនាញដទៃទៀតជាច្រើន។ ក្នុងឆ្នាំ២០០៩ លោកត្រូវបានតែងតាំងជា នាយកការិយាល័យសិក្សា នៃនាយកដ្ឋានហ្វឹកហ្វឺន ធនាគារ អេស៊ីលីដា និងបន្ទាប់មកជា នាយករងនាយកដ្ឋានហ្វឹកហ្វឺន ធនាគារ អេស៊ីលីដា នៅឆ្នាំ ២០១១ ។ នៅឆ្នាំ២០១២ លោកមានតំណែងជា នាយកនាយកដ្ឋានហ្វឹកហ្វឺន នៃ អេស៊ីលីដា ត្រេននីង សេនធ័រ ។ ឆ្នាំ២០១៣ លោកទទួលមុខតំណែងជា នាយកការិយាល័យសិក្សា និងចាប់ពីដើមឆ្នាំ២០១៤ ដល់ឆ្នាំ ២០១៥ លោកមានតំណែងជា ទីប្រឹក្សា នៃអេស៊ីលីដា ត្រេននីង សេនធ័រ ។ ចាប់ពីខែមករា ឆ្នាំ២០១៦ រហូតមកដល់បច្ចុប្បន្ន លោកមានតំណែងជា ទីប្រឹក្សា នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ។



**លោក ម៉ែន សុផល**
ទីប្រឹក្សា

# ក្រមសីលធម៌

ក្នុងក្រមសីលធម៌របស់ក្រុមប្រឹក្សាភិបាល គ្រប់គ្រងដោយ ៖

១. អនុស្សរណៈ និងលក្ខន្តិកៈរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

២. កិច្ចព្រមព្រៀងភាគទុនិក និង

៣. ច្បាប់ និងបទបញ្ញត្តិទាំងឡាយណាដែលពាក់ព័ន្ធរបស់ព្រះរាជាណាចក្រកម្ពុជា

វិវឌ្ឍនាការឥតឈប់ឈររបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា គឺទាមទារឲ្យមានការយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាថា បទដ្ឋាននៃការអនុវត្តផ្ទៃក្នុងរបស់សាជីវកម្ម ត្រូវបានរក្សាក្នុងកម្រិតមួយខ្ពស់បំផុត ។ ក្នុងចំណោមបញ្ហាផ្សេងៗនោះ រួមមាន៖ កិច្ចព្រមព្រៀងលើការផ្តល់សេវារបស់ក្រុមប្រឹក្សាភិបាល កម្មវិធីបណ្តុះបណ្តាលតួនាទីមុខងាររបស់ក្រុមប្រឹក្សាភិបាល បញ្ជីវាយតម្លៃក្រុមប្រឹក្សាភិបាល និងក្រមសីលធម៌របស់ក្រុមប្រឹក្សាភិបាល ត្រូវបានរៀបចំដាក់ឲ្យប្រើប្រាស់ ហើយតួនាទីទាក់ទងទៅនឹងប្រាក់លាភការ និងការចំណាយរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានរៀបចំជាទម្រង់យ៉ាងច្បាស់លាស់ ។

និយោជិតគ្រប់រូបរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ស្ថិតក្រោមការគ្រប់គ្រងមួយយ៉ាងតឹងរឹងនៃ ក្រមសីលធម៌ដែលបានកំណត់ក្នុងអនុសញ្ញារួមការងារ ដោយគ្របដណ្តប់លើបញ្ហាមួយចំនួនដូចជា៖ ចរិត លក្ខណបុគ្គល ទំនាក់ទំនងជាមួយអ្នករួមការងារ អតិថិជន និងអ្នកគ្រប់គ្រង អាថ៌កំបាំងវិជ្ជាជីវៈ វិវាទលើផលប្រយោជន៍ ការទទួលយកអំណោយ ការសម្អាតប្រាក់ និងការបកអាក្រាតកំហុសឆ្គង ។

ឯកសារទាំងនេះ ត្រូវបានត្រួតពិនិត្យសារឡើងវិញយ៉ាងទៀងទាត់ដោយសវនករ ដើម្បីធានាថា វានៅតែ មានសុពលភាពប្រើប្រាស់ និងទាន់សម័យ ។



ថ្នាក់ដឹកនាំ អេស៊ីលីដា រំលឹកគុណមាតា-បិតា មុនពិធីបើកវគ្គហ្វឹកហ្វឺន





សកម្មភាពបរិច្ចាគឈាមរបស់ថ្នាក់ដឹកនាំ និងកម្មករនិយោជិត ព្រមទាំងនិស្សិត នៃវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

# របាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនករឯករាជ្យ

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

## មាតិកា


របាយការណ៍ក្រុមប្រឹក្សាភិបាល ........ ៣០

របាយការណ៍របស់សវនករឯករាជ្យ ........ ៣២

របាយការណ៍ហិរញ្ញវត្ថុ

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........ ៣៤
- របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ ........ ៣៥
- របាយការណ៍បម្រែបម្រួលមូលធន ........ ៣៦
- របាយការណ៍លំហូរសាច់ប្រាក់ ........ ៣៧

កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ........ ៣៨




សមាសភាពគណៈកម្មាធិការប្រតិបត្តិ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

# របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសេចក្តីសោមនស្ស ក្នុងការដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា (ហៅកាត់ថា " ក្រុមហ៊ុន ") សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ។

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនក្នុងអំឡុងឆ្នាំ និងរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម៖

| | |
|---|---|
| ១. បណ្ឌិត សូ ផនណារី | ប្រធានក្រុមប្រឹក្សាភិបាល |
| ២. លោក ព្រំ វិសុទ្ធ | អភិបាលសមាជិកក្រុមប្រឹក្សាភិបាល |
| ៣. លោក អ៊ុង សំអុល | អភិបាលសមាជិកក្រុមប្រឹក្សាភិបាល |
| ៤. លោក ឆន ពន្លឺ | អភិបាលសមាជិកក្រុមប្រឹក្សាភិបាល |
| ៥. លោក Pieter Kooi | អភិបាលសមាជិកក្រុមប្រឹក្សាភិបាល |
| ៦. បណ្ឌិត ឌី សមស៊ីដេត | អភិបាលសមាជិកក្រុមប្រឹក្សាភិបាល |

## អំពីក្រុមហ៊ុន

មុនថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រុមហ៊ុន (អតីត " ក្រុមហ៊ុន អេស៊ីលីដា ត្រេននីង សេនធ័រ លីមីតធីត " គឺជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត បង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមអាជ្ញាប័ណ្ណលេខ Co.១៣៣២KH/២០១១ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ពីក្រសួងពាណិជ្ជកម្ម។ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រសួងពាណិជ្ជកម្មបានអនុម័តឲ្យក្រុមហ៊ុនប្តូរនាមករណ៍ក្រុមហ៊ុនទៅជា វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ ០០០០៣៨៣៦។នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជាបានចេញអាជ្ញាប័ណ្ណឲ្យក្រុមហ៊ុន តាមរយៈអនុក្រឹត្យលេខ ១៣អនក្រ.បក ដើម្បីប្រែក្លាយជាវិទ្យាស្ថាន។ ក្រុមហ៊ុនត្រូវបានកាន់កាប់ទាំងស្រុងដោយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាធនាគារពាណិជ្ជចុះបញ្ជីពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាបណ្តុះបណ្តាលដល់និស្សិតជាតិ និងអន្តរជាតិ នូវសេវាអប់រំកម្រិតឧត្តមសិក្សាប្រកបដោយគុណភាពខ្ពស់ ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ដោយអនុលោមទៅតាមអនុក្រឹត្យដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធ។ ក្រុមហ៊ុនក៏ចូលរួមចំណែកដោយតរិយាបថវិជ្ជមាន ក្នុងការកសាងសមត្ថភាពរបស់ខ្លួន ដើម្បីបង្កើនគុណសម្បត្តិប្រកបដោយការប្រកួតប្រជែង ក្នុងទីផ្សារពលកម្ម ក៏ដូចជាដើម្បីរៀបចំអាជីវកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ក្រុមហ៊ុនអាចនឹងផ្តល់សេវាផ្សេងៗបន្ថែមទៀត យោងទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ នៅលើទំព័រទី៨។

ក្នុងអំឡុងដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ក្រុមហ៊ុនមិនបានប្រកាស ឬបានបង់ភាគលាភទេ (ឆ្នាំ២០១៥៖គ្មាន)។

## ទ្រព្យសកម្ម

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលអាចបណ្តាលឱ្យតម្លៃទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនពុំត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលបានកើតឡើង ហើយអាចបណ្តាលឲ្យប៉ះពាល់ដល់វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្ម និងបំណុលដែលមានស្រាប់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវ ឬមិនសមស្របជាសារវន្តនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ៖

ក. មិនមានបន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំមក និង

ខ. មិនមានបំណុលយថាភាពណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំមក

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់ក្រុមហ៊ុន បានក្លាយជាការបង្ខំឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងរយៈពេល១២ខែបន្ទាប់ពីដំណាច់ឆ្នាំ ដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃកំណត់សងនោះទេ ។

## ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយដែលមិនបានរៀបរាប់នៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងដំណាច់ឆ្នាំ រហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៅក្នុងឆ្នាំនោះទេ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល លើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះក្រុមប្រឹក្សាភិបាលត្រូវ ៖

១. អនុវត្តគោលការណ៍គណនេយ្យសមស្រប ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយ ការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះឱ្យបានជាប្រចាំ ។
២. អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មានរបស់ CIFRS ហើយប្រសិនបើមានការប្រាសចាកណាមួយក្នុងការ បង្ហាញឱ្យមានភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនោះត្រូវបានបង្ហាញ ពន្យល់ និងកំណត់បរិមាណឲ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។
៣. រក្សាទុកកំណត់ត្រាគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ។
៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីសន្មតសមរម្យថា ក្រុមហ៊ុននឹងមិនអាចបន្តកិច្ចប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង
៥. គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាព តាមរយៈការសម្រេចចិត្តសំខាន់ៗទាំងអស់ ដែលជះឥទ្ធិពលដល់ប្រតិបត្តិការនិងលទ្ធផលរបស់ក្រុមហ៊ុន ហើយត្រូវធានាថាផលប៉ះពាល់ទាំងនោះ ត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថាក្រុមហ៊ុនបានអនុវត្តតាមតម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមធានាអះអាងថារបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងលទ្ធផលអាជីវកម្ម បម្រែបម្រួលមូលធន ព្រមទាំងលំហូរសាច់របស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជា ។

ជ. ក្រុមប្រឹក្សាភិបាល

ACLEDA

បណ្ឌិត សូ ផនណារី
ប្រធានក្រុមប្រឹក្សាភិបាល
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនភាគទុនិក វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

## របាយការណ៍សវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

### មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ អំពី ស្ថានភាពហិរញ្ញវត្ថុរបស់ វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា (ហៅកាត់ថា " ក្រុមហ៊ុន ") គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

### របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមាន៖

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦
- របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ។

### មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិ ស្តីពីសវនកម្មនៃកម្ពុជា (ហៅកាត់ថា " ស្តង់ដារសវនកម្ម ")។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដារទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ " ការទទួលខុសត្រូវរបស់សវនករក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ " នៅក្នុងរបាយការណ៍របស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួលមានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពីក្រុមហ៊ុន ដែលអនុលោមទៅតាមក្រមសីលធម៌សម្រាប់គណនេយ្យករវិជ្ជាជីវៈ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ (ហៅកាត់ថា " ក្រមសីលធម៌អន្តរជាតិ ") និងអនុលោមទៅតាមក្រមសីលធម៌ របស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា " វគសក ")។ យើងខ្ញុំបានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្នែកក្រមសីលធម៌ផ្សេងៗទៀត ដែលកំណត់ដោយក្រមសីលធម៌អន្តរជាតិ និង " វគសក " ។

### ការទទួលខុសត្រូវរបស់ថ្នាក់គ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចរបាយការណ៍ហិរញ្ញវត្ថុ

ថ្នាក់គ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងបង្ហាញរបាយការណ៍ទាំងនោះឲ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលថ្នាក់គ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ថ្នាក់គ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តភាពអាជីវកម្ម លើកលែងតែថ្នាក់គ្រប់គ្រងគ្រោងនឹងបិទអាជីវកម្មរបស់ក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ដោយមិនមានជម្រើសប្រកបដោយភាពប្រាកដប្រជាណាមួយ ។

អ្នកដែលទទួលបន្ទុកអភិបាលកិច្ច ត្រូវមានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

### ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំគឺស្វែងរកអំណះអំណាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូល ពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនកម្មដែលមានមតិយោបល់របស់យើងខ្ញុំ។ ការអះអាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្ម តម្រូវឲ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យ និងរក្សាការងឿងឆ្ងល់ប្រកបដោយវិជ្ជាជីវៈ ក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្មដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងស្វែងរកភស្តុតាងសវនកម្មគ្រប់គ្រាន់និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា។ ការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការបដិសេធនូវប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំទៅលើប្រសិទ្ធភាពនៃការត្រួតពិនិត្យប្រព័ន្ធផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធដែលថ្នាក់គ្រប់គ្រងបានធ្វើឡើង ។
- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់ មូលដ្ឋានគណនេយ្យនិរន្តភាពអាជីវកម្មរបស់ថ្នាក់គ្រប់គ្រង អាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណា ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា អាចបណ្តាលឲ្យមានការសង្ស័យ ជាដុំកំភួនទៅលើលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនកម្ម ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាង ព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន រហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនកម្មនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគត អាចបណ្តាលឲ្យក្រុមហ៊ុនឈប់បន្តនិរន្តភាពអាជីវកម្ម ។
- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រាប់ទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើឲ្យមានការបង្ហាញត្រឹមត្រូវ ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗ ដូចជា ទំហំការងារ និងពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗដែលយើងខ្ញុំបានរកឃើញ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តក្នុងការគ្រប់គ្រងផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ ។

ជ. ក្រុមហ៊ុន PricewaterhouseCoopers ( Cambodia ) Ltd.

គុយ លីម
Partner



រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧



ថ្នាក់ដឹកនាំ និងកម្មករនិយោជិត ព្រមទាំងនិស្សិត វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចូលរួមលេងកីឡា ដើម្បីសុខភាព

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | ៣១ ធ្នូ ឆ្នាំ ២០១៦ | | ៣១ ធ្នូ ឆ្នាំ ២០១៥ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ | ១៦.០៧៧.៦០៨ | ៦៤.៩០៥.៣០៣ | ១៣.៦២៩.១២៤ | ៥៥.១៩៧.៩៥២ |
| ទ្រព្យសកម្មអរូបី | ៧ | ៣.៦៨៥ | ១៤.៨៧៦ | ៧២២ | ២.៩២៤ |
| ពន្ធពន្យារទ្រព្យសកម្ម | ៨ | ១៣៨.៨១៤ | ៥៦០.៣៩២ | ៩៥.៨៩២ | ៣៨៨.៣៦៣ |
| ប្រាក់តម្កល់តាមច្បាប់ | ៩ | ៥៩.៤៥០ | ២៤០.០០០ | - | - |
| ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់ | ១០ | ៣៧.២៩២ | ១៥០.៥៤៨ | ៣៧.២៩២ | ១៥១.០៣៣ |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | ១៦.៣១៦.៨៤៩ | ៦៥.៨៧១.១១៩ | ១៣.៧៦៣.០៣០ | ៥៥.៧៤០.២៧២ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១១ | ១.៣១៩.៦៩០ | ៥.៣២៧.៥៨៩ | ៩០.៥៣៣ | ៣៦៦.៦៥៩ |
| ប្រាក់តម្កល់មានកាលកំណត់ | ១២ | ៨.៩៤២.៥៥០ | ៣៦.១០១.០៧៤ | ២.៨៤៨.០៤៨ | ១១.៥៣៤.៥៩៤ |
| ប្រាក់ជំនួយត្រូវទទួល | | - | - | - | - |
| គណនីត្រូវទទួលផ្សេងៗ | ១៣ | ២៦.៨៦០ | ១០៨.៤៣៤ | ៦៦.០៨៣ | ២៦៧.៦៣៦ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | ១០.២៨៩.១០០ | ៤១.៥៣៧.០៩៧ | ៣.០០៤.៦៦៤ | ១២.១៦៨.៨៨៩ |
| **ទ្រព្យសកម្មសរុប** | | ២៦.៦០៥.៩៤៩ | ១០៧.៤០៨.២១៦ | ១៦.៧៦៧.៦៩៤ | ៦៧.៩០៩.១៦១ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| ប្រាក់កម្ចី | ១៥ | ៤.៧៩៨.០៣៣ | ១៩.៣៦៩.៦៥៩ | - | - |
| កាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិក | ១៦ | ២៤៧.៨០២ | ១.០០០.៣៧៧ | ២១៥.៩៤២ | ៨៧៤.៥៦៥ |
| **បំណុលរយៈពេលវែងសរុប** | | ៥.០៤៥.៨៣៥ | ២០.៣៧០.០៣៦ | ២១៥.៩៤២ | ៨៧៤.៥៦៥ |
| **បំណុលរយៈពេលខ្លី** | | | | | |
| ប្រាក់កម្ចី | ១៥ | ១៩.០៧៧ | ៧៧.០១៥ | - | - |
| បង្គរ និងគណនីត្រូវសងផ្សេងៗ | ១៧ | ៦៦៦.៨៥០ | ២.៦៩២.០៧៣ | ៤៣២.០១៥ | ១.៧៤៩.៦៦១ |
| បំណុលពន្ធលើប្រាក់ចំណេញក្នុងគ្រា | ២២ | ១១.១៩៥ | ៤៥.១៩៤ | ៥៣.៣៤២ | ២១៦.០៣៥ |
| **បំណុលរយៈពេលខ្លីសរុប** | | ៦៩៧.១២២ | ២.៨១៤.២៨២ | ៤៨៥.៣៥៧ | ១.៩៦៥.៦៩៦ |
| **បំណុលសរុប** | | ៥.៧៤២.៩៥៧ | ២៣.១៨៤.៣១៨ | ៧០១.២៩៩ | ២.៨៤០.២៦១ |
| **មូលធន** | | | | | |
| ដើមទុន | ១៤ | ១៧.៨០៥.០០០ | ៧១.៨៧៨.៧៨៥ | ១២.៨០៥.០០០ | ៥១.៨៦០.២៥០ |
| ចំណេញរក្សាទុក | | ៣.០៥៧.៩៩២ | ១២.៣២០.១២៤ | ៣.២៦១.៣៩៥ | ១៣.១៤៤.៥១៦ |
| ទុនបម្រុងផ្សេងៗ | | - | ២៤.៩៨៩ | - | ៦៤.១៣៤ |
| **មូលធនសរុប** | | ២០.៨៦២.៩៩២ | ៨៤.២២៣.៨៩៨ | ១៦.០៦៦.៣៩៥ | ៦៥.០៦៨.៩០០ |
| **មូលធន និងបំណុលសរុប** | | ២៦.៦០៥.៩៤៩ | ១០៧.៤០៨.២១៦ | ១៦.៧៦៧.៦៩៤ | ៦៧.៩០៩.១៦១ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ១១ ដល់ទំព័រទី ៤២ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | ២០១៦ | | ២០១៥ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល |
| ចំណូល | ១៨ | ១.៨៧១.៦២១ | ៧.៥៨៥.៦៨០ | ២.១៦៦.៣១២ | ៨.៧៩៥.២២៧ |
| ថ្លៃដើមនៃសេវាកម្ម | ១៩ | (៨៦១.៣៧៤) | (៣.៤៩១.១៤៩) | (៦៤៣.៩៥៦) | (២.៦១៤.៤៦១) |
| ចំណេញដុល | | ១.០១០.២៤៧ | ៤.០៩៤.៥៣១ | ១.៥២២.៣៥៦ | ៦.១៨០.៧៦៦ |
| ចំណាយទូទៅ និងរដ្ឋបាល | ២០ | (១.៣៣៦.៩៥០) | (៥.៤១៨.៦៥៨) | (១.៣៦៩.៦៩៣) | (៥.៥៦០.៩៥៣) |
| ចំណូលផ្សេងៗ | | ៣៣៧ | ១.៣៦៦ | ២០៥ | ៨៣២ |
| ខាតផ្សេងៗ-សុទ្ធ | | (១.២៧៩) | (៥.១៨៤) | (១៩៣) | (៧៨៤) |
| (ខាត)/ចំណេញ ប្រតិបត្តិការ | | (៣២៧.៦៤៥) | (១.៣២៧.៩៤៥) | ១៥២.៦៧៥ | ៦១៩.៨៦១ |
| ចំណូលពីប្រាក់ជំនួយ | | - | - | ៥.៣៨០ | ២១.៨៤៣ |
| ចំណូលការប្រាក់ | | ១៣៦.០៥៦ | ៥៥១.៤៣៥ | ២០៤.១៥៨ | ៨២៨.៨៨១ |
| ចំណាយការប្រាក់ | | (៣២.៤៩៥) | (១៣១.៧០២) | - | - |
| ចំណូលការប្រាក់-សុទ្ធ | ២១ | ១០៣.៥៦១ | ៤១៩.៧៣៣ | ២០៤.១៥៨ | ៨២៨.៨៨១ |
| (ខាត)/ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | | (២២៤.០៨៤) | (៩០៨.២១២) | ៣៦២.២១៣ | ១.៤៧០.៥៨៥ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២២ | ២២.៨៤២ | ៩២.៥៧៩ | (៧២.១៥០) | (២៩២.៩២៩) |
| (ខាត)/ចំណេញក្នុងឆ្នាំ | | (២០១.២៤២) | (៨១៥.៦៣៣) | ២៩០.០៦៣ | ១.១៧៧.៦៥៦ |
| ចំណូលលម្អិតផ្សេងៗ៖ | | | | | |
| ខ្ទង់ផ្សេងៗដែលមិនត្រូវបានចាត់ថ្នាក់ឡើងវិញក្នុងចំណេញ-ខាត | | | | | |
| ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិកឡើងវិញ | | (២.១៦១) | (៥.៤៤២) | (៣.០៥៤) | (៧.៣៧២) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៣៩.១៤៥) | - | (៦៤.៨៣១) |
| (ខាត)/ចំណេញលម្អិតសរុបក្នុងឆ្នាំ | | (២០៣.៤០៣) | (៨៦០.២២០) | ២៨៧.០០៩ | ១.១០៥.៤៥៣ |
| (ខាត)/ចំណេញរបស់៖ | | | | | |
| ម្ចាស់ក្រុមហ៊ុន | | (២០១.២៤២) | (៨១៥.៦៣៣) | ២៩០.០៦៣ | ១.១៧៧.៦៥៦ |
| (ខាត)/ចំណេញលម្អិតសរុបរបស់៖ | | | | | |
| ម្ចាស់ក្រុមហ៊ុន | | (២០៣.៤០៣) | (៨៦០.២២០) | ២៨៧.០០៩ | ១.១០៥.៤៥៣ |



វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា ជាមួយ ស្ថាប័នអប់រំ អ៊ិន ធី ស៊ី គ្រុប

# របាយការណ៍បម្រែបម្រួលមូលធន

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | ជារបស់ម្ចាស់ក្រុមហ៊ុន | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ដើមទុន | | ចំណេញរក្សាទុក | | ទុនបម្រុងផ្សេងៗ | | សរុប | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ***សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥*** | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ | ១២,៨០៥,០០០ | ៥២,១៨០,៣៧៥ | ២,៩៧៤,៣៨៦ | ១១,៩៩១,៦៥៨ | - | ១២៨.៩៦៥ | ១៥.៧៧៩.៣៨៦ | ៦៤.៣០០.៩៩៨ |
| ចំណូលលម្អិត: | | | | | | | | |
| ចំណេញក្នុងឆ្នាំ | - | - | ២៩០.០៦៣ | ១.១៦៥.២៥៧ | - | - | ២៩០.០៦៣ | ១.១៦៥.២៥៧ |
| ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិកឡើងវិញ | - | - | (៣.០៥៤) | (១២.៣៩៩) | - | - | (៣.០៥៤) | (១២.៣៩៩) |
| ចំណូលលម្អិតផ្សេងៗ - លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (៦៤.៨៣១) | - | (៦៤.៨៣១) |
| ចំណូលលម្អិតសរុបក្នុងឆ្នាំ | - | - | ២៨៧.០០៩ | ១.១៥២.៨៥៨ | - | (៦៤.៨៣១) | ២៨៧.០០៩ | ១.០៨៨.០២៧ |
| ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន៖ | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៣២០.១២៥) | - | - | - | - | - | (៣២០.១២៥) |
| ***សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥*** | ១២.៨០៥.០០០ | ៥១.៨៦០.២៥០ | ៣.២៦១.៣៩៥ | ១៣.១៤៤.៥១៦ | - | ៦៤.១៣៤ | ១៦.០៦៦.៣៩៥ | ៦៥.០៦៨.៩០០ |
| ***សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦*** | | | | | | | | |
| សមតុល្យគិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ | ១២.៨០៥.០០០ | ៥១.៨៦០.២៥០ | ៣.២៦១.៣៩៥ | ១៣.១៤៤.៥១៦ | - | ៦៤.១៣៤ | ១៦.០៦៦.៣៩៥ | ៦៥.០៦៨.៩០០ |
| ចំណូលលម្អិត: | | | | | | | | |
| ខាតក្នុងឆ្នាំ | - | - | (២០១.២៤២) | (៨១៥.៦៣៣) | - | - | (២០១.២៤២) | (៨១៥.៦៣៣) |
| ការវាស់វែងកាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិកឡើងវិញ | - | - | (២.១៦១) | (៨.៧៥៩) | - | - | (២.១៦១) | (៨.៧៥៩) |
| ចំណូលលម្អិតផ្សេងៗ - លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | (៣៩.១៤៥) | - | (៣៩.១៤៥) |
| ខាតលម្អិតសរុបក្នុងឆ្នាំ | - | - | (២០៣.៤០៣) | (៨២៤.៣៩២) | - | (៣៩.១៤៥) | (២០៣.៤០៣) | (៨៦៣.៥៣៧) |
| ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន៖ | | | | | | | | |
| ដើមទុនបន្ថែមបានបង់ | ៥.០០០.០០០ | ២០.២៦៥.០០០ | - | - | - | - | ៥.០០០.០០០ | ២០.២៦៥.០០០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (២៤៦.៤៦៥) | - | - | - | - | - | (២៤៦.៤៦៥) |
| ***សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦*** | ១៧.៨០៥.០០០ | ៧១.៨៧៨.៧៨៥ | ៣.០៥៧.៩៩២ | ១២.៣២០.១២៤ | - | ២៤.៩៨៩ | ២០.៨៦២.៩៩២ | ៨៤.២២៣.៨៩៨ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ៣៨ ដល់ទំព័រទី ៥៧ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# របាយការណ៍លំហូរសាច់ប្រាក់

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់ | ២០១៦ | | ២០១៥ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| (ខាត)/ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ | | (២២៤.០៨៤) | (៩០៨.២១២) | ៣៦២.២១៣ | ១.៤៧០.៥៨៥ |
| *និយ័តកម្ម៖* | | | | | |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ | ១៥៥.៩៣១ | ៦៣១.៩៨៨ | ៩៨.៤៥៥ | ៣៩៩.៧២៧ |
| រំលស់ទ្រព្យសកម្មអរូបី | ៧ | ៤៦៨ | ១.៨៩៧ | ២៨៥ | ១.១៥៧ |
| ចំណាយការប្រាក់-សុទ្ធ | ២១ | (១០៣.៥៦១) | (៤១៩.៧៣៣) | (២០៤.១៥៨) | (៨២៨.៨៨១) |
| ខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | ១៥៧ | ៦៣៦ | ១៩៩ | ៨០៨ |
| | | (១៧១.០៨៩) | (៦៩៣.៤២៤) | ២៥៦.៩៩៤ | ១.០៤៣.៣៩៦ |
| *បម្រែបម្រួលដើមទុនបង្វិល៖* | | | | | |
| ប្រាក់ជំនួយត្រូវទទួល | | - | - | ១៣៧.៤៤៧ | ៥៥៨.០៣៥ |
| គណនីត្រូវទទួលផ្សេងៗ | | ៣៩.២២៣ | ១៥៨.៩៧១ | ៩៤.១២៩ | ៣៨២.១៦៤ |
| បង្គរ និងគណនីត្រូវបង់ផ្សេងៗ | | ២៣៤.៨៣៤ | ៩៥១.៧៨២ | ៨៧.២០០ | ៣៥៤.០៣២ |
| កាតព្វកិច្ចអត្ថប្រយោជន៍បុគ្គលិក | | ២៩.៦៩៩ | ១២០.៣៧០ | ២១.៦៩៨ | ៨៨.០៩៤ |
| សាច់ប្រាក់បានប្រើក្នុងប្រតិបត្តិការ | | ១៣២.៦៦៧ | ៥៣៧.៦៩៩ | ៥៩៧.៤៦៨ | ២.៤២៥.៧២១ |
| ពន្ធលើប្រាក់ចំណេញបានបង់ | | (៦២.២២៧) | (២៥២.២០៦) | (២២៨.១៤៥) | (៩២៦.២៦៩) |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ** | | ៧០.៤៤០ | ២៨៥.៤៩៣ | ៣៦៩.៣២៣ | ១.៤៩៩.៤៥២ |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ៦ | (២.៥៧៤.៩១២) | (១០.៤៣៦.១១៨) | (១.២៤៧.៥២៧) | (៥.០៦៤.៩៦០) |
| ការធ្វើមូលធនកម្មការប្រាក់ពីទ្រព្យសកម្មដែលមានគុណវុឌ្ឍិ | ៦ | (២៩.៦៦០) | (១២០.២១២) | - | - |
| ការទិញទ្រព្យសកម្មអរូបី | ៧ | (៣.៤៣០) | (១៣.៩០២) | - | - |
| ប្រាក់តម្កល់មានកាលកំណត់ | | (៦.១១៤.៤៦០) | (២៤.៧៨១.៩០៦) | (៦៤.៣៣១) | (២៦១.១៨៤) |
| ការប្រាក់បានទទួល | | ១៥៦.០១៤ | ៦៣២.៣២៥ | ១៩៥.៨៧៧ | ៧៩៥.២៦១ |
| ប្រាក់តម្កល់តាមច្បាប់ | | (៥៩.៤៥០) | (២៤០.៩៥១) | - | - |
| **សាច់ប្រាក់សុទ្ធបានប្រើក្នុងសកម្មភាពវិនិយោគ** | | (៨.៦២៥.៨៩៨) | (៣៤.៩៦០.៧៦៤) | (១.១១៥.៩៨១) | (៤.៥៣០.៨៨៣) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| សាច់ប្រាក់បានពីដើមទុនបន្ថែមបានបង់ | | ៥.០០០.០០០ | ២០.២៦៥.០០០ | - | - |
| សាច់ប្រាក់បានពីប្រាក់កម្ចី | | ៤.៨១៧.១១០ | ១៩.៥២៣.៧៤៧ | - | - |
| ការប្រាក់បានបង់ | | (៣២.៤៩៥) | (១៣១.៧០២) | - | |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន** | | ៩.៧៨៤.៦១៥ | ៣៩.៦៥៧.០៤៥ | - | - |
| កំណើន/(តំហយ)សាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ | | ១.២២៩.១៥៧ | ៤.៩៨១.៧៧៤ | (៧៤៦.៦៥៨) | (៣.០៣១.៤៣១) |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ | | ៩០.៥៣៣ | ៣៦៦.៦៥៩ | ៨៣៧.១៩១ | ៣.៤១១.៥៥៣ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (២០.៨៤៤) | - | (១៣.៤៦៣) |
| **សាច់ប្រាក់និងសាច់ប្រាក់សមមូលចុងឆ្នាំ** | ១១ | ១.៣១៩.៦៩០ | ៥.៣២៧.៥៨៩ | ៩០.៥៣៣ | ៣៦៦.៦៥៩ |

# កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

## ១. ព័ត៌មានទូទៅ

មុនថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រុមហ៊ុន (អតីត "ក្រុមហ៊ុន អេស៊ីលីដា ត្រេននីង សេនធ័រ លីមីតធីត") គឺជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត បង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមអាជ្ញាប័ណ្ណលេខ Co.១៣៣២KH/២០១១ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១១ ពីក្រសួងពាណិជ្ជកម្ម។ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រសួងពាណិជ្ជកម្មបានអនុម័តឲ្យក្រុមហ៊ុនប្តូរនាមករណ៍ក្រុមហ៊ុនទៅជា វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ ០០០០៣៨៣៦។ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជាបានចេញអាជ្ញាប័ណ្ណឲ្យក្រុមហ៊ុន តាមរយៈអនុក្រឹត្យលេខ ១៣អនក្រ.បក ដើម្បីប្រែក្លាយជាវិទ្យាស្ថាន។ ក្រុមហ៊ុនត្រូវបានកាន់កាប់ទាំងស្រុងដោយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាធនាគារពាណិជ្ជ ចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាបណ្តុះបណ្តាលដល់និស្សិតជាតិ និងអន្តរជាតិ នូវសេវាអប់រំកម្រិតឧត្តមសិក្សាប្រកបដោយគុណភាពខ្ពស់ថ្នាក់បរិញ្ញាបត្ររង បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ ដោយអនុលោមទៅតាមអនុក្រឹត្យដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាលកម្ពុជា និងអាជ្ញាធរពាក់ព័ន្ធ។ ក្រុមហ៊ុនក៏ចូលរួមចំណែកដោយឥរិយាបទវិជ្ជមាន ក្នុងការកសាងសមត្ថភាពរបស់ខ្លួន ដើម្បីបង្កើនគុណសម្បត្តិប្រកបដោយការប្រកួតប្រជែងក្នុងទីផ្សារពលកម្ម ក៏ដូចជាដើម្បីរៀបចំអាជីវកម្មរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។ ក្រុមហ៊ុនអាចនឹងផ្តល់សេវាផ្សេងៗបន្ថែមទៀត យោងទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

ការិយាល័យចុះបញ្ជីរបស់ក្រុមហ៊ុន មានទីតាំងស្ថិតនៅអគារលេខ ៥០ ផ្លូវ ៥១៦ កែងនឹងផ្លូវ ៣៣៥ ភូមិ ៦ សង្កាត់បឹងកក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ក្រុមហ៊ុនមានបុគ្គលិកចំនួន ៩៤នាក់ (ឆ្នាំ២០១៥ ៖ ១០១នាក់) ។

ក្រុមប្រឹក្សាភិបាល បានអនុម័តឲ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនេះនៅថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៧ ។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗ ដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញដូចខាងក្រោម។ គោលការណ៍គណនេយ្យទាំងនេះ ត្រូវបានអនុវត្តជាប្រចាំគ្រប់ឆ្នាំទាំងអស់ដែលបានបង្ហាញ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ ។

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

*(ក) ការអនុវត្តតាម CIFRS*

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យ បានប្រកាសដាក់ឲ្យប្រើប្រាស់ ស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទាំងស្រុងទៅតាមស្តង់ដារទាំងអស់ដែលផ្សព្វផ្សាយដោយ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ រាប់ទាំងបំណកស្រាយ និងវិសោធនកម្មផ្សេងៗ ដែលអាចកើតឡើងក្នុងកាលៈទេសៈផ្សេងៗ។ អង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន អនុលោមទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ។ អង្គភាពដែលមិនមានការទទួលខុសត្រូវជាសាធារណៈ ក៏អាចជ្រើសរើសអនុវត្ត CIFRS ដែរ ។

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង អនុលោមទៅតាម CIFRS និងត្រូវបានរៀបចំតាមវិធីសាស្ត្រថ្លៃដើម ។

របាយការណ៍នេះ គឺជារបាយការណ៍ហិរញ្ញវត្ថុដំបូងគេ របស់ក្រុមហ៊ុន ដែលត្រូវបានរៀបចំអនុលោមទៅតាម CIFRS។ របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ត្រូវបានក្រុមហ៊ុនរៀបចំដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម (ហៅកាត់ថា "CIFRS for SMEs")។ CIFRS for SMEs មានភាពខុសប្លែកគ្នាជាក់លាក់ពី CIFRS។ ក្រុមហ៊ុនបានផ្លាស់ប្តូរគម្រោងគណនេយ្យរបស់ខ្លួន ដើម្បីឲ្យស្របតាមគម្រោងគណនេយ្យក្រុមហ៊ុនមេរបស់ខ្លួន ។

ការផ្ទៀងផ្ទាត់ និងការពណ៌នា អំពីផលប៉ះពាល់នៃការផ្លាស់ប្តូរ ពី CIFRS for SMEs មកប្រើ CIFRS ទៅលើមូលធនលទ្ធផលលម្អិត លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ និងទ្រព្យសម្បត្តិ និងបរិក្ខាររបស់ក្រុមហ៊ុន ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ៥ ។

### ២.២ ស្តង់ដារគណនេយ្យថ្មី វិសោធកម្ម និងបំណកស្រាយ

*(ក) ស្តង់ដារគណនេយ្យថ្មី វិសោធកម្ម និងបំណកស្រាយ - ត្រូវអនុវត្តពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦*

ក្រុមហ៊ុនបានអនុវត្តស្តង់ដារ និងវិសោធនកម្មខាងក្រោមនេះ សម្រាប់របាយការណ៍ប្រចាំឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ៖

- គណនេយ្យសម្រាប់ការទិញអត្ថប្រយោជន៍ ក្នុងសម្ព័ន្ធប្រតិបត្តិការ - វិសោធនកម្ម IFRS 11 ។
- ការបញ្ជាក់អំពីវិធីសាស្ត្រ រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី ដែលអាចទទួលយកបាន - វិសោធនកម្ម IAS 16 និង IAS 38 ។
- ការកែលម្អប្រចាំឆ្នាំចំពោះ IFRSs 2012 - 2014 cycle និង
- ការលាតត្រដាងបឋម - វិសោធនកម្ម IAS 1 ។

ការអនុវត្តវិសោធនកម្មទាំងនេះ មិនមានផលប៉ះពាល់ណាមួយទៅលើការិយបរិច្ឆេទបច្ចុប្បន្នឬការិយបរិច្ឆេទមុនទេហើយក៏មិនទំនងជាមានផលប៉ះពាល់ទៅលើការិយបរិច្ឆេទអនាគតដែរ ។

*(ខ) ស្តង់ដារគណនេយ្យថ្មី វិសោធកម្ម និងបំណកស្រាយ ដែលក្រុមហ៊ុនមិនទាន់បានអនុវត្ត*

ក្រុមហ៊ុនមិនបានអនុវត្តស្តង់ដារគណនេយ្យថ្មី និងវិសោធនកម្មមួយចំនួនដែលបានចេញផ្សាយរួច ប៉ុន្តែមិនទាន់ចូលជាធរមានដូចខាងក្រោមនេះ មុនកាលកំណត់ទេ៖

| | |
|---|---|
| CIFRS 9 | ឧបករណ៍ហិរញ្ញវត្ថុ - ចូលជាធរមាន សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ឬការិយបរិច្ឆេទ គណនេយ្យបន្ទាប់ពីនេះ ។ |
| CIFRS 15 | ប្រាក់ចំណូលពីកិច្ចសន្យាជាមួយអតិថិជន - ចូលជាធរមាន សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើម នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ ។ |
| CIFRS 16 | ភតិសន្យា-ចូលជាធរមាន សម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំ ដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ឬការិយបរិច្ឆេទគណនេយ្យ បន្ទាប់ពីនេះ ។ |

ក្រុមហ៊ុនកំពុងតែស្ថិតនៅក្នុងដំណើរការ នៃការវាយតម្លៃអំពីផលប៉ះពាល់នៃស្តង់ដារគណនេយ្យថ្មី និងវិសោធនកម្មទាំងនេះលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្នុងការអនុវត្តលើកដំបូងនេះ។

## ២.៣ ការប្តូររូបិយប័ណ្ណ

### *(ក) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ*

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានវាស់វែងដោយប្រើរូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បងដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល" )។ក្រុមហ៊ុនថែរក្សាកំណត់ត្រាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោល និងជារូបិយប័ណ្ណសម្រាប់បង្ហាញរបស់ក្រុមហ៊ុន។ ប្រាក់ដុល្លារអាមេរិកត្រូវបានចាត់ទុកជារូបិយប័ណ្ណគោល ដោយសារវាមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការរបស់ក្រុមហ៊ុន ។

### *(ខ) ប្រតិបត្តិការ និងសមតុល្យ*

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗ ត្រូវបានកត់ត្រាប្តូរទៅជារូបិយប័ណ្ណគោលដោយប្រើអត្រាប្តូរប្រាក់នាកាលបរិច្ឆេទ នៃប្រតិបត្តិការ នោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណដែលបណ្តាលមកពីការទូទាត់ប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្មនិងបំណុលរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នាដំណាច់ឆ្នាំ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត ។

## ២.៤ ការបង្ហាញជាប្រាក់រៀល

របាយការណ៍ចំណេញ-ខាតនិងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរសាច់ប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាមធ្យមប្រចាំឆ្នាំ ។ ទ្រព្យសកម្មនិងបំណុលក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ ដែលបានបង្ហាញ និងមូលធនភាគទុនិក ត្រូវបានប្តូរតាមអត្រាបិទបញ្ជីនាកាលបរិច្ឆេទរាយការណ៍ ។

ក្រុមហ៊ុនបានប្រើអត្រាប្តូរប្រាក់ផ្លូវការ ដែលផ្សព្វផ្សាយដោយធនាគារជាតិនៃកម្ពុជា។ គិតត្រឹមកាលបរិច្ឆេទរាយការណ៍ អត្រាមធ្យមប្រចាំឆ្នាំ គឺ១ដុល្លារអាមេរិក ស្មើនឹង ៤.០៥៣រៀល (២០១៥ ៖ ១ដុល្លារអាមេរិកស្មើនឹង ៤.០៦០រៀល) ហើយអត្រានាថ្ងៃបិទបញ្ជីគឺ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៣៧រៀល (២០១៥ ៖ ១ដុល្លារអាមេរិកស្មើនឹង ៤.០៥០រៀល) ។

## ២.៥ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើនៅធនាគារ និងការវិនិយោគរយៈពេលខ្លីដែលមានលទ្ធភាពបង្វិលជាសាច់ប្រាក់បានលឿន និងមានកាលកំណត់ដើមរយៈពេលបីខែ ឬតិចជាងបីខែ ។

## ២.៦ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់បង្គរ និងការខាតបង្គរដែលបណ្តាលមកពីការចុះថយតម្លៃ។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗ ក្នុងការនាំយកទ្រព្យសកម្មនោះទៅកាន់ទីតាំង និងលក្ខខណ្ឌចាំបាច់ ដើម្បីឲ្យវាមានសមត្ថភាពបំពេញប្រតិបត្តិការទៅតាមការគ្រោងទុករបស់ថ្នាក់គ្រប់គ្រង។

ចំណាយនាពេលបន្ទាប់ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យសកម្មដាច់ ដោយឡែក តាមការសមស្រប តែនៅពេលដែលក្រុមហ៊ុនរំពឹងថា មានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះ នឹងហូរចូលមកក្នុងក្រុមហ៊ុន ហើយថ្លៃដើមនៃទ្រព្យនោះ អាចត្រូវបានវាស់វែងគួរឲ្យជឿជាក់បានតែប៉ុណ្ណោះ។ តម្លៃយោងរបស់គ្រឿងបន្លាស់ត្រូវបានគេឈប់កត់ត្រា។ រាល់ចំណាយលើការជួសជុល និងថែទាំទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផលលម្អិត ក្នុងឆ្នាំហិរញ្ញវត្ថុដែលប្រតិបត្តិការនោះកើតឡើង ។

ដីធ្លីមិនត្រូវបានដករំលស់ទេ។ ការធ្វើរំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរ ដើម្បីជម្រះថ្លៃដើម ឬតម្លៃរបស់ទ្រព្យសម្បត្តិ និងបរិក្ខារចេញពីបញ្ជី លើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់វា ដូចខាងក្រោម៖

| | |
|---|---|
| ការកែលម្អដីធ្លី | ៣ - ២០ ឆ្នាំ |
| ការកែលម្អទ្រព្យជួល | ៣ ឆ្នាំ |
| សង្ហារិម និងបរិក្ខារភ្ជាប់ | ៣ ឆ្នាំ |
| បរិក្ខារការិយាល័យ | ៣ - ៥ ឆ្នាំ |
| កុំព្យូទ័រ | ៣ ឆ្នាំ |
| យានយន្ត | ៣ - ៥ ឆ្នាំ |

តម្លៃសំណល់និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញ និងកែលម្អតម្រូវទៅតាមស្ថានភាពសមស្រប នាដំណាច់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ ។

តម្លៃយោងនៃទ្រព្យសកម្មណាមួយ ដែលលើសពីតម្លៃដែលអាចស្រង់មកវិញបាន ត្រូវបានកត់ត្រាបន្ថយភ្លាមឱ្យនៅត្រឹមតម្លៃដែលអាចស្រង់មកវិញបានរបស់វា។

ចំណេញ និងខាតបណ្តាលពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារណាមួយចេញត្រូវបានកំណត់ដោយការប្រៀបធៀបសាច់ប្រាក់បានពីការលក់ និងតម្លៃយោងនៃទ្រព្យសកម្មនោះ ហើយត្រូវបានកត់ត្រានៅក្នុងខ្ទង់ -ចំណេញ/(ខាត)ផ្សេងៗ-សុទ្ធ- ក្នុងរបាយការណ៍ចំណេញ-ខាត។

## ២.៧ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ ដែលបានទិញនិងចំណាយពាក់ព័ន្ធផ្សេងៗ ត្រូវបានរាយការណ៍តាមថ្លៃដើម ដករំលស់បង្គរ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃបង្គរ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។ រំលស់ត្រូវបានគណនា ដោយប្រើវិធីសាស្ត្ររំលស់ថេរ ដើម្បីបែងចែកថ្លៃដើមលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់វាក្នុងរយៈពេល ៥ឆ្នាំ ។

## ២.៨ ការថយចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានធ្វើរំលស់ទេ ហើយត្រូវបានធ្វើតេស្តប្រចាំឆ្នាំ ដើម្បីរកការថយចុះតម្លៃរបស់វា។ ទ្រព្យសកម្មដែលត្រូវធ្វើរំលស់ត្រូវបានត្រួតពិនិត្យរកការថយចុះតម្លៃ នៅពេល

មានព្រឹត្តិការណ៍ ឬបម្រែបម្រួលកាលៈទេសៈណាមួយ ចង្អុលបង្ហាញថាតម្លៃយោងរបស់វា មិនអាចទទួលបានមកវិញបាន។ ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រានៅពេលដែលតម្លៃយោងរបស់ទ្រព្យសកម្មនោះលើសពីតម្លៃដែលអាចយកមកវិញបាន។ តម្លៃដែលអាចយកមកវិញបាន គឺជាតម្លៃណាមួយដែលខ្ពស់ជាងរវាងតម្លៃសមស្របនៃទ្រព្យសកម្មនោះ ដកចំណាយក្នុងការលក់ និងតម្លៃបានពីការប្រើប្រាស់ទ្រព្យសកម្មនោះ។ ក្នុងការប៉ាន់ស្មានរកការថយចុះតម្លៃ ទ្រព្យសកម្មទាំងនេះ ត្រូវបានបែងចែកជាក្រុមតូចៗ តាមដែលអាចធ្វើទៅបាន (CGUs) ដើម្បីកំណត់ពីលំហូរសាច់ប្រាក់ដាច់ដោយឡែករបស់វានីមួយៗ ។

## ២.៩ ទ្រព្យសកម្មហិរញ្ញវត្ថុ

### ២.៩.១ ការធ្វើចំណាត់ថ្នាក់

ក្រុមហ៊ុនធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួន ជាឥណទាន គណនីត្រូវទទួល និងទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់។ ការធ្វើចំណាត់ថ្នាក់គឺអាស្រ័យទៅលើគោលបំណង ដែលបានទិញទ្រព្យសកម្មហិរញ្ញវត្ថុទាំងនោះ ។ ថ្នាក់គ្រប់គ្រងបានកំណត់ការធ្វើចំណាត់ថ្នាក់ ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនពេលធ្វើការកត់ត្រាដំបូង ។

*(i) ឥណទាន និងគណនីត្រូវទទួល*

ឥណទាន និងគណនីត្រូវទទួល គឺជាទ្រព្យសកម្មហិរញ្ញវត្ថុមិននិស្សន្ទ (non-derivative) ដែលមានកាលកំណត់សងប្រាក់ថេរ ឬអាចកំណត់បាន ហើយមិនដាក់លក់នៅលើទីផ្សារសកម្ម ។ គណនីទាំងនេះត្រូវបានកត់ត្រានៅក្នុងទ្រព្យសកម្មរយៈពេលខ្លី លើកលែងតែវាមានកាលកំណត់ លើសពី១២ខែបន្ទាប់ពីកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នោះវាត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មរយៈពេលវែង ។ ឥណទាន និងគណនីអតិថិជនរបស់ក្រុមហ៊ុនរួមមាន "សាច់ប្រាក់ និងសាច់ប្រាក់សមមូល" និង"ប្រាក់បញ្ញើមានកាលកំណត់" នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

*(ii) ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់*

ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់ គឺជាទ្រព្យសកម្មហិរញ្ញវត្ថុមិននិស្សន្ទ (non-derivative) ដែលត្រូវបានកំណត់ក្នុងប្រភេទនេះ ឬមិនត្រូវបានចាត់ថ្នាក់ក្នុងប្រភេទផ្សេង ។ វាត្រូវបានបញ្ចូលនៅក្នុងទ្រព្យសកម្មរយៈពេលវែង លើកលែងតែការវិនិយោគនោះផុតកំណត់ ឬថ្នាក់គ្រប់គ្រងមានបំណងនឹងលក់វាចេញក្នុងរយៈពេល១២ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ។

### ២.៩.២ ការកត់ត្រា និងការវាស់វែង

*(i) ការវាស់វែងបឋម*

ការទិញ និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុជាប្រចាំ ត្រូវបានកត់ត្រានាកាលបរិច្ឆេទពាណិជ្ជកម្ម ជាកាលបរិច្ឆេទដែលក្រុមហ៊ុនសន្យាទិញ ឬលក់ទ្រព្យសកម្ម ។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្របបូកនឹងចំណាយប្រតិបត្តិការ ហើយទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនកត់ត្រាតាមតម្លៃសមស្រប ត្រូវបានកត់ត្រាក្នុងចំណេញ-ខាត។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគេឈប់កត់ត្រា នៅពេលដែលក្រុមហ៊ុនមានសិទ្ធិទទួលលំហូរសាច់ប្រាក់ពីការវិនិយោគដែលផុតកំណត់ ឬការវិនិយោគដែលបានផ្ទេររាល់ហានិភ័យជាសារវន្ត និងបានផ្ទេរកម្មសិទ្ធិទាំងអស់ ។

*(ii) ការវាស់វែងបន្ទាប់*

ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់ ត្រូវបានវាស់វែងជាបន្ទាប់តាមតម្លៃសមស្រប លើកលែងតែការវិនិយោគក្នុងឧបករណ៍មូលធន ដែលមិនបានដាក់លក់លើទីផ្សារសកម្ម និងការវិនិយោគដែលតម្លៃសមស្របរបស់វា មិនអាចត្រូវបានវាស់វែងគួរឲ្យទុកចិត្តបាន ក្នុងករណីនេះការវិនិយោគទាំងនេះត្រូវបានរាយការណ៍តាមថ្លៃដើម។

ឥណទាន និងគណនីត្រូវទទួល ត្រូវបានរាយការណ៍ជាបន្ទាប់តាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្រ្តអត្រាការប្រាក់មានប្រសិទ្ធភាព។ នៅរៀងរាល់កាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ ក្រុមហ៊ុនវាយតម្លៃថាតើមានភស្តុតាងជាក់ស្តែងបង្ហាញថាទ្រព្យសកម្មហិរញ្ញវត្ថុមួយ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុមានការថយចុះតម្លៃដែរឬទេ (កំណត់សម្គាល់ ២.១១)។

## ២.១០ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួនសុទ្ធបន្ទាប់ពីកាត់កងត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលមានសិទ្ធិស្របច្បាប់ក្នុងការកាត់កងចំនួនដែលបានកត់ត្រា ហើយមានបំណងធ្វើការទូទាត់តាមមូលដ្ឋានសុទ្ធ ឬទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

## ២.១១ ការថយចុះតម្លៃ នៃទ្រព្យសកម្មហិរញ្ញវត្ថុ

ក្រុមហ៊ុនធ្វើការវាយតម្លៃ នៅរៀងរាល់កាលបរិច្ឆេទរបាយការណ៍នីមួយៗ ដើម្បីកំណត់ថា តើមានភស្តុតាងជាក់ស្តែងបង្ហាញថា ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុមានការថយចុះតម្លៃឬទេ។ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាថយចុះតម្លៃ ហើយមានការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ តែនៅពេលដែលមានភស្តុតាងជាក់ស្តែងបង្ហាញពីការថយចុះតម្លៃ ដែលជាលទ្ធផលបណ្តាលមកពីព្រឹត្តិការណ៍មួយ ឬព្រឹត្តិការណ៍ច្រើនដែលបានកើតឡើង បន្ទាប់ពីការកត់ត្រាទ្រព្យសកម្មបឋម (ហៅថា "ព្រឹត្តិការណ៍ខាតបង់") ហើយព្រឹត្តិការណ៍ខាតបង់នោះ (ឬព្រឹត្តិការណ៍នានា) មានផលប៉ះពាល់ទៅលើលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគតរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ ដែលអាចប៉ាន់ស្មានគួរឲ្យជឿជាក់បាន។

## ២.១២ បង្គរ និងគណនីត្រូវសងផ្សេងៗ

បង្គរ និងគណនីត្រូវសងផ្សេងៗ ត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប ហើយបន្ទាប់មកទៀតវាត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ដោយប្រើវិធីសាស្រ្តការប្រាក់ដែលមានប្រសិទ្ធភាព។

## ២.១៣ ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានកត់ត្រាជាបឋមតាមតម្លៃសមស្រប កាត់កងនឹងចំណាយប្រតិបត្តិការដែលបានកើតឡើង។ បន្ទាប់មកប្រាក់កម្ចីត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់។ ចំនួនលម្អៀងរវាងសាច់ប្រាក់ (កាត់កងចំណាយប្រតិបត្តិការ) និងចំនួនត្រូវបង្វិលសង ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ ក្នុងរយៈពេលនៃប្រាក់កម្ចីនោះ ដោយប្រើវិធីសាស្រ្តការប្រាក់ដែលមានប្រសិទ្ធភាព ។

ប្រាក់កម្ចីត្រូវបានចាត់ថ្នាក់ជាបំណុលរយៈពេលខ្លី លុះត្រាតែក្រុមហ៊ុនមានសិទ្ធិដោយឥតលក្ខខណ្ឌ ក្នុងការពន្យារពេលទូទាត់បំណុលយ៉ាងហោចណាស់ ១២ខែ បន្ទាប់ពីកាលបរិច្ឆេទរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

## ២.១៤ ចំណាយប្រាក់កម្ចី

ចំណាយប្រាក់កម្ចីទូទៅ និងចំណាយជាក់លាក់ក្នុងការទិញ ការសាងសង់ ឬការផលិតទ្រព្យសកម្មដែលមានគុណវុឌ្ឍិជាទ្រព្យសកម្មដែលត្រូវចំណាយពេលវេលាច្រើនក្នុងការសាងសង់បញ្ចប់ សម្រាប់ដាក់ប្រើប្រាស់ ឬដាក់លក់ ត្រូវបានបន្ថែមទៅក្នុងថ្លៃដើមនៃទ្រព្យសកម្មទាំងនោះ រហូតដល់ពេលដែលទ្រព្យសកម្មទាំងនោះមានភាពរួចរាល់ ។

រាល់ចំណាយលើប្រាក់កម្ចីទាំងអស់ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ-ខាត នៅក្នុងការិយបរិច្ឆេទដែលវាបានកើតឡើង ។

## ២.១៥ ពន្ធលើប្រាក់ចំណេញក្នុងគ្រា និងពន្ធពន្យារ

បន្ទុកពន្ធក្នុងឆ្នាំរួមមានពន្ធលើប្រាក់ចំណេញ និងពន្ធពន្យារ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិត លើកលែងតែវាពាក់ព័ន្ធទៅនឹងខ្ទង់ផ្សេងៗដែលបានកត់ត្រានៅក្នុងលទ្ធផលលម្អិតផ្សេងៗ ឬកត់ត្រាដោយផ្ទាល់ក្នុង

មូលធន។ ក្នុងករណីនេះ ពន្ធក៏ត្រូវបានកត់ត្រាក្នុងលទ្ធផលលម្អិតផ្សេងៗ ឬកត់ត្រាដោយផ្ទាល់ក្នុងមូលធន ។

ពន្ធលើប្រាក់ចំណេញក្នុងគ្រា ត្រូវគណនាតាមមូលដ្ឋានច្បាប់ពន្ធដែលបានអនុម័តរួចជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំគិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នៅក្នុងប្រទេសកម្ពុជា ។

ពន្ធពន្យារលើប្រាក់ចំណេញត្រូវបានកត់ត្រា តាមចំនួនលម្អៀងបណ្តោះអាសន្នដែលកើតមានរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និងតម្លៃយោងរបស់វា នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ពន្ធពន្យារលើប្រាក់ចំណេញ ត្រូវបានកំណត់តាមអត្រាពន្ធ និងច្បាប់ផ្សេងៗ ដែលបានអនុម័តរួចជាស្ថាពរ ឬអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទរបាយការណ៍ ។

ពន្ធពន្យារទ្រព្យសកម្ម និងបំណុលពន្ធពន្យារត្រូវបានកាត់កង ប្រសិនបើក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីកាត់កងបំណុលពន្ធក្នុងគ្រា ជាមួយនឹងពន្ធទ្រព្យសកម្ម ហើយបើវាទាក់ទងទៅនឹងពន្ធលើប្រាក់ចំណេញ ដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយ ទៅលើអង្គភាពជាប់ពន្ធដូចគ្នា ។

ពន្ធពន្យារទ្រព្យសកម្ម ត្រូវបានកត់ត្រាតែនៅពេលដែលមានភាពប្រាកដប្រជាថា នឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដែលអាចប្រើប្រាស់លម្អៀងបណ្តោះអាសន្ននេះបាន។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវបានកាត់បន្ថយនៅពេលដែលមិនមានភាពប្រាកដថា នឹងមានអត្ថប្រយោជន៍ពន្ធពាក់ព័ន្ធត្រូវបានកត់ត្រា ។

## ២.១៦ សំវិធានធន

សំវិធានធនត្រូវបានកត់ត្រា នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចផ្លូវច្បាប់នាពេលបច្ចុប្បន្ន ឬកាតព្វកិច្ចដែលកើតចេញពីលទ្ធផលនៃព្រឹត្តការណ៍អតីតកាលដែលទំនងជាតម្រូវឲ្យក្រុមហ៊ុនធ្វើការដោះស្រាយ និងទូទាត់កាតព្វកិច្ចទាំងនោះ ហើយចំនួនទឹកប្រាក់អាចប៉ាន់ស្មានដែលគួរឲ្យជឿជាក់បាន។ ក្រុមហ៊ុនមិនកត់ត្រាសំវិធានធនចំពោះការខាតបង់ពីប្រតិបត្តិការនាពេលអនាគតទេ ។

នៅពេលដែលមានកាតព្វកិច្ចប្រហាក់ប្រហែលគ្នាច្រើន វាទំនងជាតម្រូវឲ្យមានលំហូរសាច់ប្រាក់ដើម្បីទូទាត់ ហើយត្រូវបានកំណត់ដោយពិនិត្យទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចទាំងមូល។ សំវិធានធនត្រូវបានកត់ត្រា ទោះបីជាលំហូរចេញនៃខ្ទង់ណាមួយ ដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ កាតព្វកិច្ចដូចគ្នានោះ មានចំនួនតិចតួចក៏ដោយ ។

សំវិធានធន ត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃចំណាយដែលរំពឹងថាត្រូវទូទាត់កាតព្វកិច្ចទាំងនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលាទឹកប្រាក់ និងហានិភ័យជាក់លាក់ផ្សេងៗចំពោះកាតព្វកិច្ចនោះ។ កំណើនសំវិធានធនបណ្តាលមកពីពេលវេលាដែលកន្លងហួស ត្រូវបានកត់ត្រាជាចំណាយការប្រាក់ ។

## ២.១៧ អត្ថប្រយោជន៍បុគ្គលិក

### (ក) មូលនិធិសោធននិវត្តបុគ្គលិក

ក្រុមហ៊ុនផ្តល់ជូនបុគ្គលិករបស់ខ្លួន នូវមូលនិធិសោធននិវត្ត ដែលជាគម្រោងវិភាគទានមានកំណត់។ មូលនិធិនេះបានមកពីវិភាគទានប្រចាំខែ ដែលត្រូវបានកំណត់ឡើង អាស្រ័យទៅតាមប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិកម្នាក់ក្នុងនោះក្រុមហ៊ុនផ្តល់វិភាគទានចំនួន ១0% (២០១៥៖ ១0%) ហើយបុគ្គលិកផ្តល់វិភាគទានចំនួន ៥% (២០១៣៖ ៥%) នៃប្រាក់បៀវត្សរ៍របស់បុគ្គលិកម្នាក់ៗ ។

មូលនិធិនេះត្រូវបានរក្សាដោយធនាគារ អេស៊ីលីដា ភីអិលស៊ី។ វិភាគទានរបស់ក្រុមហ៊ុន ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍ចំណេញ-ខាត នៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុដែលពាក់ព័ន្ធ។ នៅពេលដែលក្រុមហ៊ុនបានបង់វិភាគទានទៅ ធនាគារ អេស៊ីលីដា ភីអិលស៊ី ក្រុមហ៊ុនមិនជាប់កាតព្វកិច្ចបង់ប្រាក់ផ្សេងទៀតទេ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី នឹងបង់ប្រាក់សោធននិវត្តន៍នេះទាំងស្រុងជូនបុគ្គលិក នៅពេលដែលពួកគាត់បញ្ចប់កិច្ចសន្យាការងារជាមួយក្រុមហ៊ុន ។

### (ខ) អត្ថប្រយោជន៍ពេលចូលនិវត្ត

នៅពេលដល់អាយុចូលនិវត្ត ក្រុមហ៊ុនផ្តល់ជូនបុគ្គលិកពេញសិទ្ធិរបស់ខ្លួននូវគម្រោងអត្ថប្រយោជន៍ពេលចូលនិវត្ត ដែលមិនមានមូលនិធិដាច់ដោយឡែកដូចខាងក្រោម៖

- បុគ្គលិកដែលមានអតីតភាពការងារ ជាមួយក្រុមហ៊ុន ចំនួន១៥ឆ្នាំ ឬច្រើនជាងនេះ ហើយត្រូវដល់អាយុចូលនិវត្តនៅអាយុ៥៨ឆ្នាំចំពោះអ្នកគ្មានជំនាញ និង៦០ឆ្នាំចំពោះអ្នកមានជំនាញ នឹងត្រូវទទួលបានអត្ថប្រយោជន៍ ពេលចូលនិវត្តស្មើនឹងប្រាក់បៀវត្សរ៍ចំនួន១២ខែ នៃប្រាក់បៀវត្សរ៍មូលដ្ឋានចុងក្រោយ ។
- បុគ្គលិកដែលមានអតីតភាពការងារ ជាមួយក្រុមហ៊ុន ចំនួន១៥ឆ្នាំ ឬច្រើនជាងនេះ ហើយត្រូវដល់អាយុចូលនិវត្តមុននៅអាយុ៥៥ឆ្នាំ ចំពោះអ្នកគ្មានជំនាញ និង៥៧ឆ្នាំចំពោះអ្នកមានជំនាញ នឹងត្រូវទទួលបានអត្ថប្រយោជន៍ ពេលចូលនិវត្តស្មើនឹងប្រាក់បៀវត្សរ៍ ចំនួន៦ខែ នៃប្រាក់បៀវត្សរ៍មូលដ្ឋានចុងក្រោយ។

ក្រុមហ៊ុនមិនបានរក្សាទុកមូលនិធិនេះដាច់ដោយឡែកទេ ហើយបំណុលត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ទៅតាមតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចដែលបានកំណត់ នាកាលបរិច្ឆេទរាយការណ៍ ដោយប្រើវិធីសាស្ត្រ Projected Unit Credit ដើម្បីប៉ាន់ស្មានចំណាយចុងក្រោយបំផុតរបស់ក្រុមហ៊ុនទៅលើអត្ថប្រយោជន៍ដែលបុគ្គលិកត្រូវទទួលបាន ជាថ្នូរនឹងសេវាដែលពួកគាត់បានបំពេញជូនក្រុមហ៊ុនក្នុងពេលបច្ចុប្បន្ន និងក្នុងពេលកន្លងមក។ ក្រុមហ៊ុនដាក់បន្ទុកចំណាយអត្ថប្រយោជន៍នេះ ក្នុងការិយបរិច្ឆេទណាដែលការបង់អត្ថប្រយោជន៍ពេលចូលនិវត្តនេះបានកើតឡើង។ កាតព្វកិច្ចនោះកើតឡើងនៅពេលដែលបុគ្គលិកបានបំពេញសេវា ជាថ្នូរដើម្បីទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្ត ដែលក្រុមហ៊ុនរំពឹងថា ត្រូវបង់ក្នុងការិយបរិច្ឆេទរាយការណ៍ នាពេលអនាគត ។

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្ត ត្រូវបានកំណត់ដោយធ្វើអប្បហារលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគត ដោយយោងទៅតាមអត្រាការប្រាក់បញ្ញើមានកាលកំណត់រយៈពេល៦ឆ្នាំរបស់ក្រុមហ៊ុនមេ ដោយសារមិនមានទីផ្សារសញ្ញាប័ណ្ណទីផ្សារ ឬសញ្ញាប័ណ្ណរដ្ឋដែលមានគុណភាពខ្ពស់នៅក្នុងប្រទេសកម្ពុជា ។

ចំណេញនិងខាតពីការវាយតម្លៃអត្ថប្រយោជន៍ពេលចូលនិវត្ត ដែលកើតពីបទពិសោធន៍និយ័តកម្ម និងបម្រែបម្រួលក្នុងការសន្មត ការវាយតម្លៃអត្ថប្រយោជន៍ពេលចូលនិវត្ត ត្រូវបានកត់ត្រាជាបន្ទុក ឬជាឥណទាននៅក្នុងចំណេញ-ខាតក្នុងរបាយការណ៍លទ្ធផលលម្អិត ក្នុងការិយបរិច្ឆេទដែលវាបានកើតឡើង។ ចំណាយដែលពាក់ព័ន្ធនឹងការផ្តល់អត្ថប្រយោជន៍ទាំងនេះ ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លម្អិតផ្សេងៗ ដើម្បីបែងចែកចំណាយទៅតាមការិយបរិច្ឆេទនៃកិច្ចសន្យាការងារ ដែលក្រុមហ៊ុនត្រូវបង់អត្ថប្រយោជន៍នេះ។

ចំណាយលើសេវាក្នុងអតីតកាល ត្រូវបានកត់ត្រាជាបន្ទាន់នៅក្នុងរបាយការណ៍ចំណេញ-ខាត។

## ២.១៨ ការទទួលស្គាល់ចំណូល

ចំណូលត្រូវបានវាស់វែងតាមតម្លៃសមស្រប នៃសាច់ប្រាក់ដែលបានទទួល ឬសាច់ប្រាក់ដែលត្រូវទទួល ចំពោះការផ្តល់សេវាផ្សេងៗ នៅក្នុងដំណើរការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ។

ក្រុមហ៊ុនកត់ត្រាចំណូល នៅពេលដែលចំនួននៃប្រាក់ចំណូលនោះអាចវាស់វែងគួរឲ្យទុកចិត្តបាន និងនៅពេលដែលមានភាពប្រាកដថា មានអត្ថប្រយោជន៍ សេដ្ឋកិច្ចនាពេលអនាគត នឹងកើតមានចំពោះក្រុមហ៊ុន។ ចំណូល

ទទួលបានពីសេវាបណ្តុះបណ្តាល និងសេវាប្រឹក្សា ត្រូវបានកត់ត្រានៅពេលដែលក្រុមហ៊ុនបានបំពេញសេវានោះរួចរាល់ ។

### ២.១៩ ចំណូលការប្រាក់

ចំណូលការប្រាក់ត្រូវបានកត់ត្រា នៅក្នុងរបាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ តាមមូលដ្ឋានសមមាត្រពេលវេលា ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព ។

### ២.២០ ភតិសន្យា

ភតិសន្យាដែលហានិភ័យ និងផលលើកម្មសិទ្ធិ ត្រូវបានរក្សាដោយភាគីម្ចាស់ជួល ត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ការទូទាត់ភតិសន្យាប្រតិបត្តិ (ដកអត្ថប្រយោជន៍ផ្សេងៗដែលបានទទួលពីភាគីម្ចាស់ជួល) ត្រូវបានកត់ត្រា ជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផលលម្អិត តាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យានោះ ។

## ៣. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

### ៣.១ កត្តាហានិភ័យហិរញ្ញវត្ថុផ្សេងៗ

សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន ត្រូវប្រឈមមុខនឹងហានិភ័យផ្សេងៗ ដូចជា ហានិភ័យទីផ្សារ (រួមមាន ហានិភ័យការប្តូររូបិយប័ណ្ណ ហានិភ័យតម្លៃ និងហានិភ័យអត្រាការប្រាក់) ហានិភ័យឥណទាន និងហានិភ័យសន្ទនីយ។ ក្រុមហ៊ុនមិនប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទ (derivative financial instruments) ដូចជាកិច្ចសន្យាប្តូររូបិយប័ណ្ណ (foreign exchange contracts) និងការផ្តោះប្តូរ អត្រាការប្រាក់ (interest rate swap) ដើម្បីការពារហានិភ័យរបស់ខ្លួននោះទេ ។

#### (ក) ហានិភ័យទីផ្សារ

#### *(i) ហានិភ័យការប្តូររូបិយប័ណ្ណ*

ក្រុមហ៊ុនមិនប្រឈមមុខជាសារវន្ត ចំពោះហានិភ័យការប្តូរបិយប័ណ្ណទេ ។ ប្រតិបត្តិការគណនេយ្យ និងកំណត់ត្រាគណនេយ្យរបស់ក្រុមហ៊ុន ភាគច្រើនកត់ត្រាជាប្រាក់ដុល្លារអាមេរិក នៅក្នុងដំណើរការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន។ ក្រុមហ៊ុនមិនមានគោលការណ៍ ដើម្បីការពាររូបិយប័ណ្ណ ធៀបនឹងការប្រែប្រួលក្នុងការប្តូររូបិយប័ណ្ណទេ ។

#### *(ii) ហានិភ័យតម្លៃ*

ក្រុមហ៊ុនមិនមានហានិភ័យតម្លៃទំនិញ ឬហានិភ័យតម្លៃមូលបត្រទេ ដោយសារទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់ ត្រូវបានវាស់វែងតាមថ្លៃដើម។

#### *(iii) ហានិភ័យអត្រាការប្រាក់*

ហានិភ័យអត្រាការប្រាក់គឺជាហានិភ័យ ដែលបម្រែបម្រួលនាពេលអនាគតនៃអត្រាការប្រាក់ទីផ្សារ នឹងធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន។ ក្រុមហ៊ុនបានខ្ចីប្រាក់ពីគ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងអត្រាការប្រាក់ថេរ ដូចនេះមិនបណ្តាលឲ្យមានហានិភ័យអត្រាការប្រាក់ជាសារវន្តទេ ។

ដោយសារក្រុមហ៊ុនមិនមានទ្រព្យសកម្ម និងបំណុលដែលមានការប្រាក់ជាសារវន្ត ដូចនេះប្រាក់ចំណូល និងលំហូរសាច់ប្រាក់ប្រតិបត្តិការរបស់ក្រុមហ៊ុនមានឯករាជ្យពេញលេញពីបម្រែបម្រួលអត្រាការប្រាក់លើទីផ្សារ ។

ក្រុមហ៊ុនមិនមានការផ្តោះប្តូរអត្រាការប្រាក់ ឬការការពារផ្សេងៗ(Hedges) ទេ ដោយសារក្រុមប្រឹក្សាភិបាល ជឿជាក់ថាហានិភ័យអត្រាការប្រាក់ នឹងមិនមានទំហំជាសារវន្តទេ ។

#### (ខ) ហានិភ័យឥណទាន

ឧបករណ៍ហិរញ្ញវត្ថុដែលមានសក្តានុពល អាចធ្វើឲ្យក្រុមហ៊ុនមានការប្រមូលផ្តុំហានិភ័យឥណទាន ភាគច្រើនមានសាច់ប្រាក់ និងសាច់ប្រាក់សមមូល និងប្រាក់បញ្ញើមានកាលកំណត់។ ក្រុមហ៊ុនមិនប្រឈមមុខនឹងហានិភ័យឥណទានទេ ដោយសារក្រុមហ៊ុនមិនមានគណនីត្រូវទទួលផ្សេងៗជាសារវន្តទេ គិតត្រឹម កាលបរិច្ឆេទរាយការណ៍នេះ ។

ដើម្បីធ្វើឲ្យហានិភ័យឥណទានលើសាច់ប្រាក់ និងសាច់ប្រាក់សមមូល និងប្រាក់បញ្ញើមានកាលកំណត់ ស្ថិតក្នុងកម្រិតអប្បបរមា ក្រុមហ៊ុនបានតម្កល់ប្រាក់បញ្ញើរបស់ខ្លួន ជាមួយក្រុមហ៊ុនមេតែប៉ុណ្ណោះ ។ ក្រុមប្រឹក្សាភិបាលជឿជាក់ថា ហានិភ័យឥណទានអតិបរមារបស់ក្រុមហ៊ុនត្រូវបានកម្រិត ។

ការគ្រប់គ្រងហានិភ័យសន្ទនីយដែលប្រុងប្រយ័ត្ន រួមមានការរក្សាទុកសាច់ប្រាក់ឲ្យបានគ្រប់គ្រាន់ មានមូលបត្រអាចលក់លើទីផ្សារបាន និងមានមូលនិធិគ្រប់គ្រាន់ ដើម្បីបំពេញកាតព្វកិច្ចសងបំណុលរបស់ខ្លួននៅថ្ងៃផុតកំណត់ និងដើម្បីបញ្ចប់ស្ថានភាពទីផ្សារ ។

ក្រុមហ៊ុនមិនមានឥណទានជាមួយគ្រឹះស្ថានហិរញ្ញវត្ថុណាមួយទេ ព្រោះក្រុមហ៊ុនបានពឹងផ្អែកទាំងស្រុងទៅលើក្រុមហ៊ុនមេរបស់ខ្លួន តាមរយៈការចូលរួមដើមទុន ។

តារាងខាងក្រោមនេះចាត់ថ្នាក់បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ទៅតាមកាលកំណត់របស់វា អាស្រ័យទៅតាមកាលរយៈពេលដែលនៅសល់ គិតត្រឹមកាលបរិច្ឆេទ របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រហូតដល់កាលបរិច្ឆេទផុតកំណត់។ ចំនួនដែលបានលាតត្រដាងនៅក្នុងតារាង គឺជាលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យាមិនធ្វើអប្បហារ ។






ការចូលរួមតាំងពិព័រណ៍អប់រំ របស់វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា នៅពហុកីឡដ្ឋានជាតិ អូឡាំពិក

| | តិចជាង១ខែ | ពី១ខែ-៣ខែ | ពី៣ខែ-១២ខែ | លើសពី១២ខែឡើងទៅ | សរុប |
|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | | | |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១១៩.៦៩០ | - | - | - | ១១៩.៦៩០ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១.៦១៣.២២០ | ៣.២៤៤.៤៦៦ | ៥.៤១៧.១០៧ | - | ១០.២៧៤.៧៩៣ |
| | ១.៧៣២.៩១០ | ៣.២៤៤.៤៦៦ | ៥.៤១៧.១០៧ | - | ១០.៣៩៤.៤៨៣ |
| **បំណុល** | | | | | |
| បង្គរ និងគណនីត្រូវសងផ្សេងៗ | ១២៨.៥៨០ | ៤.០២៥ | ១០៥.៩១៩ | - | ២៣៨.៥២៤ |
| ប្រាក់កម្ចី | - | - | ៣៧៧.០៤៤ | ៦.៧៦៤.៥៨២ | ៧.១៤១.៦២៦ |
| | ១២៨.៥៨០ | ៤.០២៥ | ៤៨២.៩៦៣ | ៦.៧៦៤.៥៨២ | ៧.៣៨០.១៥០ |
| **គម្លាតសន្ទនីយសុទ្ធ** | ១.៦០៤.៣៣០ | ៣.២៤០.៤៤១ | ៤.៩៣៤.១៤៤ | (៦.៧៦៤៥៨២) | ៣.០១៤.៣៣៣ |
| **សមមូលនឹងពាន់រៀល** | ៦.៤៧៦.៦៨០ | ១៣.០៨១.៦៦០ | ១៩.៩១៩.១៣៩ | (២៧.៣០៨.៦១៨) | ១២.១៦៨.៨៦១ |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | | | | | |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៩០.៥៣៣ | - | - | - | ៩០.៥៣៣ |
| ប្រាក់បញ្ញើមានកាលកំណត់ | ២៥៧.៧៤២ | ២.៦១១.០២៤ | - | - | ២.៨៦៨.៧៦៦ |
| | ៣៤៨.២៧៥ | ២.៦១១.០២៤ | - | - | ២.៩៥៩.២៩៩ |
| **បំណុល** | | | | | |
| បង្គរ និងគណនីត្រូវសងផ្សេងៗ | ១.៨៥៥ | ២៩០.៣៧៥ | - | - | ២៩២.២៣០ |
| | ១.៨៥៥ | ២៩០.៣៧៥ | - | - | ២៩២.២៣០ |
| **គម្លាតសន្ទនីយសុទ្ធ** | ៣៤៦.៤២០ | ២.៣២០.៦៤៩ | - | - | ២.៦៦៧.០៦៩ |
| **សមមូលនឹងពាន់រៀល** | ១.៤០៣.០០១ | ៩.៣៩៨.៦២៨ | - | - | ១០.៨០១.៦២៩ |

## ៣.២ ការគ្រប់គ្រងហានិភ័យដើមទុន

ទិសដៅរបស់ក្រុមហ៊ុនក្នុងការគ្រប់គ្រងដើមទុន គឺដើម្បីការពារលទ្ធភាពរបស់ ខ្លួនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ដើម្បីបន្តផ្តល់ផលប្រយោជន៍ជូនភាគហ៊ុននិក និងភាគីពាក់ព័ន្ធផ្សេងទៀត និងរក្សារចនាសម្ព័ន្ធមូលធនល្អបំផុត ដើម្បីកាត់បន្ថយ ចំណាយដើមទុន។

ក្រុមហ៊ុនបានចុះបញ្ជីដើមទុនរបស់ខ្លួនជាមួយក្រសួងពាណិជ្ជកម្ម។ គិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ក្រុមហ៊ុនបានបង្កើនដើមទុនរហូតដល់ ១៧.៨០៥.០០០ ដុល្លារអាមេរិក (២០១៥ ៖ ១២.៨០៥.០០០ ដុល្លារអាមេរិក) ដែលក្រុមហ៊ុនមេ បានបង់ប្រាក់រួចរាល់ហើយ ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ក្រុមហ៊ុនបានខ្ចីប្រាក់ពី International Finance Cooperation ក្នុងទឹកប្រាក់ចំនួន ៤.៧៩៨.០៣៣ ដុល្លារអាមេរិក ដែលមានកាលកំណត់សង និងមានការប្រាក់ថេរ ។

## ៣.៣ ការប៉ាន់ស្មានតម្លៃសមស្រប

ក្រុមហ៊ុនមិនមានទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ ដែលត្រូវបានវាស់វែង តាមតម្លៃសមស្របទេ។ វិធីសាស្ត្រ និងការសន្មត ដែលបានប្រើប្រាស់ក្នុងការប៉ាន់ស្មានតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាមតម្លៃសមស្រប មានដូចខាង ក្រោម ៖

(ក) សាច់ប្រាក់ និងសាច់ប្រាក់សមមូល - តម្លៃយោងនៃចំនួនទាំងនេះ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា ដោយសារ វាមានរយៈពេលខ្លី ។

(ខ) ប្រាក់បញ្ញើមានកាលកំណត់ - តម្លៃយោងនៃចំនួនទាំងនេះ មាន តម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា ដោយសារ កាលកំណត់របស់វា មានរយៈពេលតិចជាង១២ខែ ។

(គ) គណនីត្រូវទទួល និងគណនីត្រូវសងផ្សេងៗ - តម្លៃយោងនៃគណនី ត្រូវទទួល និងគណនីត្រូវសងផ្សេងៗ មានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្របរបស់វា ដោយសារគណនីទាំងនេះមានរយៈពេលខ្លី និងស្ថិតនៅក្រោមលក្ខខណ្ឌឥណទានធម្មតា ។

(ឃ) ប្រាក់កម្ចី - ប្រាក់កម្ចីដែលមានកាលកំណត់លើសពី១២ខែ ឬលើសពីនេះ តម្លៃសមស្របត្រូវបានប៉ាន់ស្មាន អាស្រ័យទៅតាមលំហូរសាច់ប្រាក់អប្បហារក្នុងកិច្ចសន្យា ដោយប្រើអត្រាការប្រាក់នៃប្រាក់កម្ចីនាដំណាច់ឆ្នាំ ដោយសារមិនមានអត្រាការប្រាក់លើទីផ្សារសម្រាប់ប្រាក់កម្ចីដែលមានហានិភ័យប្រហាក់ប្រហែលគ្នា ។

## ៤. ការប៉ាន់ស្មានគណនេយ្យសំខាន់ៗ និងការវិនិច្ឆ័យ

ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន និងសន្មតដោយផ្ដោតទៅលើកាលៈទេសៈនានាក្នុងពេលអនាគត។ តាមនិយមន័យ លទ្ធផលនៃការប៉ាន់ស្មានគណនេយ្យ កម្រដូចគ្នាជាមួយនឹងលទ្ធផលជាក់ស្ដែងណាស់។ ការប៉ាន់ស្មាន និងការសន្មត ដែលមានហានិភ័យជាសារវន្ត បណ្ដាលឱ្យមាននិយ័តកម្មធំដុំលើតម្លៃយោងទ្រព្យសកម្ម និងបំណុលនាការិយបរិច្ឆេទបន្ទាប់ ត្រូវបានបង្ហាញដូចខាងក្រោម៖

### ពន្ធ

ពន្ធត្រូវបានគណនា តាមមូលដ្ឋានបំណកស្រាយបទប្បញ្ញត្តិពន្ធដារនាពេលបច្ចុប្បន្ន។ ទោះជាយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទាំងនេះមានការខុសប្លែកគ្នាទៅតាមពេលវេលា ហើយការកំណត់ចំនួនពន្ធចុងក្រោយ នឹងត្រូវធ្វើឡើងបន្ទាប់ពីមានការត្រួតពិនិត្យរបស់អគ្គនាយកដ្ឋានពន្ធដារ។

លិខិតប្រកាសពន្ធរបស់ក្រុមហ៊ុន តម្រូវឲ្យមានការត្រួតពិនិត្យតាមគ្រាដោយអគ្គនាយកដ្ឋានពន្ធដារ។ ដោយសារការអនុវត្តច្បាប់ និងបទបញ្ញត្តិស្ដីពីពន្ធដារចំពោះប្រតិបត្តិការជាច្រើនប្រភេទ អាចនាំឱ្យមានការបកស្រាយផ្សេងៗគ្នា ដូចនេះ ចំនួនពន្ធដែលបានរាយការណ៍នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ អាចមានការត្រូវផ្លាស់ប្ដូរនាកាលបរិច្ឆេទបន្ទាប់ ក្រោយពីត្រូវបានធ្វើការវាយតម្លៃចុងក្រោយដោយអគ្គនាយកដ្ឋានពន្ធដារ ។

### អត្ថប្រយោជន៍ពេលចូលនិវត្ត

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្ត គឺអាស្រ័យទៅតាមកត្តាផ្សេងៗមួយចំនួន ដែលកំណត់ដោយថ្នាក់គ្រប់គ្រង ដោយប្រើប្រាស់ការសន្មតមួយចំនួន រួមមាន អត្រាកំណើនប្រាក់បៀវត្សរ៍ អត្រាចេញចូលរបស់បុគ្គលិក និងអត្រាមរណៈ។ ការសន្មតដែលបានប្រើប្រាស់ក្នុងការកំណត់ថ្លៃដើមសុទ្ធសម្រាប់អត្ថប្រយោជន៍ពេលចូលនិវត្ត រួមបញ្ចូលអត្រាអប្បហារ។ បម្រែបម្រួល ណាមួយក្នុងការសន្មតទាំងនេះ នឹងធ្វើឱ្យប៉ះពាល់ដល់តម្លៃនៃកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្ត ។

ដោយសារប្រទេសកម្ពុជា មិនមានសញ្ញាប័ណ្ណទីផ្សារ និងសញ្ញាប័ណ្ណរដ្ឋថ្នាក់គ្រប់គ្រង បានប្រើអត្រាការប្រាក់សម្រាប់ប្រាក់បញ្ញើមានកាលកំណត់រយៈពេល៦ឆ្នាំ របស់ក្រុមហ៊ុនមេ ជាអត្រាអប្បហារក្នុងការកំណត់តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ចេញប៉ាន់ស្មាន ដែលរំពឹងថានឹងត្រូវទូទាត់កាតព្វកិច្ចអត្ថប្រយោជន៍ចូលនិវត្ត ។

## ៥. ការផ្លាស់ប្ដូរមកអនុវត្ត CIFRS

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ គឺជារបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដំបូងគេ ដែលត្រូវបានរៀបចំឡើងដោយអនុលោមទៅតាម CIFRS ។

គោលការណ៍គណនេយ្យ CIFRS របស់ក្រុមហ៊ុន ដែលបានបង្ហាញក្នុងកំណត់សម្គាល់ ២ ត្រូវបានអនុវត្តក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ព័ត៌មានប្រៀបធៀប និងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដើមគ្រា ។

ផលប៉ះពាល់ក្នុងការផ្លាស់ប្ដូរមកអនុវត្ត CIFRS ត្រូវបានសង្ខេបដូចខាងក្រោម៖

### (ក) ការជ្រើសរើសក្នុងការផ្លាស់ប្ដូរ

តាមរយៈការផ្លាស់ប្ដូរនេះ CIFRS 1 អនុញ្ញាតឲ្យមានការលើកលែងពីការអនុវត្ត ត្រលប់ក្រោយឡើងវិញទាំងស្រុង។ ក្រុមហ៊ុនបានជ្រើសរើសមិនយកការលើកលែងណាមួយដែលមាននៅក្នុង CIFRS 1 ទេ។ ជាងនេះទៅទៀត មិនមានការលើកលែងសំខាន់ៗណាមួយ ដែលក្រុមហ៊ុនអាចអនុវត្តបានទេ។

### (ខ) ការផ្ទៀងផ្ទាត់រវាងមូលធន និងលទ្ធផលលម្អិត ដែលបានកត់ត្រាក្នុងគ្រាមុន ក្រោម CIFRS for SME ទៅនឹងការកត់ត្រាក្រោម CIFRS

មិនមានភាពខុសប្លែកគ្នាជាសារវន្តក្នុងការផ្ទៀងផ្ទាត់ រវាងការកត់ត្រាក្រោម CIFRS for SME និងការកត់ត្រាក្រោម CIFRS នូវខ្ទង់មូលធន គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និងលទ្ធផលលម្អិតសរុបសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ទេ ។

### (គ) និយ័តកម្មលើរបាយការណ៍លំហូរសាច់ប្រាក់

មិនមានភាពខុសប្លែកគ្នាជាសារវន្ត រវាងការកត់ត្រាក្រោម CIFRS for SME និងការកត់ត្រាក្រោម CIFRS នូវខ្ទង់នីមួយៗ ក្នុងលំហូរសាច់ប្រាក់ប្រតិបត្តិការលំហូរសាច់ប្រាក់វិនិយោគ និងលំហូរសាច់ប្រាក់ហិរញ្ញប្បទានទេ ។



ដំណើរទស្សនកិច្ចសិក្សារបស់និស្សិត វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា ទៅកាន់កសិដ្ឋានស្រែអំបិល ខេត្តកំពត

# ៦.ទ្រព្យសម្បត្តិ និងបរិក្ខារ

| | ដីធ្លី | ការកែលម្អ ដីធ្លី | ការកែលម្អ ទ្រព្យជួល | សង្ហារិម និង បរិក្ខារភ្ជាប់ | បរិក្ខារ ការិយាល័យ | កុំព្យូទ័រ | យានយន្ត | ការងារកំពុង ដំណើរការ | សរុប |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | | | | | | | | | |
| ថ្លៃដើម | | | | | | | | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ | ១២.២១៣.៩៣៦ | - | ១៤៩.០៥៦ | ៣៦.០៣៣ | ១៤០.៩២៥ | ១២៥.៨៥២ | ១០៨.៩០០ | ១.១២៤.១១៦ | ១៣.៨៩៨.៨១៨ |
| ទិញបន្ថែម | - | ១.០៨១.២០១ | ៦.១៣៨ | ៣៥០ | ១៥.៥៧៣ | ៧០.៤៦៩ | - | ១.៤៣០.៨៤១ | ២.៦០៤.៥៧២ |
| ផ្ទេរ | - | - | - | - | - | ៨.៦០៤ | - | (៨.៦០៤) | - |
| លក់ចេញ | - | - | (២.៨២៧) | - | (២.៩០៦) | - | - | - | (៥.៧៣៣) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | ១២.២១៣.៩៣៦ | ១.០៨១.២០១ | ១៥២.៣៦៧ | ៣៦.៣៨៣ | ១៥៣.៥៩២ | ២០៤.៩២៥ | ១០៨.៩០០ | ២.៥៤៦.៣៥៣ | ១៦.៤៩៧.៦៥៧ |
| **ដក៖ រំលស់បង្គរ** | | | | | | | | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ | - | - | ២០.៣៣២ | ១៤.២៨២ | ១០០.១៨៥ | ៨៩.៨០៨ | ៤៥.០៨៧ | - | ២៦៩.៦៩៤ |
| រំលស់ | - | ១៤.៨០១ | ៤៨.៥៣៥ | ៨.៣៣៤ | ២៨.១១០ | ៣៤.៣២៤ | ២១.៨២៧ | - | ១៥៥.៩៣១ |
| លក់ចេញ | - | - | (២.៨២៧) | - | (២.៧៤៩) | - | - | - | (៥.៥៧៦) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | - | ១៤.៨០១ | ៦៦.០៤០ | ២២.៦១៦ | ១២៥.៥៤៦ | ១២៤.១៣២ | ៦៦.៩១៤ | - | ៤២០.០៤៩ |
| **តម្លៃចុះបញ្ជីសុទ្ធគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | ១២.២១៣.៩៣៦ | ១.០៦៦.៤០០ | ៨៦.៣២៧ | ១៣.៧៦៧ | ២៨.០៤៦ | ៨០.៧៩៣ | ៤១.៩៨៦ | ២.៥៤៦.៣៥៣ | ១៦.០៧៧.៦០៨ |
| សមមូលនឹងពាន់រៀល | ៤៩.៣០៧.៦៦០ | ៤.៣០៥.០៥៧ | ៣៤៨.៥០២ | ៥៥.៥៧៣ | ១១៣.២២២ | ៣២៦.១៦១ | ១៦៩.៤៩៧ | ១០.២៧៩.៦២៧ | ៦៤.៩០៥.៣០៣ |

| | ដីធ្លី | ការកែលម្អ ដីធ្លី | ការកែលម្អ ទ្រព្យជួល | សង្ហារិម និង បរិក្ខារភ្ជាប់ | បរិក្ខារ ការិយាល័យ | កុំព្យូទ័រ | យានយន្ត | ការងារកំពុង ដំណើរការ | សរុប |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | | | | | | | | | |
| ថ្លៃដើម | | | | | | | | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ | ១២.២១៣.៩៣៦ | - | ១៥.៩៧០ | ១៤.៦៥២ | ១៣៤.៣៦០ | ១១៦.៨៩៣ | ១០៨.៩០០ | ៤៧.១៦៥ | ១២.៦៥១.៨៧៦ |
| ទិញបន្ថែម | - | - | ៦៥០ | ៤.៥៨៧ | ៧.១៥០ | ៨.៩៥៩ | - | ១.២២៦.១៨១ | ១.២៤៧.៥២៧ |
| ផ្ទេរ | - | - | ១៣២.៤៣៦ | ១៦.៧៩៤ | - | - | - | (១៤៩.២៣០) | - |
| លក់ចេញ | - | - | - | - | (៥៨៥) | - | - | - | (៥៨៥) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | ១២.២១៣.៩៣៦ | - | ១៤៩.០៥៦ | ៣៦.០៣៣ | ១៤០.៩២៥ | ១២៥.៨៥២ | ១០៨.៩០០ | ១.១២៤.១១៦ | ១៣.៨៩៨.៨១៨ |
| **ដក៖ រំលស់បង្គរ** | | | | | | | | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ | - | - | ៩.៦៦៦ | ១១.៣០៩ | ៦៨.៦០០ | ៥៨.៧៣១ | ២៣.៣១៩ | - | ១៧១.៦២៥ |
| រំលស់ | - | - | ១០.៦៦៦ | ២.៩៧៣ | ៣១.៩៧១ | ៣១.០៧៧ | ២១.៧៦៨ | - | ៩៨.៤៥៥ |
| លក់ចេញ | - | - | - | - | (៣៨៦) | - | - | - | (៣៨៦) |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | | - | ២០.៣៣២ | ១៤.២៨២ | ១០០.១៨៥ | ៨៩.៨០៨ | ៤៥.០៨៧ | - | ២៦៩.៦៩៤ |
| **តម្លៃចុះបញ្ជីសុទ្ធគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | ១២.២១៣.៩៣៦ | - | ១២៨.៧២៤ | ២១.៧៥១ | ៤០.៧៤០ | ៣៦.០៤៤ | ៦៣.៨១៣ | ១.១២៤.១១៦ | ១៣.៦២៩.១២៤ |
| សមមូលនឹងពាន់រៀល | ៤៩.៤៦៦.៤៤១ | - | ៥២១.៣៣២ | ៨៨.០៩២ | ១៦៤.៩៩៧ | ១៤៥.៩៧៨ | ២៥៨.៤៤២ | ៤.៥៥២.៦៧០ | ៥៥.១៩៧.៩៥២ |

ការផ្ទៀងផ្ទាត់ការទិញទ្រព្យសម្បត្តិ និងបរិក្ខារបន្ថែម ជាមួយនឹងលំហូរសាច់ប្រាក់មានដូចខាងក្រោម៖

| | ២០១៦ | | ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទិញបន្ថែម | ២.៦០៤.៥៧២ | ១០.៥៥៦.៣៣០ | ១.២៤៧.៥២៧ | ៥.០៦៤.៩៦០ |
| ដក៖ ការធ្វើមូលធនកម្មការប្រាក់លើទ្រព្យសកម្មដែលមានគុណវុឌ្ឍិ (ក) | (២៩.៦៦០) | (១២០.២១២) | - | - |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារក្នុងលំហូរសាច់ប្រាក់ | ២.៥៧៤.៩១២ | ១០.៤៣៦.១១៨ | ១.២៤៧.៥២៧ | ៥.០៦៤.៩៦០ |

(ក) អត្រាការប្រាក់ដែលបានធ្វើមូលធនកម្ម លើទ្រព្យសកម្មដែលមានគុណវុឌ្ឍិ ដែលទទួលបានពី International Finance Corporation ក្រោមលិខិតវិនិយោគលេខ ៣៥២៤២ គឺ ៧,៣៨៥% ក្នុងមួយឆ្នាំ ។

## ៧. ទ្រព្យសកម្មអរូបី

| | កម្មវិធីកុំព្យូទ័រ | សរុប |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | |
| ថ្លៃដើម | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ | ១.៤២៧ | ១.៤២៧ |
| ទិញបន្ថែម | ៣.៤៣១ | ៣.៤៣១ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | ៤.៨៥៨ | ៤.៨៥៨ |
| ដក៖ រំលស់បង្គរ | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ | ៧០៥ | ៧០៥ |
| រំលស់ | ៤៦៨ | ៤៦៨ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | ១.១៧៣ | ១.១៧៣ |
| តម្លៃចុះបញ្ជីសុទ្ធគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | ៣.៦៨៥ | ៣.៦៨៥ |
| សមមូលនឹងពាន់រៀល | ១៤.៨៧៦ | ១៤.៨៧៦ |

| | កម្មវិធីកុំព្យូទ័រ | សរុប |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | | |
| ថ្លៃដើម | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ | ១.៤២៧ | ១.៤២៧ |
| ទិញបន្ថែម | - | - |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | ១.៤២៧ | ១.៤២៧ |
| ដក៖ រំលស់បង្គរ | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥ | ៤២០ | ៤២០ |
| រំលស់ | ២៨៥ | ២៨៥ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | ៧០៥ | ៧០៥ |
| តម្លៃចុះបញ្ជីសុទ្ធគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | ៧២២ | ៧២២ |
| សមមូលនឹងពាន់រៀល | ២.៩២៤ | ២.៩២៤ |

## ៨. ពន្ធពន្យារទ្រព្យសកម្ម

| | ២០១៦ | | ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ពន្ធពន្យារទ្រព្យសកម្ម | ១៤៣.៤០១ | ៥៧៨.៩១០ | ៩៨.០៩៤ | ៣៩៧.២៨២ |
| បំណុលពន្ធពន្យារ | (៤.៥៨៧) | (១៨.៥១៨) | (២.២០២) | (៨.៩១៩) |
| | ១៣៨.៨១៤ | ៥៦០.៣៩២ | ៩៥.៨៩២ | ៣៨៨.៣៦៣ |

បម្រែបម្រួលពន្ធពន្យារទ្រព្យសកម្ម និងបំណុលពន្ធពន្យារក្នុងអំឡុងឆ្នាំ មានដូចខាងក្រោម:

| | ២០១៦ | | ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| គិតត្រឹមថ្ងៃទី០១ ខែមករា | ៩៥.៨៩២ | ៣៨៨.៣៦៣ | ៩១.៤៨០ | ៣៧២.៧៨១ |
| កត់ត្រាជាបន្ទុកក្នុងរបាយការណ៍ចំណេញ-ខាត | ៤២.៩២២ | ១៧៣.៩៦៣ | ៤.៤១២ | ១៧.៩១២ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១.៩៣៤) | - | (២.៣៣០) |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ | ១៣៨.៨១៤ | ៥៦០.៣៩២ | ៩៥.៨៩២ | ៣៨៨.៣៦៣ |

## ពន្ធពន្យារទ្រព្យសកម្ម

| | សំវិធានធន | ប្រាក់រង្វាន់បុគ្គលិក | ចំណូលមិនទាន់ទទួលបាន | ចំណេញពីការប្តូររូបិយប័ណ្ណដែលមិនទាន់ទទួលស្គាល់ | សរុប |
|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ៨៥.០២៧ | ៧.៧៤៩ | - | ៩១៤ | ៩៣.៦៩០ |
| កត់ត្រាជាបន្ទុកក្នុងរបាយការណ៍ចំណេញ-ខាត | ៣.០៥៣ | ១.៣៤៨ | - | ៣ | ៤.៤០៤ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | ៨៨.០៨០ | ៩.០៩៧ | - | ៩១៧ | ៩៨.០៩៤ |
| សមមូលនឹងពាន់រៀល | ៣៥៦.៧២៤ | ៣៦.៨៤៣ | - | ៣.៧១០ | ៣៩៧.២៧៧ |
| គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ | ៨៨.០៨០ | ៩.០៩៧ | - | ៩១៧ | ៩៨.០៩៤ |
| កត់ត្រាជាបន្ទុក/(ឥណទាន) ក្នុងរបាយការណ៍ចំណេញ-ខាត | ៣.៩៧៣ | ១៨៥ | ៤១.៤០៦ | (២៥៧) | ៤៥.៣០៧ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | ៩២.០៥៣ | ៩.២៨២ | ៤១.៤០៦ | ៦៦០ | ១៤៣.៤០១ |
| សមមូលនឹងពាន់រៀល | ៣៧១.៦១៨ | ៣៧.៤៧១ | ១៦៧.១៥៦ | ២.៦៦៤ | ៥៧៨.៩០៩ |

## បំណុលពន្ធពន្យារ

| | រំលស់ពន្លឿន | សរុប |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ២.២១០ | ២.២១០ |
| កត់ត្រាជាបន្ទុកក្នុងរបាយការណ៍ចំណេញ-ខាត | (៨) | (៨) |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | ២.២០២ | ២.២០២ |
| សមមូលនឹងពាន់រៀល | ៨.៩១៨ | ៨.៩១៨ |
| គិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ | ២.២០១ | ២.២០១ |
| កត់ត្រាជាបន្ទុកក្នុងរបាយការណ៍ចំណេញ-ខាត | ២.៣៨៥ | ២.៣៨៥ |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | ៤.៥៨៦ | ៤.៥៨៦ |
| សមមូលនឹងពាន់រៀល | ១៨.៥១៤ | ១៨.៥១៨ |

## ៩. ប្រាក់តម្កល់តាមច្បាប់

អនុលោមតាមប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ ២៩៥ ស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់គ្រឹះស្ថានឧត្តមសិក្សាឯកជន តម្រូវឲ្យ វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា តម្កល់ប្រាក់បញ្ញើអប្បបរមាទៅក្នុងគណនីធនាគាររបស់ អគ្គនាយកដ្ឋានរតនាគារជាតិ ដែលរក្សាទុកនៅធនាគារកណ្តាល ក្នុងទឹកប្រាក់ចំនួន ២៤០.០០០.០០០ រៀល (ប្រមាណជា ៥៩.៤៥០ ដុល្លារអាមេរិក) ដើម្បីធ្វើប្រតិបត្តិការអាជីវកម្មគ្រឹះស្ថានឧត្តមសិក្សាឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ១០. ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់លក់

| | ២០១៦ | | ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| មូលបត្រកម្មសិទ្ធិមិនបានចុះបញ្ជី | | | | |
| គិតត្រឹមថ្ងៃទី០១ ខែមករា | ៣៧.២៩២ | ១៥១.០៣៣ | ៣៧.២៩២ | ១៥១.៩៦៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (៤៨៥) | - | (៩៣២) |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ (*) | ៣៧.២៩២ | ១៥០.៥៤៨ | ៣៧.២៩២ | ១៥១.០៣៣ |

(*) នេះគឺជាការវិនិយោគរបស់ក្រុមហ៊ុនក្នុងធនាគារ អេស៊ីលីដា ឡាវ ចំនួន ០,១% ជាការវិនិយោគមូលធន ។

## ១១. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ២០១៦ | | ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| សាច់ប្រាក់ក្នុងដៃ | ៧.៣១៩ | ២៩.៥៤៧ | ២.១៩១ | ៨.៨៧៤ |
| សាច់ប្រាក់នៅធនាគារ | ១.៣១២.៣៧១ | ៥.២៩៨.០៤២ | ៨៨.៣៤២ | ៣៥៧.៧៨៥ |
| | ១.៣១៩.៦៩០ | ៥.៣២៧.៥៨៩ | ៩០.៥៣៣ | ៣៦៦.៦៥៩ |

សាច់ប្រាក់នៅធនាគាររួមមានគណនីចរន្តដែលគ្មានការប្រាក់ និងប្រាក់បញ្ញើមានកាលកំណត់រយៈពេលបីខែ ដែលមានអត្រាការប្រាក់ ១,៥០% ក្នុងមួយឆ្នាំ (២០១៥ ៖ ៥% ក្នុងមួយឆ្នាំ) ដែលបានរក្សាទុកនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាក្រុមហ៊ុនមេ ។

## ១២. ប្រាក់បញ្ញើមានកាលកំណត់

| | ២០១៦ | | ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រយៈពេល៦ខែ | ៨.៨៥០.០០០ | ៣៥.៧២៧.៤៥០ | ១.៣៥០.០០០ | ៥.៤៦៧.៥០០ |
| រយៈពេល១២ខែ | - | - | ១.៣៨៥.៥៤០ | ៥.៦១១.៤៣៧ |
| បង្គរការប្រាក់ត្រូវទទួល | ៩២.៥៥០ | ៣៧៣.៦២៤ | ១១២.៥០៨ | ៤៥៥.៦៥៧ |
| | ៨.៩៤២.៥៥០ | ៣៦.១០១.០៧៤ | ២.៨៤៨.០៤៨ | ១១.៥៣៤.៥៩៤ |

ប្រាក់បញ្ញើមានកាលកំណត់ត្រូវបានរក្សាទុកនៅធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលមានអត្រាការប្រាក់ក្នុងចន្លោះពី ៥% ទៅ ៦,៥០% ក្នុងមួយឆ្នាំ (២០១៥ ៖ ៦,៥០% ទៅ ៧% ក្នុងមួយឆ្នាំ)។

## ១៣. គណនីត្រូវទទួលផ្សេងៗ

| | ២០១៦ | | ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ពន្ធកាត់ទុកត្រូវទទួល | ១១.៦៨៩ | ៤៧.១៨៩ | - | - |
| ចំណាយបង់មុន | ៦.៨១៥ | ២៧.៥១២ | ៤៦.៦៨៤ | ១៨៩.០៧០ |
| ទឹកប្រាក់ធនាគារ អេស៊ីលីដា ភីអិលស៊ី ជំពាក់ (កំណត់សម្គាល់ ២៤) | - | - | ១០.៦០៥ | ៤២.៩៥០ |
| គណនីត្រូវទទួលពីកម្រៃបណ្ដុះបណ្ដាល | - | - | ១៥ | ៦១ |
| ផ្សេងៗ | ៨.៣៥៦ | ៣៣.៧៣៣ | ៨.៧៧៩ | ៣៥.៥៥៥ |
| | ២៦.៨៦០ | ១០៨.៤៣៤ | ៦៦.០៨៣ | ២៦៧.៦៣៦ |

## ១៤. ដើមទុន

ក្រុមហ៊ុនបានចុះបញ្ជីដើមទុនរបស់ខ្លួនចំនួន ១២.៨០៥.០០០ ដុល្លារអាមេរិក ជាមួយក្រសួងពាណិជ្ជកម្ម ដោយបានបែងចែកទៅជា ១២.៨០៥.០០០ភាគហ៊ុន ដែលមានតម្លៃចារិក១ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន។រាល់ដើមទុនទាំងអស់ត្រូវបានបង់រួចរាល់ទាំងស្រុង។នៅថ្ងៃទី១៨ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រុមហ៊ុនបានបន្ថែមដើមទុនបង់រួចចំនួន ៥.០០០.០០០ ដុល្លារអាមេរិក ដោយបានបែងចែកទៅជា ៥.០០០.០០០ភាគហ៊ុន ដែលមានតម្លៃចារិក១ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន។ គិតត្រឹមកាលបរិច្ឆេទរាយការណ៍ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានបង់ប្រាក់លើដើមទុនរួចរាល់ទាំងស្រុង ។

| | ២០១៦ | | ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| គិតត្រឹមថ្ងៃទី០១ ខែមករា | ១២.៨០៥.០០០ | ៥១.៨៦០.២៥០ | ១២.៨០៥.០០០ | ៥២.១៨០.៣៧៥ |
| ដើមទុនបន្ថែមបានបង់ | ៥.០០០.០០០ | ២០.២៦៥.០០០ | - | - |
| លម្អៀងពីការប្ដូររូបិយប័ណ្ណ | - | (២៤៦.៤៦៥) | - | (៣២០.១២៥) |
| គិតត្រឹមថ្ងៃទី៣១ ខែធ្នូ | ១៧.៨០៥.០០០ | ៧១.៨៧៨.៧៨៥ | ១២.៨០៥.០០០ | ៥១.៨៦០.២៥០ |

## ១៥. ប្រាក់កម្ចី

| | ២០១៦ | | ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| International Finance Corporation: | | | | |
| ប្រាក់កម្ចី | ៤.៧៩៨.០៣៣ | ១៩.៣៦៩.៦៥៩ | - | - |
| បង្គរការប្រាក់ត្រូវបង់ | ១៩.០៧៧ | ៧៧.០១៥ | - | - |
| | ៤.៨១៧.១១០ | ១៩.៤៤៦.៦៧៤ | - | - |




ថតរូបអនុស្សាវរីយ នាយកវិទ្យាស្ថាន ជាមួយសិស្សដែលបានទទួលអាហារូបករណ៍ ពី វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា

ខ និង លក្ខខណ្ឌនៃប្រាក់កម្ចីនេះ មានដូចខាងក្រោម៖

| ម្ចាស់ប្រាក់កម្ចី | កាលបរិច្ឆេទដកប្រាក់ | កាលបរិច្ឆេទផុតកំណត់ | កម្រិតប្រាក់កម្ចី ដុល្លារអាមេរិក | អត្រាការប្រាក់ | អ្នកធានា | ខ និងលក្ខខណ្ឌផ្សេងៗ |
|---|---|---|---|---|---|---|
